**competent adj.** មានសមត្ថកិច្ច, មានសមត្ថភាព, ~ authority អាជ្ញាធរមានសមត្ថកិច្ច, ~ party ភាគីមានសមត្ថកិច្ច
**competing lines** មុខទំនិញប្រកួតប្រជែង
**competition** ការប្រកួតប្រជែង, សារម្ភ, free ~ ការប្រកួតប្រជែងសេរី
**competitive** ដែលប្រជែង, ~ advantage ឧត្តមភាពប្រជែង, ~ examination ការប្រលងប្រជែង, ~ market ផ្សារប្រកួតប្រជែង, ~ price ថ្លៃប្រកួតប្រជែង
**competitiveness** ភាពប្រកួតប្រជែង, ភាពដេញជើងគ្នា
**competitor** អ្នកប្រជែង ( ថ្លៃ, ទីផ្សារ.. )
**compile v.** ចងក្រង
**complain v.** ត្អូញត្អែរ, តវ៉ា
**complainant** អ្នកប្តឹងតវ៉ា
**complaint** បណ្តឹង, ពាក្យបណ្តឹង
**complementary** ដែលបំពេញឱ្យគ្នាទៅមក
**completion** ការបញ្ចប់, ការបង្ហើយ, ~ of a contract ការបញ្ចប់កិច្ចសន្យា
**complex adj.** មិស្សភាព ( ស្មុគស្មាញ ) superiority ~ សេយ្យមានះ, inferiority ~ ហីនមានះ, complexity មិស្សភាព
**complex business plan** ប្លង់អាជីវកម្មស្មុគស្មាញ
**complex multi-stage design** ប្លង់ច្រើនដំណាក់មិនសាមញ្ញ
**complexity** ភាពស្មុគស្មាញ, ភាពសាំញ៉ាំ
**compliance with, in** ស្របជាមួយ
**complicate v.** ធ្វើអោយស្មុគស្មាញ
**complicity** ការចូលដៃ
**complimentary** ១. ដែលសសើរ ២. ដែលអោយទទេ ( ឥតគិតថ្លៃ )
**comply** ប្រតិបត្តិតាម, ធ្វើតាម

**component** សមាសភាគ, ធាតុផ្សំ
**composition** សមាសភាព
**compound entry** លេខនាផ្គុំ (លេខនាមានប្រើចាប់ពីបីគណនីឡើងទៅ)
**compound growth** វឌ្ឍនភាពសមាស
**compound interest** ការប្រាក់សមាស
**comprehensive adj.** គ្រប់ជ្រុងជ្រោយ, ទូលំទូលាយ, ~ analysis ការវិភាគគ្រប់ជ្រុងជ្រោយ
**compromise** ការស្រុះស្រួល
**comptroller** អ្នកត្រួតពិនិត្យខាងហិរញ្ញវត្ថុ
**compulsory** ជាកាតព្វកិច្ច, ដែលខានមិនបាន, ~ inspection អធិការកិច្ចជាកាតព្វកិច្ច
**computable** ដែលអាចគណនាបាន
**computer virus** វីរុស/វិសាណូ កុំព្យូទ័រ
**comrade n.** សមមិត្ត, សហជីវិន, ពួកម៉ាក
**conceal v.** លាក់លៀម
**concealment** ការលាក់លៀម
**concentration** ការប្រមូលផ្តុំ, land ~ ការប្រមូលផ្តុំដីធ្លី, ~ level of a substance កំរិតកំហាប់នៃសារធាតុ
**concept** គោលគំនិត, ទស្សនាទាន
**conception** ទស្សនាទាន
**conceptual error** ល្បៀងផ្នែកទស្សនាទាន
**conceptualise v.** គិតគូរបង្កើតថ្មី
**concern** កង្វល់, ព្រួយបារម្ភ, business ~ គ្រឹះស្ថាន (ជំនួញ), his business is a going ~ មុខជំនួញរបស់គាត់កំពុងដំណើរការទៅមុខ (និងមានចំណេញ)
**concerned** ដែលពាក់ព័ន្ធ, ~ ministry ក្រសួងពាក់ព័ន្ធ
**concert, act in v.** ធ្វើសកម្មភាពរួមគ្នា (ដើម្បីសំរេចគោលដៅអ្វីមួយ)
**concerted economic action** សកម្មភាពសេដ្ឋកិច្ចមានវគ្គមានស្មើ
**concession** សម្បទាន, forest ~ សម្បទានព្រៃឈើ, ~ holder សម្បទានិក, social land ~ សម្បទានដីសង្គមកិច្ច, price ~ សម្បទានថ្លៃ
**concessionaire** សម្បទានិក, forest ~ ព្រៃសម្បទានិក
**concessional, concessionary** ដែលផ្តល់សម្បទាន/អនុគ្រោះ, ~ loan កំចីផ្តល់សម្បទាន, ~ terms លក្ខខណ្ឌសម្បទាន
**conciliate v.** ផ្សះផ្សា
**conclusion n.** សន្និដ្ឋាន, អវសានកថា (ភាគបញ្ចប់នៃរបាយការណ៍)
**concrete measure** វិធានការជាក់ស្តែង
**concurrence** ១. ការយល់ព្រម, ការឯកភាព ២.ការកើតដំណាលគ្នា (ព្រឹត្តិការណ៍)
**condition** លក្ខខណ្ឌ, working ~ លក្ខខណ្ឌធ្វើការងារ, ~ precedent លក្ខខណ្ឌបង្កើតកាតព្វកិច្ច, ~ subsequent លក្ខខណ្ឌបញ្ចប់កាតព្វកិច្ច
**conditional** ដោយមានលក្ខខណ្ឌ, ~ acceptance ការទទួលព្រមដោយមានលក្ខខណ្ឌ
**conditionality** ភាពមានលក្ខខណ្ឌ
**conducive to** អំណោយផលដល់
**conduct** កិរិយាមាយាទ, ការប្រព្រឹត្តិ(ខ្លួន)
**conduct v. & n.** ១. ដឹកនាំ, ធ្វើ, ដំណើរការ ២. ~ of business កិច្ចដំណើរការធ្វើអាជីវកម្ម
**conference** សន្និសីទ
**confession n.** ការសារភាព, សច្ចាវីករណ៍
**confidential** សំងាត់

**confirmation** ការបញ្ជាក់, ~ of order ការបញ្ជាក់នូវការបញ្ជាទិញ, ~ of price ការបញ្ជាក់ថ្លៃ
**confirmed letter of credit** សារឥណទានអនុសិទ្ធិ
**confirming bank** ធនាគារបញ្ជាក់
**confiscate** រឹបអូស (យកទ្រព្យ), ដកហូត
**conflict** ទំនាស់, ~ of interest ទំនាស់ផលប្រយោជន៍
**confrontation n.** ការប្រទល់មុខគ្នា, សម្មុខីកម្ម, ~ meeting ការប្រជុំទល់មុខគ្នា
**confusing** ច្រឡំបល់, ងាយភ័ន្តច្រឡំ
**confusion** ការភ័ន្តច្រឡំ, ការច្រឡំបល់, ការច្របូកច្របល់
**conglomerate** ក្រុមហ៊ុនពហុផលិតផល
**conscience** មនសិការ
**conscientious** ដែលមានមនសិការ, ដែលយកចិត្តទុកដាក់
**consensus** ការមូលមតិ, កុងសង់ស៊ុស
**consent v. & n.** ១. ព្រម ២. ការយល់ព្រម
**consequential** ដែលជាវិបាក
**conservation** អភិរក្ស,ការរក្សា, ~ of nature អភិរក្សធម្មជាតិ, soil ~ អភិរក្សដី
**conservative adj.** អភិរក្ស
**consideration** ការពិចារណា, under ~ កំពុងពិនិត្យពិចារណា
**consignee** អ្នកទទួលទំនិញ
**consignee's account, all charges to** រាល់សោហ៊ុយចំណាយជាបន្ទុករបស់អ្នកទទួលទំនិញ
**consignment n.** ១. ការបញ្ជូនទំនិញ, ~ note លិខិតបញ្ជូនទំនិញ ២. អីវ៉ាន់មួយក្រុម (ឧ.មួយកុងតឺន័រ) ដែលបញ្ជូនទៅ
**consignor** អ្នកបញ្ជូនទំនិញ
**consistency** ១. សង្គតភាព, ភាពស៊ីគ្នា ២. ភាពមិនផ្លាស់ប្តូរ
**consolidated** (information) (ព័ត៌មាន) ច្របាច់បញ្ចូលគ្នា
**consolidated balance sheet** តារាងតុល្យការសរុប (បូកចូលថែមនូវបុត្រសម្ព័ន្ធ...)
**consolidation of balance sheets** ការច្របាច់បញ្ចូលគ្នានូវតារាងតុល្យការ
**consortium** កុងស័រស្យូម, សមាគម
**conspiracy n.** ការគិតក្បត់, សហក្បត់ (ការរួមគំនិតក្បត់)
**constant** ថេរ, ~ price ថ្លៃថេរ
**constituency** មជ្ឈដ្ឋានអ្នកគាំទ្រ, មណ្ឌលបោះឆ្នោត
**constitution** រដ្ឋធម្មនុញ្ញ
**Constitutional Council** ក្រុមប្រឹក្សាធម្មនុញ្ញ
**constitutionality** ធម្មនុញ្ញភាព
**constraint** កំហិត (ឧបសគ្គ)
**constructive** ជាលក្ខណៈកសាង, ~ criticism ការទិតៀនជាលក្ខណៈកសាង
**consultancy** ការផ្តល់យោបល់ឯកទេស
**consultant** អ្នកពិគ្រោះយោបល់
**consultation** ការពិគ្រោះយោបល់
**Consultative Group** (CG) ក្រុមពិគ្រោះយោបល់
**consumables** វត្ថុធាតុប្រើប្រាស់
**consume v.** ប្រើប្រាស់ (ស្បៀងអាហារ, ឥន្ធនៈ...)
**consumer** អ្នកប្រើប្រាស់, ~ basket កន្ត្រកទំនិញប្រើប្រាស់, ~ credit ឥណទានសំរាប់ទិញទំនិញប្រើប្រាស់, ~ goods ទំនិញប្រើប្រាស់, ~ price ថ្លៃទំនិញប្រើប្រាស់ (ថ្លៃលក់រាយ), ~ price index (CPI) សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់, ~ surplus ផលចំណេញនៃអ្នកប្រើប្រាស់

**consumption** ការប្រើប្រាស់, ~ expenditures ចំណាយប្រើប្រាស់, home (domestic) ~ ការប្រើប្រាស់ក្នុងស្រុក, ~ curve ខ្សែកោងប្រើប្រាស់

**contact** ការជួបទាក់ទង, ~ person មនុស្សសំរាប់ជួបទាក់ទង

**container** កុងតឺន័រ (ផ្ទុកទំនិញ)

**contemporary** សហកាល, សហសម័យ

**contempt** ការមើលងាយ, ~ of court ការប្រមាថតុលាការ

**content** ១. ខ្លឹមសារ ២. មាតិកា

**contest n.** ការប្រជែង, ការប្រកួត, ~ a decision ជំទាស់តវ៉ានឹងសេចក្ដីសំរេច

**context** បរិបទ, បរិការណ៍

**contingency** យថាភាព, ការឥតព្រាងទុក, ~ beneficiary អត្ថគាហកជាយថាហេតុ, ~ plan ផែនការទុកអនុវត្តជាយថាហេតុ

**contingent adj.** អាស្រ័យលើ (ព្រឹត្តិការណ៍អ្វីមួយដែលអាចកើតឡើង រឺមិនកើតឡើង), អនិមិត្ត

**continuity** និរន្តរភាព

**continuous adj.** បន្តរហូត, បន្តជាប់

**contra account** គណនីបដិភាគ

**contra entry** លេខនាបញ្ច្រាស (ដើម្បីលុបចោលនូវលេខនាមុន)

**contraband** ទំនិញរត់ពន្ធ

**contraception** ការបង្ការកំណើត

**contract** កិច្ចសន្យា, ~ of insurance កិច្ចសន្យាធានារ៉ាប់រង, ~ of sale កិច្ចសន្យាលក់, ~ of work កិច្ចសន្យាការងារ

**contract** (public) **employee** បុគ្គលិក(រដ្ឋ)ជាប់កិច្ចសន្យា

**contract law** ច្បាប់កិច្ចសន្យា

**contract v. out of an agreement** ដក ឬលុបកិច្ចសន្យា (ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីភាគីម្ខាងទៀត)

**contract v.** ១. ចុះកិច្ចសន្យា ២. រួមចុះ (សេដ្ឋកិច្ច)

**contract, under** ជាប់កិច្ចសន្យា, ក្រោមកិច្ចសន្យា

**contracting party** ភាគីចុះកិច្ចសន្យា

**contractor** អ្នកចុះកិច្ចសន្យា, អ្នកម៉ៅការ, sub-contractor អ្នកម៉ៅការបន្ត

**contractual business** អាជីវកម្មឈរលើកិច្ចសន្យា

**contradiction** បដិវាទកម្ម, ភាពផ្ទុយគ្នា

**contradictory** ដែលផ្ទុយគ្នា

**contrast n.** ភាពផ្ទុយគ្នា, ព្យតិរេក

**contra-transfer** ចុះបញ្ច្រាស, ធ្វើប្រតិក្រាន្តលេខនា

**contravene v.** ល្មើស, បំពាន

**contribute v.** រួមវិភាគទាន, រួមចំណែក

**contribution** វិភាគទាន, ការរួមចំណែក, ~ in kind វិភាគទានជាសំភារៈ

**control v.** ត្រួតពិនិត្យ, ត្រួតត្រា

**controllable expenses** ចំណាយគ្រប់គ្រងបាន

**controlled selection** ជំរើសមានការត្រួតពិនិត្យ

**controller** អ្នកត្រួតពិនិត្យ

**controlling interest, have a** មានចំណែកភាគហ៊ុនត្រួតត្រា (គឺមានលើសពី ៥0%នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុន)

**controversy** វាទប្បដិវាទ (រឺ វាទប្រតិវាទ រឺការជជែករកខុសត្រូវជាសាធារណៈ)

**contumacy n.** ទុដ្ឋភាព (ការមិនព្រមចូលខ្លួនទៅតុលាការ)

**convenience food** អាហារវេចខ្ចប់ស្រាប់

(ដែលស្រួល រៀបចំ/ចំអិន)
**convention** ១. អនុសញ្ញា ២. សន្និបាត ៣. សន្ធិកម្ម/ការសន្មត
**conversation** ការសន្ទនា, សន្ទនាការ
**conversion** ការប្តូរ, ~ price/rate អត្រាប្តូរ (ដើម្បីគិតប្តូររូបិយវត្ថុមួយទៅជារូបិយវត្ថុបរទេស)
**convertible currency** រូបិយវត្ថុដែលអាចប្តូរយករូបិយវត្ថុផ្សេងបាន
**conveyance** ១. ការផ្ទេរ (កម្មសិទ្ធិ) ២. ឯកសារផ្ទេរ
**convict** ទណ្ឌិត (អ្នកជាប់ពន្ធនាគារ)
**cooperate v.** ធ្វើសហប្រតិបត្តិការ
**cooperative adj. & n.** ១. ដែលធ្វើសហប្រតិបត្តិការ ២. សហករណ៍
**coordinates** និយាមការ (រយៈទទឹង/រយៈបណ្តោយ)
**co-owner, co-proprietor** សហកម្មសិទ្ធិករ, ម្ចាស់កម្មសិទ្ធិរួមគ្នា
**co-ownership** សហកម្មសិទ្ធិ
**co-property** ទ្រព្យសម្បត្តិរួមគ្នា
**copyright** សិទ្ធិចំលង, រក្សាសិទ្ធិ
**core** ស្នូល, ~ budget ថវិកាស្នូល, ~ funding មូលនិធិស្នូល, ~ resources ធនធានស្នូល
**corn n.** (US) ពោត, baby ~ ស្ងៀតពោត (បន្លែ)
**corporate state** រដ្ឋសហគ្រិន
**corporation** សាជីវកម្ម, multinational ~ សាជីវកម្មពហុជាតិ, ~ tax (GB) ពន្ធលើប្រាក់ចំណេញក្រុមហ៊ុន
**correct adj.** ត្រឹមត្រូវ
**correlated response variance** វ៉ារីយ៉ង់ចំលើយទាក់ទិន
**correlation** សហសម្ព័ន្ធ, ទំនាក់ទំនង
**correspondence, business** ការសរសេរទាក់ទងខាងជំនួញ, លិខិតឆ្លើយឆ្លងអាជីវកម្ម
**correspondent bank** ធនាគារឆ្លើយឆ្លង
**corridor** របៀង, ថែវ, economic ~ របៀងសេដ្ឋកិច្ច
**corroborate v.** បញ្ជាក់/អះអាង បន្ថែម, ធ្វើបមាណីយករណ៍
**corruption n.** អំពើពុករលួយ
**cost** ១. តំលៃ ២. បរិយាទាន ៣. ថ្លៃដើម ៤. បន្ទុកចំណាយ, ចំណាយ
**cost accounting** គណនេយ្យថ្លៃដើម, គណនេយ្យវិភាគ
**cost and freight** (C & F) ថ្លៃទំនិញបូកថ្លៃដឹកជញ្ជូន
**cost of goods sold or cost of sales** ថ្លៃដើមទំនិញលក់ចេញ
**cost of living** ថ្លៃទ្រទ្រង់ជីវភាព
**cost price** ថ្លៃដើម
**cost, historical** តំលៃទិញចូល
**cost, insurance, freight** (CIF) ថ្លៃទំនិញបូកថ្លៃធានារ៉ាប់រងបូកថ្លៃដឹកជញ្ជូន
**cost, manufacturing** ថ្លៃដើមផលិតកម្ម
**cost-benefit analysis** ការវិភាគចំណាយនិងផលចំណេញ
**cost-effective adj.** ដែលមានប្រសិទ្ធភាពចំណាយ
**costing** ការគណនាថ្លៃដើម
**Council of Ministers** ទីស្តីការគណៈរដ្ឋមន្ត្រី
**counter** បញ្ជរ
**counter party** បដិភាគី
**counter valuation** បដិកោសលវិច្ឆ័យ
**counterbalance v.** រាំងខ្ទប់តទិ្វពល
**countermand** បដិសេធបង្គាប់មុនចោល,

ចេញប្រតិអាណត្តិ
**counter-offer** ការអោយថ្លៃលើ ( ដើម្បីប្រជែងទិញ)
**counterpart** សមភាគី
**counterpart adj.** បដិភាគ, ~ entry លេខនាបដិភាគ, ~ fund មូលនិធិបដិភាគ
**counter-revolution n.** ប្រតិបដិវត្តន៍
**country report** របាយការណ៍ស្តីពីប្រទេស
**country-representative office** ការិយាល័យតំណាងប្រចាំប្រទេស
**country-risk analysis** ការវិភាគគ្រោះប្រទេស
**coupe, forest** ព្រៃគុប
**court clerks** ក្រឡាបញ្ជី
**court or lawcourt** សាលា កាត់ក្តី/ជំរះក្តី
**covenant** ការព្រមព្រៀងជាផ្លូវការ
**cover note** (insurance) កំណត់សំអាង ( ធានារ៉ាប់រង)
**cover price** ថ្លៃលើក្រប ( ថ្លៃលក់វាយចុះលើក្របសៀវភៅ, ទស្សនាវដ្តី ...)
**cover, banking** ប្រាក់ធានា
**cover, full** (insurance) ប័ណ្ណធានារ៉ាប់រងលើហានិភ័យគ្រប់ប្រភេទ
**cover, temporary** (insurance) ប័ណ្ណធានារ៉ាប់រងបណ្តោះអាសន្ន
**coverage** ការ/ទំហំ គ្របដណ្តប់ ( ឧ. ដោយប័ណ្ណធានារ៉ាប់រង)
**craftsmanship n.** ហត្ថកោសល្យ
**creation n.** ការបង្កើត, មាបនកម្ម, និម្មិតកម្ម, មាបនវត្ថុ
**creative thinking** គំនិតច្នៃប្រឌិត
**creativity** គំនិតច្នៃប្រឌិត
**credibility** ភាពគួរឱ្យជឿ, កិត្តិនាម
**credit bank** ធនាគារឥណទាន
**credit bureau** ការិយាល័យផ្តល់ព័ត៌មានពីកិត្តិនាម ( នៃសហគ្រាស...)
**credit in kind** ឥណទានវត្ថុ ( មិនមែនជាប្រាក់)
**credit institution** ស្ថាប័នឥណទាន
**credit market** ទីផ្សារឥណទាន
**credit n. & adj. & v.** ១. ឥណទាន ២. ឥណទាយី ៣. កត់ត្រាខាងឥណទាន
**credit plus** ឥណទានបូក ( ឥណទានដែលគិតគូរទាំងការជួយជាប្រាក់កាស និងបច្ចេកទេស)
**credit rating** ចំណាត់ថ្នាក់ឥណទាន, សមត្ថភាពសងបំណុលរបស់អ្នកខ្ចី
**credit restrictions** កំហិតនៃឥណទាន
**credit risk** ហានិភ័យនៃឥណទាន
**credit sale** ការលក់ជឿ
**credit slip** ប័ណ្ណសំណៅឥណទាន, សក្ខីប័ត្រឥណទាន
**credit solvency** លទ្ធភាពសងបំណុល
**credit status** ជំហរឥណទាន
**credit terms** លក្ខខណ្ឌឥណទាន
**credit worthiness** ភាពគួរបានទទួលឥណទាន
**credit worthy borrower** អ្នកខ្ចីប្រាក់ដែលគួរអោយទុកចិត្ត
**credit, open** ឥណទានគ្មានដាក់វត្ថុធានា ( សំរាប់អតិថិជនល្អរបស់ធនាគារ)
**credit, tax** ឥណទានពន្ធ
**credit, trade** ឥណទានជំនួញ ( ផ្តល់ឱ្យសហគ្រាសមានទំនាក់ទំនងជំនួញជាមួយគ្នា)
**creditor** ឥណទាយក, ម្ចាស់បំណុល
**credulity n.** ភាពងាយជឿ, សទ្ធាលុភាព
**creeping inflation** អតិផរណាសន្សឹមៗ

**crime** បទល្មើសព្រហ្មទ័ណ្ឌ
**criteria, criterion** លក្ខណៈវិនិច្ឆ័យ
**crop n.** ដំណាំ, ផលដំណាំ, supplementary ~ ដំណាំរួមផ្សំ
**cross check** ផ្ទៀងគ្នាទៅវិញទៅមក
**cross class** ថ្នាក់ឆ្លង
**cross rate, exchange cross rate** អត្រាប្តូររូបិយប័ណ្ណផ្ទៀងផ្ទាត់ ( អត្រាប្តូរប្រាក់ធៀបតាម រូបិយវត្ថុទី៣ ដូចជា ដុល្លារ)
**cross border** (trade) ឆ្លងកាត់ព្រំដែន (ពាណិជ្ជកម្ម)
**crossed cheque** មូលប្បទានប័ត្រឆូត
**cross-examine v.** ការសួរបញ្ជាក់សាក្សីផ្ទៀងផ្ទាត់នឹងចំលើយពេលមុន
**cross-voting n.** ការបោះឆ្នោតអោយគណបក្សផ្សេង ( មិនមែនគណបក្សខ្លួន)
**crude oil** ប្រេងឆៅ
**culprit n.** ពិរុទ្ធិកជន
**cultivated land** ដីដាំដុះ
**culture** វប្បធម៌, ~ of impunity វប្បធម៌រួចទោស
**cumulated list** បញ្ជីបូកត្រួត
**curb v.** ទប់ស្កាត់
**curfew** បំរាមគោចរ
**currency** រូបិយវត្ថុ, hard ~ រូបិយវត្ថុខ្លាំង (របស់ប្រទេសមានសេដ្ឋកិច្ចមាំមួន និងងាយប្តូរយករូបិយវត្ថុផ្សេងទៀត), soft ~ រូបិយវត្ថុខ្សោយ
**currency in circulation** រូបិយវត្ថុក្នុងចរាចរ
**currency of account** រូបិយវត្ថុយកមកគិតគូរ
**currency of payment** រូបិយវត្ថុទូទាត់
**currency of the contract** រូបិយវត្ថុនៃកិច្ចសន្យា
**currency operation** ប្រតិបត្តិការលើរូបិយវត្ថុ ( ដូចជាការប្តូរប្រាក់ជាដើម )
**current account or checking account** (US) គណនីចរន្ត
**current adj.** ចរន្ត, ~ expenditures ចំណាយចរន្ត
**current assets** ទ្រព្យសកម្ម ចរន្ត/ចល័ត
**current liabilities** ទ្រព្យអកម្មចរន្ត
**current price** ថ្លៃចរន្ត, ថ្លៃបច្ចុប្បន្ន, ~ list តារាងថ្លៃចរន្ត
**current revenue** ចំណូលចរន្ត ( *ចំណូលជាប្រចាំ* ក្នុងឯកសារខ្លះ)
**current account holder** ម្ចាស់គណនីចរន្ត
**current market rate** អត្រាថ្លៃទីផ្សារប្រចាំថ្ងៃ
**curtailment** ការកាត់បន្ថយ
**curve** ខ្សែកោង, aggregate supply ~ ខ្សែកោងផ្គត់ផ្គង់សរុប
**custody (keeping)** ការរក្សាទុក
**custom of the port** (COP) ទំនៀមទំលាប់ផែ
**custom-built/made** កសាង/ធ្វើ ពិសេសសំរាប់អតិថិជនណាម្នាក់
**customer** អតិថិជន
**customs house** ទីចាត់ការគយ
**customs** គយ, ~ agent ភ្នាក់ងារគយ, ~ Department ទីចាត់ការគយនិងរដ្ឋាករ, ~ breach បទល្មើសច្បាប់គយ, ~ declaration ប្រតិវេទន៍គយ, ~ examination ការត្រួតពិនិត្យនៃភ្នាក់ងារគយ, ~ frontier ព្រំដែនគយ, ~ invoice វិក្កយបត្រគយ, ~ permit លិខិតអនុញ្ញាតពីទីចាត់ការគយ, ~ regulations បទបញ្ញត្តិគយ, ~ tariff តារាងពន្ធគយ, ~ territory តំបន់ត្រួតពិនិត្យគយ ( តំបន់ដែលគយ

អាចតាមចាប់ទំនិញបាន)
**customs broker** បុគ្គល/ក្រុមហ៊ុន ដែលនាំទំនិញឆ្លងកាត់គយ (បំរើអោយក្រុមហ៊ុនដឹកជញ្ជូន)
**customs duties (or dues)** ពន្ធគយ
**cycle** វដ្ត, ស៊ីក្លូ, ខួប, ជុំ, ~ of poverty វដ្តនៃភាពក្រីក្រ

## D, d

**daily** ប្រចាំថ្ងៃ, ~ sales return ចំណូលលក់ប្រចាំថ្ងៃ
**damage** ការខូចខាត, អន្តរាយ, ~ by seawater អន្តរាយដោយសារទឹកសមុទ្រ
**damages** ប្រាក់សំណងចំពោះការខូចខាត
**danger money** ប្រាក់ផ្តល់បន្ថែមសំរាប់ការងារមានគ្រោះថ្នាក់
**DARE** (Demand and Resource Evaluation) ការវាយតំលៃធនធាន និងតំរូវការ
**data** ទិន្នន័យ, enter v. ~ បញ្ចូលទិន្នន័យ
**data processing** ការចាត់ចែងទិន្នន័យ
**database** មូលដ្ឋានទិន្នន័យ
**data-collection stage** ដំណាក់កាលប្រមូលទិន្នន័យ
**date** កាលបរិច្ឆេទ, ថ្ងៃខែ, interest to ~ ការប្រាក់មកទល់បច្ចុប្បន្ន
**date a cheque forward** ចុះកាលបរិច្ឆេទអនាគតលើមូលប្បទានប័ត្រ
**date of maturity** ថ្ងៃដល់កំណត់សងប្រាក់, ឥណប្រតិទាន,
**date, by the due** ដល់ថ្ងៃកំណត់
**date, interest to** ប្រាក់ការមកទល់បច្ចុប្បន្ន
**day** ថ្ងៃ, settlement ~ ថ្ងៃទូទាត់បញ្ជី, ថ្ងៃជំរះបញ្ជី
**day labourer** ពលករស៊ីប្រាក់ថ្ងៃ, ទិនិកជន
**day-release** ១. ថ្ងៃរួចផុត (ពន្ធ)
២. ប្រព័ន្ធដែលអនុញ្ញាតឱ្យនិយោជិតសំរាកពីការងារដើម្បីរៀនសូត្រ
**DCB** (Domestic Competitive Bidding) ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក
**de facto** តាមការជាក់ស្តែង, តាមព្រឹត្តិន័យ, ~ management ការគ្រប់គ្រងតាមព្រឹត្តិន័យ
**de jure** តាមផ្លូវច្បាប់
**dead account** គណនីឈប់ប្រើ, គណនីងាប់
**dead loss** ការខាតបង់សរុប
**dead money** ប្រាក់ងាប់, ប្រាក់មិនយកទៅធ្វើការរកស៊ី
**dead season** រដូវស្ងប់សកម្មភាព (ឧ. រដូវលក់ដូរមិនសូវដាច់)
**deadline** កាលកំណត់, កាលបរិច្ឆេទដល់កំណត់
**deadlock** ភាពទាល់ច្រក break the ~ ទំលាយភាពទាល់ច្រក
**dead-weight** ១. ទំងន់និចល, ទំងន់ងាប់ (គ្មានជួយបំរើការ)
**deal** ការព្រមព្រៀងខាងជំនួញ, អាបណសញ្ញា, get a good ~ ទិញបានថោក, package ~ ការព្រមព្រៀងជាកញ្ចប់
**dealer** ពាណិជ្ជករ
**dealership** ទំនាក់ទំនងជំនួញផ្តាច់មុខ
**dealing** ការលក់ដូរហ៊ុននៅផ្សារហ៊ុន, ជំនួញ, commercial ~ សេដ្ឋពាណិជ្ជកម្ម, fair ~ ជំនួញស្របច្បាប់, insider ~ ការជួញដូរហ៊ុនដោយអ្នកផ្ទៃក្នុង (ដែលដឹងព័ត៌មានសំងាត់ពីក្រុមហ៊ុន)

**dear** ថ្លៃ (ផ្ទុយនឹងថោក)
**dear money** ប្រាក់ខ្ចីមានប្រាក់ការខ្ពស់
**dearth of investment** កង្វះវិនិយោគ
**death** មរណភាព, ការស្លាប់, ~ certificate សំបុត្រមរណភាព, ~ in service benefit ប្រាក់បំណាច់មរណភាព
**death rate** អត្រាមរណៈ
**debate** ការជជែកដេញដោល (ឧ. នៅសភា)
**debenture** សញ្ញាប័ណ្ណ (រយៈពេលវែងៗ), លិខិតបំណុល, register of ~ បញ្ជីឈ្មោះអ្នកកាន់សញ្ញាប័ណ្ណរបស់ក្រុមហ៊ុន, ~ holder អ្នកកាន់សញ្ញាប័ណ្ណ
**debit n. & adj. & v.** ១. ឥណពន្ធ ២. ឥណាយិក ៣. កត់ត្រាខាងឥណពន្ធ
**debit/credit memorandum or debit/credit memo** កំណត់ហេតុ ឥណពន្ធ/ឥណទាន ឬ ប្រកាស ឥណពន្ធ/ឥណទាន
**debt** បំណុល, ~ holder មេបំណុល, bad ~ បំណុល អាក្រក់/ពិបាកទារ, doubtful ~ បំណុលសង្ស័យ, irrecoverable ~ បំណុលទារមិនបាន, ~ crisis វិបត្តិបំណុល, ~ ratio សមាភាគបំណុល, secured/unsecured ~ បំណុល មាន/គ្មាន ដាក់ទ្រព្យធានា
**debt-collection letter** លិខិតទារប្រាក់
**debt-for-nature swaps** បំណុលដោះដូរនឹងធម្មជាតិ
**debtor** កូនបំណុល, ឥណវន្ត
**decadence n.** ភាពចុះអាប់ឱន, អត្ថង្គត
**decapitalise n.** ដកទុនចេញ
**deceased n.** អ្នកស្លាប់
**decennial population census** ជំរឿនប្រជាជនប្រចាំទសវត្សរ៍
**decent** សមរម្យ, ~ livelihood ជីវភាពសមរម្យ
**decentralisation n.** វិមជ្ឈការ
**decentralise v.** ធ្វើវិមជ្ឈការ, decentralised power អំណាចវិមជ្ឈការ
**deciding vote** សំលេងឧត្តមានុភាព (បោះឆ្នោត)
**decile n.** ទសភាគ (ស្ថិតិ)
**decimal n. & adj.** ១. លេខទសភាគ ២. ទសភាគ
**decision** សេចក្តីសំរេច, ~ maker អ្នកធ្វើសេចក្តីសំរេច, ~ making ការធ្វើសេចក្តីសំរេច, ~ tree គំនូសដើមឈើនៃប្រព័ន្ធសំរេច
**declaration** ១. ការ/សេចក្តី ប្រកាស ២. លិខិតប្រកាស, ប្រតិវេទន៍, customs ~ ប្រតិវេទន៍គយ, tax ~ លិខិតប្រកាសសារពើពន្ធ
**declared value** តំលៃបាន ប្រកាស/ប្រតិវេទន៍
**decline n.** ការធ្លាក់ចុះយឺតៗ
**declining balance method of depreciation** វិធីរំលស់ថយជាលំដាប់
**decoding** ការបកស្រាយលេខកូដ (ប្រែជាភាសាធម្មតាវិញ)
**deconcentration** វិសហមជ្ឈការ
**decrease** ការធ្លាក់ចុះ, ការថយចុះ, ~ in price ការធ្លាក់ថ្លៃ
**decree** ក្រឹត្យ
**de-dollarisation** បដិដុល្លារូបនីយកម្ម
**deduct v.** កាត់កង, ផាត់ចេញ, after deducting depreciation ក្រោយបានផាត់រំលស់
**deductible adj.** ដែលអាចកាត់កងចេញ, tax ~ ដែលអាចកាត់កងចេញពីចំណូលជាប់ពន្ធ
**deductive method** វិធីទាញហេតុផល, វិសេសានុមានវិធី

**deed ១.** កិច្ចសន្យាជាលាយលក្ខណ៍អក្សរ
**២.** អំពើ (ល្អ រឺ អាក្រក់), good ~ កុសលកិច្ច

**deed of assignment** លិខិតផ្ទេរកម្មសិទ្ធ (ពីកូនបំណុលទៅម្ចាស់បំណុល)

**deed of conveyance** លិខិតផ្ទេរកម្មសិទ្ធិអចលនទ្រព្យ

**default** ការខុសឆ្គង, ការខ្វះខាត, ការគ្មានលទ្ធភាពសង

**default of acceptance** ការមិនទទួលព្រម

**defendant n.** ចុងចោទ

**deferred payments** ការសងប្រាក់បណ្តាក់ (ច្រើនលើក)

**deferred share** ភាគហ៊ុនដែលទទួលភាគលាភក្រោយគេ

**deferred/unearned revenue** (ប្រាក់) ចំណូលទទួលមុន (គឺត្រូវយោងទៅបញ្ចូលក្នុងការិយបរិច្ឆេទក្រោយៗ)

**deficiency** ភាពមិនគ្រប់គ្រាន់, ~ in weight ភាពខ្វះទំងន់

**deficient reserves** ប្រាក់បំរុងខ្វះ

**deficient supply** ការផ្គត់ផ្គង់មានកង្វះខាត

**deficit** ឱនភាព, balance of payments/trade ~ ឱនភាពជញ្ជីញ ទូទាត់/ពាណិជ្ជកម្ម, budget ~ ឱនភាពថវិកា, meet v. a ~ បំពេញឱនភាព

**deficit financing** ហិរញ្ញប្បទានឱនភាព

**deflate the economy** ធ្វើបរិត្តផរណាសេដ្ឋកិច្ច (តាមរយៈការកាត់បន្ថយសាច់ប្រាក់ផ្គត់ផ្គង់ រឺ ចំណាយរដ្ឋាភិបាល)

**deflation** បរិត្តផរណា (សភាពការណ៍ទំនិញចុះថ្លៃជាទូទៅ )

**deflationary gap** គំលាតបរិត្តផរណា

**deflator** (GDP) សន្ទស្សន៍បរិត្តផរណា (ផសស)

**deforestation** ការកាប់ព្រៃឈើ, វិវនការ

**defrauder** អ្នកបន្លំ (ឧ. ពន្ធ)

**defray** ចេញចំណាយជួស

**degradation** ទុព្វលភាព, ការបញ្ចុះគុណភាព

**del credere** ប្រាក់ (បូកបន្ថែមសំរាប់) ធានាការទូទាត់, ~ clause ប្រការធានាទូទាត់, ~ commission កំរៃជើងសារធានាការទូទាត់

**delay ១.** ការយឺតយ៉ាវ, រយៈកាលកំណត់យឺតយ៉ាវ, ~ in delivery ការប្រគល់យឺតយ៉ាវ,
**២.** ការពន្យារពេល, grant a ~ ផ្តល់ការពន្យារពេល

**delegate power** ធ្វើប្រតិភូកម្មអំណាច, រំលែកអំណាច, ផ្ទេរអំណាច

**delegation ១.** ការផ្ទេរ (សិទ្ធិអំណាច)
**២.** គណៈប្រតិភូ

**deliberation** ការពិភាក្សាដេញដោល

**delinquent adj. ១.** ហួសកាលកំណត់
**២.** មិនបានបំពេញកាតព្វកិច្ចដោយចេតនា

**delinquent n.** អនីតិជនប្រព្រឹត្តល្មើស

**deliver v.** ប្រគល់

**delivered at duty paid** ប្រគល់នៅកន្លែងបានបង់ពន្ធហើយ

**delivered at frontier** ប្រគល់នៅព្រំដែន

**delivery** ការប្រគល់, ~ against payment ប្រគល់ទំនិញពេលមានការទូទាត់, ~ order ប័ណ្ណបញ្ជាអោយប្រគល់ទំនិញ, ~ by instalments ប្រគល់ទំនិញតាមដំណាក់កាល, ~ note លិខិតប្រគល់ទំនិញ (ឱ្យទៅអតិថិជន ជាមួយគ្នានឹងទំនិញ)

**demagogue n.** អ្នកបញ្ឆោរាស្ត្រ, ប្រជាភិថតិកៈ

**demand** តំរូវការ, សំណូមពរ, ~ bill/draft លិខិតប្តូរយកប្រាក់ (ពេលបង្ហាញធនាគារ),

~ curve ខ្សែកោងតំរូវការ, ~ deposit ប្រាក់បញ្ញើចរន្ត, ~ exceeds supply តំរូវការលើសការផ្គត់ផ្គង់, ~ loan កំចីគ្មានកាលកំណត់ (ពេលទារត្រូវសង)

**demand, to be in poor** មិនសូវមានតំរូវការ

**demarcation** (boundary) ការកំណត់ព្រំប្រទល់

**demilitarise v.** ដកទ័ពចេញ, ធ្វើវិយោធកម្ម

**de-mining** ការបោសសំអាតមីន

**demise** ១. ភតិសន្យា, កិច្ចសន្យាជួល ២. មរណភាព

**demobilise v.** រំសាយ (កងទ័ព)

**democratisation** ប្រជាធិបតេយ្យភាវូបនីយកម្ម, ប្រជានុវត្តន៍

**demographic rate** (birth, death ...) អត្រាប្រជាសាស្ត្រ (កំណើត, មរណៈ ...)

**demonetise** ការបញ្ចប់តំលៃប្រើប្រាស់នៃក្រដាសប្រាក់/កាក់

**denationalisation** និជាតូបនីយកម្ម, ការប្តូរទ្រព្យសម្បត្តិរដ្ឋទៅជាឯកជន

**denial, flat** ការប្រកែកដាច់អហង្ការ

**denominated in USD** (cheque) ចារឹកជាដុល្លារអាមេរិក (មូលប្បទានប័ត្រ)

**denomination** ឯកតាតំលៃនៃក្រដាសប្រាក់ (រឺ កាក់)

**denominator** (fraction) ភាគបែង

**density** ដង់ស៊ីតេ

**Department of Overseas Trade** នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស

**Department of Public Prosecution** អង្គការអយ្យការ

**department store** ភណ្ឌាគារ

**dependability** ភាពអាចពឹងពាក់បាន

**depletion** ការថយចុះច្រើនៗ, ការប្រើអស់, ឥន្ទកម្ម

**depletive asset** ទ្រព្យថយចុះតាមការប្រើប្រាស់

**deport v.** និរទេស

**deposit** ប្រាក់បញ្ញើ, និក្ខិតភ័ណ្ឌ, certificate of ~ ប្រកាសនីយប័ត្របញ្ញើ, demand ~ ប្រាក់បញ្ញើចរន្ត, guaranteed ~ និក្ខិតភ័ណ្ឌធានា, savings ~ ប្រាក់បញ្ញើសន្សំ, fixed/time ~ ប្រាក់បញ្ញើមានកាលកំណត់, ~ bank ធនាគារទទួលប្រាក់បញ្ញើ, ~ guaranty account គណនីប្រាក់តំកល់ធានា, ~ in transit ប្រាក់បញ្ញើកំពុងផ្ទេរ, ~ receipt បង្កាន់ដៃទទួលប្រាក់បញ្ញើ, ~ slip ប័ណ្ណសរសេរផ្ញើប្រាក់

**deposit** ប្រាក់កក់

**deposit** (minerals...) ស្រទាប់រ៉ែ

**deposit v.** ១. កក់ ២. តំកល់ប្រាក់, ផ្ញើប្រាក់ (នៅធនាគារ)

**depositor** អ្នកផ្ញើប្រាក់

**depreciate v.** ធ្លាក់ថ្លៃ

**depreciation** ១. ការធ្លាក់ថ្លៃ/តំលៃ ២. (ការ) រំលស់ ៣. ការសឹករេច

**depreciation allowance** (accounting) ទាយជ្ជទានអោយដល់រំលស់

**depress v.** សង្កត់ចុះ (ទីផ្សារ, អារម្មណ៍, ឈ្នាន់ហ្វ្រាំងរថយន្ត ...)

**depression, economic** វិសម្ពាធសេដ្ឋកិច្ច

**deputy prime minister** ឧបនាយករដ្ឋមន្ត្រី

**deputy chairman** អនុប្រធាន

**deputy manager** នាយករង, បណ្ណាធិការរង

**deregulate v.** ធ្វើបដិនិយ័តកម្ម

**dereliction of duty** ការបោះបង់ភារកិច្ច

**derivative instrument** (banking) ឧបករណ៍និស្សន្ទ
**descendant** បច្ឆាជន
**description** ១. ការពិពណ៌នា ២. ប្រភេទទំនិញ, ~ of goods ការរាយមុខទំនិញ
**desertification** វាលហោដ្ឋានីយកម្ម (ការធ្វើឱ្យទៅជាវាលរហោដ្ឋាន)
**design** ការរចនាតាក់តែង, ប្លង់, ~ effect ឥទ្ធិពលនៃប្លង់, ~ weight ទំងន់ប្លង់
**design v.** រចនាតាក់តែង
**designation letter** លិខិតឧទ្ទេសនាម (អ្នកតំណាង...)
**desk study** ការសិក្សានៅការិយាល័យ
**detailed adj.** លំអិត, ~ instructions បទបញ្ជាលំអិត
**deteriorated** អន់គុណភាព (ទំនិញ)
**deterioration** ការអន់ថយ (គុណភាព, ថ្លៃ...)
**determine v.** កំណត់
**detriment** ការខូចប្រយោជន៍
**detrimental** ដែល ធ្វើអោយខូចប្រយោជន៍/បង្កគ្រោះថ្នាក់
**devalue v.** បញ្ចុះតំលៃរូបិយវត្ថុ (ធៀបនឹងរូបិយវត្ថុឯទៀតៗ)
**development** ការអភិវឌ្ឍន៍, ការលូតលាស់, ~ strategies យុទ្ធសាស្ត្រអភិវឌ្ឍន៍, ~ aid ជំនួយអភិវឌ្ឍន៍, ~ project គំរោងអភិវឌ្ឍន៍, Development Triangle Zone តំបន់អភិវឌ្ឍន៍ត្រីកោណ
**deviation** ១. ការងាកចេញ ២. គំលាត
**devise n.** អច្ច័យទានជាអចលនទ្រព្យ (តាមមរតកសាសន៍)
**diagnosis n.** រោគវិនិច្ឆ័យ
**diagram** គំនូសបំព្រួញ
**differentiate v.** ញែក
**differentiation** ការញែកអោយឃើញភាពខុសគ្នា
**digit** លេខ, single ~ inflation អតិផរណាមានតួលេខតែមួយខ្ទង់
**digital** ដែលបង្ហាញជាលេខ, ឌីហ្សីតាល់
**digitalised economy** សេដ្ឋកិច្ចរេខូបនីយកម្ម
**dignitary** ឥស្សរជន
**dignity** ភាពថ្លៃថ្នូរ, ឥស្សរភាព
**dilemma n.** ស្ថានភាពត្រូវធ្វើជំរើសដ៏ពិបាក
**dimension** ទំហំ, ទិដ្ឋភាព (នៃសភាពការណ៍អ្វីមួយ)
**direct adj.** ផ្ទាល់, foreign ~ investment (FDI) វិនិយោគផ្ទាល់ពីបរទេស, ~ cost តំលៃផលិតផ្ទាល់, បរិយាទានផ្ទាល់, ~ exchange ការដោះដូរដោយផ្ទាល់, ~ export ការនាំចេញដោយផ្ទាល់, ~ tax ពន្ធផ្ទាល់
**direct v.** តំរង់ទិស
**direction** ១. ទិស, ទិសដៅ ២. សេចក្តីណែនាំ, provide ~ and guidance ផ្តល់ទិសដៅនិងការណែនាំ (ឱ្យធ្វើអ្វីមួយ)
**directive** ការចង្អុលទិស, បទណែនាំ, ~ on wages and prices បទណែនាំស្តីពីបៀវត្សរ៍និងថ្លៃ
**direct-lending schemes** កម្មវិធីឥណទានផ្ទាល់
**director** នាយក
**director-general** អគ្គនាយក, deputy ~ អគ្គនាយករង
**directory** ១. បញ្ជីរាយឈ្មោះ ២. ថតដាក់ទិន្នន័យ (កុំព្យូទ័រ)
**direct-transit trade** ពាណិជ្ជកម្មឆ្លងកាត់ផ្ទាល់
**disability** ពិការភាព
**disadvantage** ផលវិបាក, គុណវិបត្តិ

**disadvantaged** ចាញ់ប្រៀប, ~ farmers កសិករទន់ខ្សោយ
**disaggregation** ការបំបែកអង្គផ្សំ
**disagree v.** មិនព្រមព្រៀង, មិនឯកភាព, មិនយល់ស្រប
**disagreement n.** ការមិនព្រមព្រៀង, in the event of ~ ក្នុងករណីគ្មានការព្រមព្រៀង
**disbursement** ការបើកផ្តល់ ( ប្រាក់ ), ~ account គណនីរាយមុខការបើកផ្តល់ប្រាក់, ~ schedule កាលវិភាគបើកផ្តល់ប្រាក់
**discharge** ១. ដកបណ្តឹង, ~ a bankrupt អោយបុគ្គលបានរួចផុតពីភាពពីក្ស័យធន ពីព្រោះបានទូទាត់បំណុលហើយ **២.** ទូទាត់បំណុលទាំងស្រុង **៣.** បញ្ឈប់ ( បុគ្គលិក )
**disciplinary action** ការដាក់វិន័យ ( ការដាក់ទោសខាងរដ្ឋបាល )
**disciplinary council** ក្រុមប្រឹក្សាវិន័យ ( អ្នកសំរេចដាក់វិន័យលើបុគ្គលិក )
**disciplinary sanction** ទណ្ឌកម្មខាងវិន័យ, to impose ~ ដាក់វិន័យ
**disciplinary transfer** ការផ្លាស់ចេញដោយដាក់វិន័យ
**disclaimer** បទប្រកាសបដិសេធ ( ការទទួលខុសត្រូវ, សិទ្ធិ ... )
**discount** ១. អបហារ ( ការចុះថ្លៃ ), cash ~ ការលក់ចុះថ្លៃតាមការបង់ជាសាច់ប្រាក់, to sell goods at a ~ លក់ទំនិញចុះថ្លៃ **២.** អបហារិត ( ប្រាក់ចុះថ្លៃអោយ ) **៣.** ចុះថ្លៃ
**discount a bill v.** ធ្វើអបហាររូបិយាណត្តិ ( លក់រូបិយាណត្តិអោយធនាគារ )
**discount bank** ធនាគារទិញឧបករណ៍ទូទាត់លិខិតបំណុល
**discount rate** អត្រាអបហារ, អត្រាចុះថ្លៃ
**discounted cash flow** (DCF) **analysis** ការវិភាគលំហូរសាច់ប្រាក់គិតតាមរយ:ពេល
**discouraged worker** ពលករបាក់ទឹកចិត្ត
**discretion** ឆន្ទានុសិទ្ធិ ( សិទ្ធិសំរេចពេញលេញ ), at the ~ of the government ជាឆន្ទានុសិទ្ធិរបស់រដ្ឋាភិបាល
**discrimination** ការរើសអើង
**disequilibrium** វិសមតា, ភាពគ្មានលំនឹង
**dishonoured bill of exchange** រូបិយាណត្តិដែលត្រូវបានបដិសេធ
**dishonoured cheque** មូលប្បទានប័ត្របដិសេធ ( មិនទូទាត់ )
**disillusion** សេចក្តីស្រងាកចិត្តយ៉ាងខ្លាំង
**disincentive** គ្រឿងបង្អាក់ទឹកចិត្ត
**disinflation** ការបន្ថយអតិផរណា
**disinvestment** ការដកទុនឈប់វិនិយោគ
**dismiss v.** បញ្ឈប់ពីការងារ, ដេញចោល, dismissal n. ការបញ្ឈប់ពីការងារ
**dispatch n.** ការបញ្ជូន, ការបែងចែក
**dispatch v.** ផ្ញើ, បញ្ជូន ( ទំនិញ... )
**dispersion diagram** ដ្យាក្រាមបំបែករាយ
**disposable personal income** ចំណូលនៅទំនេររបស់បុគ្គល, ចំណូលបុគ្គលក្រោយកាត់ពន្ធ ( ឧ. ប្រាក់ខែបើកយកទៅផ្ទះបាន )
**dispose v.** ជំរះបញ្ចប់
**dispossess** ដកហូតរបស់ទ្រព្យ
**disproportionate** (amount of cash) វិសមាមាត្រ ( ចំនួនសាច់ប្រាក់ )
**dispute** វិវាទ, ជំលោះ, ~ settlement mechanism យន្តការដោះស្រាយវិវាទ

**dissemination** ការផ្សព្វផ្សាយ
**dissolution** ការរំលាយ
**distortion** ការប្រែប្រួលខុសភាពដើម
**distress** (sale) ដោយមានធុរៈបន្ទាន់, ដោះទ័ល (ការលក់)
**distribution** ការចែកចាយ
**distribution of sample** របាយគំរូតាង
**distribution, unequal wealth** របាយវិសមធន (ការចែកចាយទ្រព្យមិនស្មើគ្នា)
**disturbance** ការរំខាន, noise ~ ការរំខានដោយសំលេង
**diversification** ចំរុះកម្ម, ពិពិធកម្ម
**dividend** ភាគលាភ
**divisible adj.** ដែលចែកដាច់, អាចបែងចែក, ~ letter of credit សារឥណទានអាចបំបែកបាន
**division of labour** ការបែងចែកពលកម្ម
**docker** កម្មករកំពង់ផែ
**documentary collection**
១. ការប្រមូលប្រាក់ក្រោយពេលបានទទួលឯកសារ
២. ការប្រមូលឯកសារ
**documentary credit** ឥណទានឯកសារ
**documentation**
១. ឯកសារ (ទាំងអស់ទាក់ទិននឹងរឿងអ្វីមួយ)
២. ការកសាងសំណុំឯកសារ
**documents against acceptance (D/A)** ផ្តល់ឯកសារប្រគល់ទំនិញពេលបញ្ជាក់ទទួលព្រមជំពាក់
**documents against payment** (D/P) ផ្តល់ឯកសារប្រគល់ទំនិញនៅពេលសងប្រាក់
**dogma n.** សិទ្ធាន្ត (ជំនឿរបស់មនុស្សមួយក្រុមដែលគេរំពឹងថាអ្នកឯទៀតទទួលយកដោយគ្មានជជែកតវ៉ា)
**dollarisation** ដុល្លារូបនីយកម្ម
**domestic** ក្នុងស្រុក (រឺ ក្នុងប្រទេស), ~ assets (bank) ទ្រព្យសកម្មក្នុងស្រុក., ~ credit ឥណទានក្នុងស្រុក, ~ demand តំរូវការក្នុងស្រុក, ~ income (DI) ផលទុនក្នុងស្រុក, ~ financing ហិរញ្ញប្បទានក្នុងប្រទេស, ~ product (DP) ផលិតផលក្នុងស្រុក, ~ savings សញ្ច័យធនក្នុងស្រុក ~ supply ការផ្គត់ផ្គង់ក្នុងស្រុក, ~ price stability ស្ថិរភាពថ្លៃក្នុងស្រុក, ~ trade ពាណិជ្ជកម្មក្នុងស្រុក
**domicile n.** លំនៅ, ~ of origin លំនៅដើម (លំនៅពីកំណើត តាមធម្មតាគឺ លំនៅឪពុក)
**domiciled bill of exchange** រូបិយាណត្តិមានបញ្ជាក់អាស័យដ្ឋាន
**domiciled in Cambodia** មានលំនៅផ្លូវការនៅកម្ពុជា
**dominate v.** គ្របសង្កត់
**domino effect** ឥទ្ធិពលដូមីណូ
**donation** អំណោយ
**donee** បដិគ្គាហក
**donor** ទាយក, អ្នកផ្តល់ជំនួយ
**dormant adj.** គ្មានសកម្មភាព, ~ company ក្រុមហ៊ុនគ្មានសកម្មភាព (ក្នុងមួយការិយបរិច្ឆេទ)
**dose** ខ្នាតមាត្រា, កំរិត
**dossier** សំណុំរឿង
**double v.** កើនមួយជាពីរ
**double-deflation technique** បច្ចេកទេសបង្រួមស្ទួន
**double-entry bookkeeping** វិធីចុះបញ្ជីទ្វេភាគ
**doubtful debt** ឥណទេយ្យសង្ស័យ
**down payment** ប្រាក់កក់, ប្រាក់បង់ដំបូង
**downgrade v** បញ្ចុះតំលៃ

(ឧ. ក្នុងការព្យាករណ៍តំលៃសន្លឹកហ៊ុន)
**downsize v.** កាត់បន្ថយ
**downstream product** ផលិតផលខាងក្រោម/ចុងខ្សែ (កើតចេញពីផលិតផលដើម)
**downward tendency** និន្នាការថយចុះ
**dowry** កេរ្តិ៍ខាងស្រី
**draconian measures** វិធានការតឹងរឹងសំបើម
**draft** ១. សេចក្តីព្រាង ២. រូបិយាណត្តិ, bank ~ រូបិយាណត្តិធនាគារ (លិខិតបញ្ជាឱ្យធនាគារបើកប្រាក់)
**draft term** លក្ខខណ្ឌលិខិត
**draught animals** (GB), **draft animals** (US) សត្វអូសទាញ
**draw lots v.** ចាប់ឆ្នោត (ដើម្បីជ្រើសរើស)
**drawback n.** ចំណុចមិនល្អ
**drawback n.** ពន្ធគយបង្វិលសងវិញ (នៅពេលទំនិញត្រូវបាននាំចេញទៅវិញ)
**drawee** បហារិត, អ្នកអោយគេដកប្រាក់, អ្នកត្រូវបានស្នើអោយបង់ប្រាក់
**drawer** បហារ៉ក, អ្នកដកប្រាក់
**drawing account** គណនីប្រាក់បញ្ញើគ្មានកាលកំណត់
**drawing rights** សិទ្ធិដកប្រាក់ (សិទ្ធិស៊ុំខ្ចី)
**drop** ការធ្លាក់ចុះ
**dual price system** ប្រព័ន្ធថ្លៃទ្វិកៈ, ប្រព័ន្ធថ្លៃពីរ
**due** ១. ដែលជំពាក់ ២. ដែលដល់កំណត់
**due date** ឥណប្រតិទាន, ថ្ងៃដល់កំណត់សងប្រាក់
**due-card** សាលាកប័ត្រផ្តល់ទំនិញ
**dumping** ការចាក់គរ, ការលក់បង្ហូចថ្លៃ, ~ duty ពន្ធទប់ទល់នឹងការលក់បង្ហូចថ្លៃ
**duplication** ១. ការធ្វើឱ្យទ្វេគុណ ២. ការត្រួតគ្នា (ឥតប្រយោជន៍)
**durability** ភាពជាប់លាប់, ភាពឋិតថេរ
**dutiable** ដែលត្រូវបង់ពន្ធ, ~ goods ទំនិញត្រូវបង់ពន្ធ/ជាប់ពន្ធ
**duty** ពន្ធ (ពិសេសពន្ធគយ និងអាករពិសេស), ad valorem ~ ពន្ធយកតាមថ្លៃ, customs ~ ពន្ធគយ, excise ~ អាករពិសេស, ~ paid price ថ្លៃគិតទាំងពន្ធ
**duty** ភារកិច្ច, ~ bound ជាប់ភារកិច្ច
**duty-free** ដែលរួចពន្ធ, ~ goods ទំនិញរួចពន្ធ
**duty-paid goods** ទំនិញបង់ពន្ធហើយ
**DVD** ឌីវីឌី (ថាសវីដេអូ)
**dwindle v** ធ្វើរលស់បន្តិចម្តងៗ
**dynamic adj.** ឌីណាមិក, ដែលមាន ថាមភាព/សន្ទុះ
**dynamics n.** ឌីណាមិក, ថាមភាព
**dynamism** ឌីណាមីស, ថាមភាព, សន្ទុះកំលាំង

## E, e

**earmark v.** លៃទុក (សំរាប់គោលដៅអ្វីមួយ)
**earned fees** កំរៃរកបាន
**earnest** ប្រាក់កក់, កំណត់
**earning capacity** សមត្ថភាពរកប្រាក់
**earnings** ចំណូល, កំរៃ, retained ~ ប្រាក់ចំណេញរក្សាទុក (ដែលមិនបានបើកឱ្យម្ចាស់ហ៊ុនជាភាគលាភទេ)
**ease, prices are inclined to** ថ្លៃមាននិន្នាការថយចុះ
**easement** សេរីភាព, សិទ្ធិប្រើប្រាស់ដីអ្នកដទៃ
**easy money policy** គោលនយោបាយសាច់ប្រាក់ងាយស្រួល (ដែលសំរួលការផ្គត់ផ្គង់សាច់ប្រាក់ដើម្បីពង្រីកសេដ្ឋកិច្ច)

**easy terms of payment** លក្ខខណ្ឌទូទាត់ងាយស្រួល
**ecological equilibrium** លំនឹងអេកូឡូស៊ី
**ecological tourism** អេកូទេសចរណ៍
**ecological zone** តំបន់អេកូឡូស៊ី
**ecology** អេកូឡូស៊ី
**eco-national product (ENP)** ផលិតផលបរិស្ថានជាតិ
**econometrics** សេដ្ឋកិច្ចមាត្រសាស្ត្រ, វិជ្ជាវាស់វែងសេដ្ឋកិច្ច
**economic** នៃសេដ្ឋកិច្ច, ~ austerity តបកម្មសេដ្ឋកិច្ច, ការត្បិតត្បៀតខាងសេដ្ឋកិច្ច, ~ blockade/embargo ការហ៊ុំព័ទ្ធសេដ្ឋកិច្ច, ~ conditions លក្ខខណ្ឌសេដ្ឋកិច្ច, សភាពការណ៍សេដ្ឋកិច្ច, ~ conversion បំលាស់សេដ្ឋកិច្ច (ពិសេសពីរចនាសម្ព័ន្ធយោធាមករចនាសម្ព័ន្ធសេដ្ឋកិច្ចមិនមែនយោធា), ~ cooperation សហប្រតិបត្តិការសេដ្ឋកិច្ច, ~ corridor របៀងសេដ្ឋកិច្ច, ~ corridor ច្រកទ្វារ សេដ្ឋកិច្ច, ~ crisis វិបត្តិសេដ្ឋកិច្ច, ~ cycle វដ្ត សេដ្ឋកិច្ច, ~ downturn/recession ការធ្លាក់ចុះ សេដ្ឋកិច្ច, ~ efficiency ប្រសិទ្ធភាពសេដ្ឋកិច្ច, ~ entity អង្គភាពសេដ្ឋកិច្ច, ~ forecast ការព្យាករណ៍សេដ្ឋកិច្ច, ~ impact ផលប៉ះពាល់ខាងសេដ្ឋកិច្ច, ~ indicator អាំងឌីការទ័រសេដ្ឋកិច្ច, ~ pattern លំនាំសេដ្ឋកិច្ច, ~ integration សមាហរណកម្មសេដ្ឋកិច្ច, ~ model គំរូសេដ្ឋកិច្ច, ~ philosophy ទស្សនវិជ្ជាសេដ្ឋកិច្ច, ~ policy គោលនយោបាយសេដ្ឋកិច្ច, ~ projection ការគន់គូរខាងសេដ្ឋកិច្ច, ~ sanction ទណ្ឌកម្មសេដ្ឋកិច្ច, ~ stabilisation programme កម្មវិធីស្ថិរភាវូបនីយកម្មសេដ្ឋកិច្ច
**economic cost-benefit analysis** (ECBA) ការវិភាគចំណាយនិងផលចំណេញខាងសេដ្ឋកិច្ច
**economical** ដែលសន្សំសំចៃ
**economics** វិទ្យាសាស្ត្រសេដ្ឋកិច្ច
**economies of scale** សេដ្ឋកិច្ចមាត្រដ្ឋាន
**economist** សេដ្ឋវិទូ
**economise** សន្សំសំចៃ
**economy** សេដ្ឋកិច្ច, សំចៃ, balance of national ~ តុល្យភាពសេដ្ឋកិច្ចជាតិ, black ~ សេដ្ឋកិច្ចងងឹត, centrally planned ~ សេដ្ឋកិច្ចផែនការប្រមូលផ្តុំ, decentralised ~ សេដ្ឋកិច្ចវិមជ្ឈការ, capitalist ~ សេដ្ឋកិច្ចមូលធន, free market ~ សេដ្ឋកិច្ចទីផ្សារសេរី, planned ~ សេដ្ឋកិច្ចផែនការ, political ~ សេដ្ឋកិច្ចនយោបាយ, ~ car រថយន្តស៊ីសាំងតិច, ~ size ខ្នាតធំ (លក់ថោកបើធៀបនឹងបរិមាណវា)
**education for all** អប់រំសំរាប់ទាំងអស់គ្នា
**Education Sector Support Programme** (ESSP) ផែនការយុទ្ធសាស្ត្រសំរាប់ទ្រទ្រង់វិស័យអប់រំ
**education service** សេវាអប់រំ
**effective** សក្តិសិទ្ធិ
**effective date** ថ្ងៃប្រសិទ្ធភាព
**effective demand** តំរូវការជាក់ស្តែង
**effective rate of protection** (ERP) អត្រាគាំពារសក្តិសិទ្ធិ
**effectiveness** ភាពសក្តិសិទ្ធិ
**efficiency** ប្រសិទ្ធភាព
**efficient** ដែលមានសមត្ថភាព, ដែលមានផលល្អ,

~ worker កម្មករដែលមានសមត្ថភាព
**elaborate** យ៉ាងល្អិតល្អន់, បរិយាយយ៉ាងល្អិតល្អន់
**elasticity** ភាពយឺត, ដែលអាចផ្លាស់ប្តូរបាន, ~ of supply and demand ភាពយឺតនៃការផ្គត់ផ្គង់ និងតំរូវការ
**elderly** ជនចាស់ជរា
**electoral official** មន្ត្រីបោះឆ្នោត
**electrification** អគ្គីសនីភាវូបនីយកម្ម, rural ~ fund មូលនិធិអគ្គីសនីភាវូបនីយកម្មជនបទ
**electronic adj.** អេឡិចត្រូនិក
**element** សមាសធាតុ
**eligibility for bank loans** ភាពអាចទទួលបានឥណទានពីធនាគារ
**eligible** ដែលមានសិទ្ធិ, ដែលអាចទទួលយកបាន
**elite** អ្នកឋានៈខ្ពស់
**embargo** ការហ៊ុំព័ទ្ធ, និន្នីវារណ៏ (ឧ. ការហាមឃាត់មិនអោយនាំទំនិញចេញ-ចូល), lift an ~ លើកការហ៊ុំព័ទ្ធចេញ, place an ~ ដាក់ការហ៊ុំព័ទ្ធ
**embezzlement** ការកេងប្រវ័ញ្ច
**emergency** ភាព បន្ទាន់/អាសន្ន, in case of ~ ក្នុងករណីបន្ទាន់, ~ aid ជំនួយសង្គ្រោះបន្ទាន់, ~ condition លក្ខខណ្ឌភាពអាសន្ន, ~ fund មូលនិធិសង្គ្រោះបន្ទាន់, ~ loan កំចីសង្គ្រោះបន្ទាន់, ~ relief ជំនួយសង្គ្រោះបន្ទាន់, ~ tax ពន្ធវិសាមញ្ញ
**emerging economies** សេដ្ឋកិច្ចកំពុងងើបឡើង
**emerging markets** ទីផ្សារកំពុងផុសឡើង
**emission** បន្សាយ (ឧ. ឧស្ម័នពុល)
**emolument** បរិលាភ, ប្រាក់បំណាច់មុខតំណែង
**emotional buying motive** បំណងទិញដោយរំភើបចិត្ត
**emphasise v.** សង្កត់ធ្ងន់, គូសបញ្ជាក់
**employee** និយោជិត, ~ oriented ដែលយកចិត្តទុកដាក់ទៅលើនិយោជិត
**employer** និយោជក
**employment** ១. ការងារ (ទៀងទាត់មានប្រាក់កំរៃ) ២. ស្ថានភាពមានការងារធ្វើ, ~ rate អត្រាអ្នកមានការងារធ្វើ ៣.ការជួល (ឱ្យបំរើការងារទៀងទាត់), ~ bureau ការិយាល័យរកការងារអោយធ្វើ, ~ shock ការប៉ះទង្គិចខាងការងារ
**empower v.** ផ្តល់អំណាច/ផ្តល់សិទ្ធិអំណាចឱ្យ
**emulation** ការប្រជែងតាមគំរូល្អ
**enact a law** អនុម័តច្បាប់
**encode v.** សរសេរជាលេខកូដ (បកប្រែភាសាសាមញ្ញទៅជាលេខកូដ)
**encouragement** ការលើកទឹកចិត្ត, ការជំរុញ
**end product** ផលិតផលសំរេច
**end result** ផលសំរេច
**endangered species** ប្រភេទស្ទើរផុតពូជ
**ending inventory** សារពើភ័ណ្ឌចុងគ្រា
**endorse v.** ១. គាំទ្រ ២. ចារខ្នង ( ឯកសារ)
**endorse v.** (an expense) ចុះទិដ្ឋាការ (បញ្ជាក់យល់ព្រមលើចំណាយ) (French: viser)
**endorsee** អ្នកមានសិទ្ធិប្រើប្រាស់លិខិតស្នាមតាមចំណារខ្នង
**endorsement** បិដ្ឋិលេខ, ចំណារពីខ្នង, រូបិយបដិភោគ, ~ for collection ចំណារខ្នងឯកសារដើម្បីប្រមូលប្រាក់
**endorser** អ្នកធ្វើបិដ្ឋិលេខ, អ្នកចារខ្នងឯកសារ, រូបិយបដិភោគី
**endowment** ប្រាក់ផ្តល់ឱ្យ, ទាយជ្ជទាន (ប្រាក់បែងចែកជាទៀងទាត់សំរាប់គោលដៅអ្វីមួយ)
**energy conservation** ការសន្សំសំចៃថាមពល
**energy efficiency** ប្រសិទ្ធភាពថាមពល
**enforce payment v.** បង្ខំអោយទូទាត់

**enforce v.** ដាក់អោយប្រតិបត្តិ, ដាក់បង្ខំឱ្យអនុវត្ត, ពង្រឹងការអនុវត្តន៍ (ច្បាប់), enforcement (n)

**enforceable** មានតំលៃប្រតិបត្តិ, អាចដាក់បង្ខំឱ្យអនុវត្តបាន

**engage v.** ពាក់ព័ន្ធចូល

**engagement** ការចូលប្រឡូក

**engine of economic growth** ក្បាលម៉ាស៊ីនកំណើនសេដ្ឋកិច្ច

**enhancement** ការលើកស្ទួយ

**enough** គ្រប់គ្រាន់

**enquiry** សេចក្តីស្នើ, make enquiries សាកសួរព័ត៌មាន

**enrollment rate** (school) អត្រាចុះឈ្មោះចូលរៀន

**enterprise** សហគ្រាស, free ~ សហគ្រាសសេរី (មិននៅក្រោមការគ្រប់គ្រងរបស់រដ្ឋ), small-scale ~ សហគ្រាសខ្នាតតូច

**entertainment** ការកំសាន្ត, ~ centre មណ្ឌលកំសាន្ត

**entitle v.** ផ្តល់សិទ្ធិ

**entity** អង្គភាព, legal ~ នីតិបុគ្គល

**entrepreneur** សហគ្រិន

**entrepreneurship** សហគ្រិនភាព, លក្ខណៈច្នៃប្រឌិតរកស៊ី

**entry** ១. លេខនា (គណនេយ្យ) **២.** ការចូល, ~ point ចំណុចចូល, ច្រកចូល

**enumerator** អ្នកចុះធ្វើអង្កេត, អ្នកសួរអង្កេត (គួរប្រើ interviewer រឺ surveyor វិញ)

**environment** បរិស្ថាន, ~ scan ការមើលចំណុចសំខាន់ក្នុងបរិស្ថាន

**environmental adj.** នៃបរិស្ថាន, ~ impact ការប៉ះពាល់បរិស្ថាន, ~ protection កិច្ចការពារបរិស្ថាន, ~ security សន្តិសុខបរិស្ថាន

**envoy** ប្រេសិត/បេសកជនពិសេស

**equality** សមភាព, income ~ សមភាពនៃប្រាក់ចំណូល, ~ benefit ផលប្រយោជន៍ស្មើគ្នា,

**equalisation** ការធ្វើអោយមានសមភាព

**equation** សមីការ

**equilibrium** លំនឹង, តុល្យភាព, សមតា, ~ price ថ្លៃលំនឹង

**equitable** ដោយសមធម៌, ស្មើភាព

**equities** ហ៊ុនធម្មតា

**equity n.** ទ្រព្យម្ចាស់ (ទ្រព្យសកម្ម ដកបំណូលចរន្ត និងហ៊ុនអនុគ្រោះ)

**equity** សមធម៌, with ~ ដែលមានសមធម៌, ~ fund មូលនិធិសមធម៌

**equity capital** ទុនម្ចាស់ហ៊ុនធម្មតា

**equity of redemption** សិទ្ធិលស់ (របស់កូនបំណុលអ៊ីប៉ូតែក)

**equity participation** ភាគកម្ម (ចូលហ៊ុន)

**equivalent** សមមូល, ស្មើគ្នា, ប៉ុនគ្នា, ~ to សមមូលនឹង, ~ value តំលៃសមមូល

**error** ល្បៀង, កំហុស, មិច្ឆាលេខ, ~ in measurement ល្បៀងក្នុងការវាស់វែង

**escalation** ការរីករាលដាល (ទំនាស់), កំណើនការតានតឹង

**escrow, in** ដែលរក្សាទុកក្នុងដៃតតីយជន

**essential** ជាសារវន្ត, ~ goods ទំនិញជាសារវន្ត

**established business** អាជីវកម្មដែលចាក់ឫសហើយ, អាជីវកម្មមានស្រាប់

**establishment** ១. គ្រឹះស្ថាន **២.** ការបង្កើត

**estate** ១. ដីកម្មសិទ្ធិ (ធំៗ)

២. ទ្រព្យសម្បត្តិរបស់បុគ្គលដែលស្លាប់
**estate agent** ភ្នាក់ងាររកស៊ីជួល រឺលក់អចលនទ្រព្យ
**estate, real** អចលនទ្រព្យ
**estimate v.** ប៉ាន់ស្មាន, វាយតម្លៃ
**estimated profit** ប្រាក់ចំណេញប៉ាន់ស្មាន
**estimation bias** លំអៀងនៃការប៉ាន់ស្មាន
**ethics** សីលធម៌, សីលធម៌វិជ្ជាជីវៈ (ក្រមសីលធម៌)
**ethnography** ជាតិពន្ធុវិទ្យា
**Eurodollar** ដុល្លារអឺរ៉ុប (ដុល្លារផ្ញើក្នុងធនាគារនៅក្រៅសហរដ្ឋអាមេរិកសំរាប់បំរើពាណិជ្ជកម្មក្នុងអឺរ៉ុប)
**evaluation** ការវាយតម្លៃ, credit project ~ ការវាយតំលៃគំរោងឥណទាន
**evasion** (tax) ការគេច (ពន្ធ)
**even number** លេខ គត់គូរ/គូរ
**event** ព្រឹត្តិការណ៍, ~ of default ករណីគ្មានលទ្ធភាពសង
**eventuality** យថាហេតុ
**evidence** ភស្តុតាង
**evolution** ការវិវត្តន៍
**evolving process** ដំណើការវិវត្តិន៍
**exacerbate** ធ្វើអោយរឹតតែធ្ងន់ធ្ងរ
**examine v.** ពិនិត្យ
**ex-ante price** ថ្លៃផែនការ (មុនពេលអនុវត្តជាក់ស្តែង)
**excavation** កំណាយ (បុរាណវិទ្យា)
**exceed v.** លើស
**excess n. & adj.** ១. ល្អើស, សំណល់ (ថវិកា) ២. លើស, ~ capacity សមត្ថភាពលើស (តំរូវការផលិត), ~ reserve ប្រាក់បំរុងលើស
**exchange** ១. ការដោះដូរ, ការប្តូរ, ការផ្លាស់ប្តូរ (ពាណិជ្ជកម្ម), ~ control ការត្រួតពិនិត្យការប្តូរប្រាក់, ~ dumping ការលក់បំផ្លាញអត្រាប្តូរប្រាក់, ~ gain/loss ចំណេញ/កំហាតលើការប្តូរប្រាក់, ~ office ការិយាល័យប្តូរប្រាក់ ២. ផ្សារ, កន្លែងលក់ទិញ, stock ~ ផ្សារហ៊ុន
**exchange rate or rate of exchange** អត្រាប្តូរប្រាក់, monthly average ~ អត្រាប្តូរប្រាក់មធ្យមប្រចាំខែ, closing ~ អត្រាប្តូរប្រាក់នៅពេលបិទ, fixed ~ អត្រាប្តូរប្រាក់មិនប្រែប្រួល/ថេរ, parallel market ~ អត្រាប្តូរប្រាក់ទីផ្សារ, forward ~ អត្រាប្តូរប្រាក់មានកាលកំណត់, official ~ អត្រាប្តូរប្រាក់ផ្លូវការ, spot ~ អត្រាប្តូរប្រាក់ដល់ដៃ
**exchange, letter of (or bill of )** រូបិយាណត្តិ
**excise tax** អាករពិសេស (ច្បាប់កម្ពុជា: អាករពិសេសលើទំនិញនិងសេវាមួយចំនួន)
**excise tax revenues** រដ្ឋទេយ្យចំណូល
**exclusive agent** តំណាងផ្តាច់មុខ
**exclusive right** សិទ្ធិផ្តាច់មុខ
**executive adj.** ដែល ប្រតិបត្តិ/អនុវត្ត, ~ body/entity/unit សេនាធិការ, ~ director នាយកប្រតិបត្តិ, ~ committee គណៈកម្មាធិការប្រតិបត្តិ, ~ structure រចនាសម្ព័ន្ធប្រតិបត្តិ, ~ summary សេចក្តីសង្ខេប (សង្ខេបឯកសារដែលវែងសំរាប់ថ្នាក់ដឹកនាំអាន)
**executive n.** ១. ថ្នាក់ដឹកនាំ, chief ~ នាយកក្រុមហ៊ុន ២. អំណាចនីតិប្រតិបត្តិ
**executive power** អំណាចនីតិប្រតិបត្តិ (រដ្ឋាភិបាល), អំណាចប្រតិបត្តិ (ស្ថាប័នផ្សេងទៀតដូចជាក្រុមប្រឹក្សាឃុំ)
**exemption, tax** ការលើកលែងពន្ធ, មុធាភាពនៃពន្ធអាករ

**exert pressure v.** ដាក់សំពាធ, ធ្វើការកៀបសង្កត់
**existence** អត្ថិភាព
**existing** ដែលមានស្រាប់, ~ structure រចនាសម្ព័ន្ធដែលមានស្រាប់, ~ level of development កំរិត មានស្រាប់/អត្ថិភាព នៃការអភិវឌ្ឍន៍
**exit point** ចំណុចចេញ, ច្រកចេញ
**ex-officio** តាមអំណាចមុខងារ (ឧ. តាម អំណាច/ដោយសារ មុខងារជាហិរញ្ញិក គាត់ត្រូវ ក្លាយជាសមាជិកនៃគណៈកម្មការហិរញ្ញវត្ថុ)
**exogenous** ខាងក្រៅ, negative ~ factors កត្តាអវិជ្ជមានខាងក្រៅ
**expansion** ការពង្រីក, វិបុលកម្ម, វិបុលការ,វិត្ថារកម្ម
**expatriate (or expat)** អ្នកចំណោលស្រុក, អាណិកជន
**expectation, rational** ការរំពឹងសមហេតុផល
**expected profit** ប្រាក់ចំណេញរំពឹងទុក
**expend v.** ចំណាយ, ចាយ
**expenditure n.** ចំណាយ, capital ~ ចំណាយជាមូលធន, current ~ ចំណាយចរន្ត (ចំណាយជាប្រចាំក្នុងឯកសារខ្លះ), ~ curve ខ្សែកោងចំណាយ
**expenses, administrative** ចំណាយរដ្ឋបាល
**expenses, sundry** ចំណាយផ្សេងៗ
**experience n.** បទពិសោធន៏
**experiment n.** ពិសោធន៏
**experimental learning cycle** វដ្តរៀនសូត្រដោយដកពិសោធន៏
**experimentation** ពិសោធនកម្ម, ការពិសោធន៏
**expertise** កោសល្យវិច័យ
**expiration of a contract** ការផុតកំណត់ នៃកិច្ចសន្យា
**explicit** ជាក់លាក់, ~ instruction បទបញ្ជា ជាក់លាក់
**exploitation** អាជីវកម្ម, ~ of natural resources ការធ្វើអាជីវកម្មធនធានធម្មជាតិ
**exploration** ការរុករក, oil ~ ការរុករក ប្រេងកាត
**exponential growth** កំណើនអិចស្ប៉ូណង់ស្យែល
**export v. & n.** ១.នាំចេញ ២.ការនាំចេញ, នីហរ័ណ, ~ article/item មុខទំនិញនាំចេញ, ~ duty ពន្ធនាំចេញ, ~ subsidies ឧបត្ថម្ភធន សំរាប់ការនាំចេញ, ~ licence អាជ្ញាប័ណ្ណនាំចេញ, ~ monopoly ការនាំចេញផ្តាច់មុខ, ~ tariff តារាងពន្ធនាំចេញ, ~ of workers ការនាំចេញ ពលកម្ម
**exportation** ការនាំចេញ, នីហរ័ណកម្ម
**exporter** អ្នកនាំចេញ, នីហារិន
**exporting firm** ក្រុមហ៊ុននាំចេញ
**exports** ទំនិញនាំចេញ
**ex-post project evaluation** ការវាយ តំលៃក្រោយពេលគំរោងចប់
**exposure** (banking) ហានិភ័យ, large ~ ហានិភ័យធំ
**extended fund facility** (EFF) ឧបករណ៏សំរួលសំរាប់មូលនិធិបន្ថែម
**extension** ការបន្តពេល (អោយ)
**extensive adj.** យថាផល, ~ agriculture កសិកម្មយថាផល
**external accounts** គណនីផ្ទៃក្រៅ
**external aid** ជំនួយពីខាងក្រៅ (ប្រទេស)
**external balance** ជញ្ជីងទូទាត់អន្តរជាតិ
**externalities** ១. ផលប៉ះពាល់មកពីក្រៅ

២. កត្តាខាងក្រៅ
**extract** សំរង់
**extraction** ការយកចេញមក, ការយករ៉ែ, និស្សារណកម្ម
**extractive industry** ឧស្សាហកម្មយករ៉ែ
**extradition** បត្យាប័ន (ការប្រគល់ជនជាប់ចោទទៅឱ្យប្រទេសផ្សេង)
**extraordinary session** សម័យប្រជុំវិសាមញ្ញ
**extrapolation** ការគន់គូរ
**extra-structural adjustment facility** (ESAF) ឧបករណ៍សំរួលសំរាប់កែតំរូវបន្ថែម
**extrinsic reward** រង្វាន់មកពីក្រៅ
**ex-warehouse price** ថ្លៃ(លក់)ចេញពីឃ្លាំង
**ex-works/ex-factory price** ថ្លៃ (លក់) ចេញពីរោងចក្រ

## F, f

**fabric of peace, strengthen the** ពង្រឹងកោសិកាសន្តិភាពអោយផ្សារភ្ជាប់គ្នាល្អ
**face value** តំលៃចុះលើប័ណ្ណ
**facilitate v.** ជួយសំរួល, បង្កលក្ខណៈងាយស្រួល
**facilities** គ្រឿងសំរួលការ, កន្លែងសំរួលការ
**facility** ការងាយស្រួល, ឧបករណ៍សំរួល, extended fund ~ ឧបករណ៍សំរួលសំរាប់មូលនិធិបន្ថែម
**fact** អង្គហេតុ
**fact-finding mission** បេសកកម្មស្វែងរកការពិត
**factor** កត្តា, ~ cost កត្តាតំលៃ (ពាក្យប្រើក្នុងគណនីជាតិសំដៅដល់ផលិតផលគិតតាមថ្លៃទីផ្សារ បូកឧបត្ថម្ភធន ដកពន្ធផ្ទាល់ចេញ), primary ~ cost កត្តាតំលៃបឋម, primary ~ income កត្តាចំនូលបឋម, primary ~ of production កត្តាផលិតកម្មបឋម
**factual** ជាក់ស្តែង, ~ situation ស្ថានភាពជាក់ស្តែង
**fad** អ្វីដែលគេនិយមមួយគ្រាៗ
**fail v.** ខកខាន, ក្ស័យធន, គ្មានជោគជ័យ
**fair** មានសមធម៌, ដោយយុត្តិធម៌, ត្រឹមត្រូវ, principle of ~ competition គោលការណ៍ប្រកួតប្រជែងត្រឹមត្រូវ, ~ price ថ្លៃសមរម្យ
**fairness** ភាពសមរម្យ
**fait(s) accompli(s)** ព្រឹត្តិន័យ (អ្វីដែលបានកើតហើយ ប្តូរលែងបាន)
**fall in prices** ការធ្លាក់ថ្លៃ
**fall sharply v.** ធ្លាក់ចុះយ៉ាងគំហុក (ឧ. ថ្លៃផលិតផល)
**fallacious** ដែលបំភាន់
**false adj.** ក្លែងក្លាយ, មិនពិត
**falsify v.** ក្លែងក្លាយ
**family allowance(s)** វិភាជន៍គ្រួសារ, ប្រាក់ឧបត្ថម្ភគ្រួសារ
**family business** អាជីវកម្មជាលក្ខណៈគ្រួសារ
**family food production** ផលិតកម្មស្បៀងជាលក្ខណៈគ្រួសារ
**family scale** (fishing) (ការនេសាទ) ជាលក្ខណៈគ្រួសារ
**family well-being** សុខុមាលភាពគ្រួសារ
**famine** ទុរ្ភិក្ស, ការអត់ឃ្លាន
**fancy** ក្បាច់ក្បូរ, ហ៊ឺហា
**fare** ថ្លៃឈ្នួលយានជំនិះ, concessionary ~ ថ្លៃឈ្នួលអនុគ្រោះ, full ~ ថ្លៃឈ្នួលពេញ, half ~ ថ្លៃឈ្នួលពាក់កណ្តាល, single/one way ~ ថ្លៃធ្វើដំណើរតែទៅ ឬ តែមក, return ~ (roundtrip ~) ថ្លៃធ្វើដំណើរទៅមក, high/low season ~ ថ្លៃឈ្នួល

ខ្ពស់ រឺទាបតាមរដូវ
**farm** កសិដ្ឋាន, ~ equipment បរិក្ខារកសិដ្ឋាន
**farming** របរកសិកម្ម, extensive ~ ការធ្វើកសិកម្មតាមបែបវិបុលវប្បកម្ម, កសិកម្មយថាផល, intensive ~ កសិកម្មអតិផល, ការធ្វើកសិកម្មតាមបែបប្រពលវប្បកម្ម
**far-sighted** ដែលមើលឃើញវែងឆ្ងាយ
**FAS** (free alongside ship) ថ្លៃទំនិញដឹកដល់គែមនាវា
**fast selling items** ទំនិញលក់ដាច់លឿន
**fast-food restaurant** ភោជនីយដ្ឋានអាហាររហ័ស
**fauna** រុច្ចៈសត្វ (ពពួកសត្វ)
**favor** ការអនុគ្រោះ
**favourable** អំណោយផល, ~ conditions លក្ខខណ្ឌអំណោយផល, ~ trade balance ជញ្ជីងពាណិជ្ជកម្មល្អ
**favouritism** អនុគ្រោះនិយម
**fax** ទូរសារ
**feasibility study** ការសិក្សាពីភាពអាចធ្វើបាន រឺ ការសិក្សាពីសមិទ្ធិលទ្ធភាព
**feature** លក្ខណៈសំគាល់, វត្ថុនិទ្ទស្សន៍
**fee** កំរៃ, សោហ៊ុយ, licence ~ កំរៃអាជ្ញាប័ណ្ណ
**feedback** ព័តិមានត្រឡប់ (ព័តិមានផ្តល់មកអោយវិញ)
**feet, foot** ហ្វីត, ហ្វូត, (រង្វាស់ប្រវែង)
**felony** បទឧក្រិដ្ឋ
**fertility** ភាពមានកូន, ~ rate អត្រាមានកូន
**feudalism** សក្តិភូមិនិយម
**fiduciary** ជនកាន់តំណែងជាទីទំនុកចិត្ត, abuse of ~ ការរំលោភសេចក្តីទុកចិត្ត

**fiduciary currency** រូបិយវត្ថុ រឺ ប្រាក់ក្រដាស
**fiduciary loan** កំចីគ្មានវត្ថុធានា
**field expenditure** ចំនាយចុះធ្វើការដល់កន្លែង
**FIFO** (first in, first out) ហ្វីហ្វូ (ចូលមុនចេញមុន)
**filing** ១. ការតំកល់ទុក ២. ការដាក់ជូនពិនិត្យ
**filing system** ប្រព័ន្ធរៀបចំឯកសារ
**fill in a form** បំពេញទំរង់បែបបទ
**final** ចុងក្រោយ, ~ goods ផលិតផលសំរេច, ~ output ធាតុចេញ/ផលិតផល ចុងក្រោយ, ~ consumption ការប្រើប្រាស់ចុងក្រោយ, ~ provisions អវសានប្បញ្ញត្តិ (ច្បាប់), ~ settlement ការទូទាត់ផ្តាច់
**finance officer** មន្ត្រីហិរញ្ញវត្ថុ
**finance v.** ផ្តល់ហិរញ្ញប្បទាន, ផ្តល់ទុន
**financial** នៃហិរញ្ញវត្ថុ, ~ accounting គណនេយ្យហិរញ្ញវត្ថុ, ~ assistance ជំនួយហិរញ្ញវត្ថុ, ~ autonomy ស្វ័យភាពហិរញ្ញវត្ថុ, ~ appropriation ប្រាក់វិភាជន៏, ~ charge/cost បន្ទុកចំណាយហិរញ្ញវត្ថុ, ~ crisis វិបត្តិហិរញ្ញវត្ថុ, ~ forecast ការព្យាករណ៏ហិរញ្ញវត្ថុ, ~ institution ស្ថាប័នហិរញ្ញវត្ថុ, ~ panic អហេតុភ័យហិរញ្ញវត្ថុ, ~ liquidation ការជំរះហិរញ្ញវត្ថុ, ~ pressure សំពាធ ហិរញ្ញវត្ថុ, ~ rate of return អត្រាទាញចំណូលហិរញ្ញវត្ថុ, ~ reform កំណែទំរង់ហិរញ្ញវត្ថុ, ~ services សេវាហិរញ្ញវត្ថុ, ~ shocks ការប៉ះទង្គិចខាងហិរញ្ញវត្ថុ, ~ self-sufficiency ភាពម្ចាស់ការខាងហិរញ្ញវត្ថុ, ~ standing ស្ថានភាពហិរញ្ញវត្ថុ, ជំហរហិរញ្ញវត្ថុ, ~ year ឆ្នាំហិរញ្ញវត្ថុ, ការិយបរិច្ឆេទ
**financial cost-benefit analysis** (FCBA)

ការវិភាគចំណាយ និងផលចំណេញហិរញ្ញវត្ថុ

**financial manager** (French: ordonnateur) អាណាប័ក, principal ~ អាណាប័កដើមខ្សែ, delegated ~ អាណាប័កផ្ទេរសិទ្ធិ

**financing** ហិរញ្ញប្បទាន, ~ arm សាខាផ្តល់ហិរញ្ញប្បទាន, ~ modalities បែបបទផ្តល់ហិរញ្ញប្បទាន

**finding** របកគំហើញ, លទ្ធផលរកឃើញ, គំហើញ, ការរកឃើញ

**fine v. & n.** ១. ផាកពិន័យ ២. ប្រាក់ផាកពិន័យ

**finished goods/products** ផលិតផល សំរេច

**fire insurance** ការធានារ៉ាប់រងគ្រោះអគ្គីភ័យ

**firm** អង្គភាពអាជីព, សហគ្រាស

**firm offer** ការសន្យាលក់ជាក់លាក់

**firm sale** ការលក់ផ្តាច់ (តាមកិច្ចសន្យាត្រឹមត្រូវ)

**fiscal** នៃសារពើពន្ធ, ~ deficit ឱនភាពសារពើពន្ធ, ~ policy នយោបាយសារពើពន្ធ, ~ year ឆ្នាំសារពើពន្ធ

**fish culture/farming** ការចិញ្ចឹមត្រី

**fisheries reform** កំណែទំរង់វិស័យនេសាទ និងជលផល

**fisheries resource** ធនធានជលផល

**fishery** ការនេសាទ

**fishery zone** ដែននេសាទ, reserved ~ ដែននេសាទបំរុងទុក

**fishing lot** ឡូត៍នេសាទ

**fixed** ជាប់លាប់, ថេរ, អចល័ត, ~ asset ទ្រព្យសកម្មជាប់លាប់, អចលកម្ម, ~ capital ទុនអចល័ត, អចលកម្ម(ជាមូលធន), ~ cost/ expenses បន្ទុកចំណាយថេរ, ~ deposit ប្រាក់បញ្ញើមានកាលកំណត់, ~ rate អត្រាថេរ (មិនប្រែប្រួល)

**fixing of quotas** ការកំណត់កូតា, ការដាក់កូតា

**fixture** គ្រឿងបំពាក់ជាប់, fixtures and fittings គ្រឿងបំពាក់ (ទាំងអចល័ត និងចល័ត ដែលលក់ទៅជាមួយនឹងផ្ទះ)

**flammable substance** សារធាតុឆេះ

**flat** សំប៉ែត, រាប, ឆាការ, ~ fee កំរៃឆាកា, ~ price ថ្លៃឆាការ

**flaw** ខ្ចោះ, គុណវិបត្តិ

**flawed** ដែលមានខ្ចោះ, ដែលមានគុណវិបត្តិ

**flexible** ដែលបត់បែនបាន, ទន់ភ្លន់, ~ exchange rate អត្រាប្តូរប្រាក់ រស់/ទន់ភ្លន់

**flight of capital** លំហូរលឿនចេញមូលធន

**flimsy paper** ក្រដាសពើល្បៅ (ក្រដាសស្តើង)

**float v.** ១. អណ្តែត, ២. ដាក់ឱ្យអណ្តែត, floating rate អត្រា (ការប្រាក់) អណ្តែត

**floating capital** ទុនបង្វិល

**flooded forest** ព្រៃលិចទឹក

**floor price** ថ្លៃអប្បបរមា

**flora** រុក្ខជាតិ

**flotation of a new company** ការចាប់ផ្តើមបើកក្រុមហ៊ុនថ្មីដោយលក់សន្លឹកហ៊ុនរបស់ក្រុមហ៊ុននោះ

**flow** លំហូរ, ការហូរ

**flow chart** តារាង, អង្គការលេខ

**flow, stock** សន្និធិចរាចរ

**fluctuation** ការឡើងចុះ(ថ្លៃ)

**FOB** (free on board) ថ្លៃទំនិញដឹកដល់លើនាវា

**FOB airport** ថ្លៃទំនិញដឹកដល់អាកាសយានដ្ឋាន

**FOB shipment to destination** ថ្លៃទំនិញដឹកដល់គោលដៅ

**FOB trimmed** ថ្លៃទំនិញដឹកដល់លើនាវា និងរៀបអោយ

**FOB under tackle** ថ្លៃទំនិញដឹកដល់ក្រោមដងយោង

**focal point** ចំណុចប្រសព្វ
**focus v. & n.** ១. ផ្ដោត ២. ចំណុចផ្ដោត
**following** តាមក្រោយ, ~ year ឆ្នាំក្រោយ (ឆ្នាំក្រោយទី១)
**follow-up v. & n.** តាមដានបន្ត
**food** ម្ហូបអាហារ, ស្បៀង, ~ price index សន្ទស្សន៍ថ្លៃម្ហូបអាហារ, ~ products/stuffs ផលិតផលស្បៀង
**food balance** តុល្យការស្បៀង (បរិមាណស្បៀងទាំងអស់ដែលមាន ធៀបនឹង ចំនួនប្រជាជនដែលត្រូវចិញ្ចឹម)
**food for work** ស្បៀងសំរាប់ពលកម្ម (ឧ. អង្ករពលកម្ម)
**food security** សន្តិសុខស្បៀង
**FOR** (free on rail) ថ្លៃទំនិញដឹកដល់លើផ្លូវដែក
**force** ១. កំលាំង ២. កំលាំងពលកម្ម
**force majeure** ប្រធានសក្តិ
**force, come into** ចូលជាធរមាន, មានប្រសិទ្ធភាព
**forecast v. & n.** ព្យាករណ៍
**foreclose a mortgage v.** ប្ដឹងអំណូស, រឹបអូសកម្មសិទ្ធិអចលនវត្ថុដាក់ធានា, ប្ដឹងទាមទារកម្មសិទ្ធិ និក្ខេបទ្រព្យ/ទ្រព្យបញ្ចាំ (ដោយសារគេមិនបានសងបំណុលតាមកិច្ចសន្យា)
**foregoing** សេចក្តីទើបលើកឡើង
**foreign** បរទេស, ~ accounts គណនីនៅបរទេស, ~ assets ទ្រព្យសកម្មបរទេស, ទ្រព្យបញ្ញើនៅបរទេស, ~ balance ជញ្ជីងទូទាត់ អន្តរជាតិ, ~ currency/exchange រូបិយវត្ថុ បរទេស (រឺ រូបិយប័ណ្ណ), ~ exchange auction ការដេញថ្លៃរូបិយប័ណ្ណ, ~ direct investment (FDI) វិនិយោគផ្ទាល់ពីបរទេស, ~ inflows លំហូរចូលពីបរទេស (ជំនួយ, រូបិយប័ណ្ណ..), ~ liabilities (bank) ទ្រព្យអកម្មបរទេស, ~ reserves ធនបំរុងបរទេស, ~ trade ពាណិជ្ជកម្ម ក្រៅប្រទេស
**foreign-aid programme** កម្មវិធីជំនួយបរទេស
**foreign-trade turnover** ចំណូលពាណិជ្ជកម្មក្រៅប្រទេស
**foreman** មេការ, មេក្រុម (ជាង, កម្មករ)
**foresight** ការយល់ដឹងមុន
**forest** ព្រៃឈើ, protected ~ areas តំបន់ព្រៃការពារ, ~ concession ព្រៃសម្បទាន, coupe ~ ព្រៃគុប, operable ~ ព្រៃឈើអាចធ្វើអាជីវកម្មបាន
**forest product/sub-product** អនុផលព្រៃឈើ
**forestry** រុក្ខសាស្ត្រ
**forfeit money** ប្រាក់ពិន័យ
**forfeit v.** កាត់ចេញ, បាត់បង់ (ជាការពិន័យ)
**forfeited to the government** (ត្រូវបាន) រឹបអូសជាសម្បត្តិរដ្ឋ
**forgery** ការក្លែង
**form** ទ្រង់ទ្រាយ, legal ~ រូបភាពគតិយុត្ត
**form** (document) ទំរង់ការ (ឯកសារ)
**form and legal concepts of the law** ទំរង់ និង គតិ នៃច្បាប់
**formal** ផ្លូវការ, រៀបរយ, ~ sector វិស័យរៀបរយ
**formalities** បែបបទ, ទំរង់បែបបទ, ទំរង់ការ, fulfil v. ~ បំពេញបែបបទ
**formulation mission** បេសកកម្មលើកមតិ
**forward** មានកាលកំណត់ (នៅអនាគត), ~ delivery ការប្រគល់មានកាលកំណត់,

~ price ថ្លៃលក់មានកាលកំណត់
**forward v.** បញ្ជូនទំនិញ
**forwarding agency** ទីភ្នាក់ងារដឹកជញ្ជូន
**forwarding, advice of** លិខិតជូនដំណឹងបញ្ជូនទំនិញ
**FOT** (free on truck) ថ្លៃទំនិញដឹកដល់លើរថយន្ត
**foul bill of lading** ប័ណ្ណដឹកជញ្ជូនមិនល្អ (ដែលបញ្ជាក់ពីស្ថានភាពទំនិញមិនល្អនៅពេលម្ចាស់នាវាទទួលវា)
**foundation** ១. គ្រឹះ, មូលដ្ឋានគ្រឹះ, ខ្លឹមសារ ២. មូលនិធិ
**founder n.** ស្ថាបនិក, អ្នកបង្កើតក្រុមហ៊ុន
**founder v.** រលំ, ទទួលបរាជ័យ
**founding instrument** ឯកសារបង្កើត (ក្រុមហ៊ុន)
**frame** ក្រប, ក្របខ័ណ្ឌ
**framework** ក្របខ័ណ្ឌ
**franchise** សិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម (ដើម្បីធ្វើអាជីវកម្ម)
**franchisee** អ្នកទទួលសិទ្ធិប្រើឈ្មោះពាណិជ្ជកម្ម
**franchiser** អ្នកផ្តល់សិទ្ធិអោយប្រើឈ្មោះពាណិជ្ជកម្ម
**fraud** ការកែបន្លំ
**fraudulent** ដែលកែបន្លំ
**free** សេរី, ~ market economy សេដ្ឋកិច្ចផ្សារសេរី, carriage ~ ដឹកអោយមិនគិតថ្លៃ (អ្នកទិញមិនបាច់ចេញថ្លៃដឹកទេ)
**free alongside ship** (FAS) ថ្លៃដឹកទំនិញដល់គែមនាវា
**free board and lodging** អាហារនិងស្នាក់នៅដោយឥតបង់ថ្លៃ
**free currency** រូបិយវត្ថុទិញលក់បានដោយសេរី (រដ្ឋគ្មានដាក់កំហិតត្រួតត្រា)
**free of charge** ដោយឥតបង់ថ្លៃ
**free on board and trimmed** (see FOB trimmed) ថ្លៃទំនិញដឹកដល់លើនាវា និងរៀបអោយ
**free on rail** (see FOR)
**free on truck** (see FOT)
**free will** (ដោយ) សុទ្ធចិត្ត
**freedom of association** សេរីភាពកសាងសមាគម
**freehold property** កម្មសិទ្ធិគ្មានកាលកំណត់
**freeze** កក, បង្កក, wage freeze ការបង្កកបៀវត្សរ៍ (មិនអោយឡើងចុះ)
**freight** ថ្លៃដឹកជញ្ជូន, ~ forward ថ្លៃដឹកត្រូវបង់ដោយអ្នកទិញ
**freight prepaid** ថ្លៃដឹកជញ្ជូនបានបង់មុន
**freight, ad valorem** ថ្លៃដឹកជញ្ជូនយកតាមថ្លៃទំនិញ
**frequency** ភាពញឹកញាប់, ប្រេកង់ (ឧ. វិទ្យុ)
**freshwater** ទឹកសាប, ~fisheries ការនេសាទទឹកសាប ~fish ត្រីទឹកសាប
**fringe benefits** អត្ថប្រយោជន៍បន្ថែម
**frozen account** គណនី ផ្អឹប/បញ្ឈប់
**frozen assets** ទ្រព្យផ្អឹប, ទ្រព្យជាប់គុំ
**frozen capital** មូលធន ផ្អឹប/បញ្ឈប់
**fruitful** ដែលមានផ្លែផ្កា
**fuel** គ្រឿងឆេះ, ឥន្ធនៈ
**full** ពេញ, ឆ្អែត, សព្វគ្រប់, ~ price ថ្លៃពេញ (គ្មានចុះថ្លៃ), ~ capacity សមត្ថភាពពេញលេញ
**full time work** ការងារពេញម៉ោង
**fully fledged bank** ធនាគារមានគ្រប់សេវា (ដែលធំធាត់ពេញរូបរាង)

**full-right representative** តំណាងពេញសិទ្ធិ
**fully paid up** ដែលបានទូទាត់ទាំងស្រុង
**function** មុខងារ
**fund** មូលនិធិ, ~ accounting systems ប្រព័ន្ធគណនេយ្យមូលនិធិ, ~ flow លំហូរមូលនិធិ, ~ raising ការរៃអង្គាសមូលនិធិ
**fund** (French: provision) សំវិធានវត្ថុ (សំរាប់ទូទាត់មូលប្បទានប័ត្រ)
**fundamental adj.** ជាគ្រឹះ, ជាមូលដ្ឋាន, ~ research ការស្រាវជ្រាវជាគ្រឹះ
**funding agency/project** ទីភ្នាក់ងារ/គំរោង ផ្តល់មូលនិធិ
**funds held in trust** មូលនិធិបញ្ញើ (ឧ. អង្គការ ក ដែលទើបបង្កើតថ្មី មិនទាន់មានគណនីនៅធនាគារនៅឡើយ ។ ទាយកអាចផ្តល់ប្រាក់ អោយអង្គការ ក ដោយផ្ញើវាចូល គណនីរបស់អង្គការ ខ ដែលមានទំនាក់ទំនងល្អជាមួយខ្លួន ដើម្បីឱ្យអង្គការនេះបើកផ្តល់បន្តទៅឱ្យអង្គការ ក)
**fungibility** ភាពដែលអាចយកទៅជំនួសគ្នាបាន (របស់និមួយៗគ្មាន លក្ខណៈ/តំរូវការ ដើម្បីសំគាល់ចេញពីគ្នាទេ: ឧ. ដែកគោល), fungible adj.
**fungibles** ទំនិញអាចថ្លឹង/រាប់...បាន
**future value** តំលៃអនាគត

## G, g

**gain n. & v.** ១. កំណើន, capital ~ តំលៃលើស (លើការលក់ទ្រព្យសកម្មជាប់លាប់) ២. កើនឡើង, ចំណេញ (ជាប្រាក់)
**galloping inflation** អតិផរណាលោតផ្លោះ
**gamble on the stock exchange v.** លេងល្បែងទិញដូរសន្លឹកហ៊ុន
**gap** គំលាត
**garment industry** ឧស្សាហកម្មកាត់ដេរ
**garnishee n.** តតិយជនអំណួស (អ្នកដែលជំពាក់ប្រាក់ដល់បុគ្គលម្នាក់ ហើយដែលត្រូវតុលាការបញ្ជាឱ្យសងប្រាក់ទៅម្ចាស់បំណុលរបស់បុគ្គលម្នាក់នោះ)
**gateway** មាត់ច្រក, international communication ~ មាត់ច្រកទូរគមនាគមន៍អន្តរជាតិ
**gather** ប្រមូលផ្តុំ
**GATT** (General Agreement on Tariffs and Trade) ហ្គាត់, កិច្ចព្រមព្រៀងទូទៅស្តីពីតារាងពន្ធគយនិងពាណិជ្ជកម្ម
**GDP** (gross domestic product) ផសស (ផលិតផលក្នុងស្រុកសរុប)
**gem or gemstone** ត្បូងមានតំលៃ
**gender** យេនឌ័រ (តួនាទីបុរសស្ត្រី)
**gene** ហ្សែន, modify a gene កែច្នៃហ្សែន
**general** ១. ទូទៅ, គោលការណ៍ (ក្នុងប្រកាស..), ~ points (in law) កំណត់ទូទៅ, ~ provisions បទប្បញ្ញត្តិទូទៅ ២. អគ្គ, ~ director អគ្គនាយក
**general and administrative expenses** ចំណាយទូទៅ និងចំណាយរដ្ឋបាល
**general inspector** អគ្គាធិការ, deputy ~ អគ្គាធិការរង
**general inspectorate** អគ្គាធិការដ្ឋាន
**general ledger** (accounting) សៀវភៅធំ
**general meeting** មហាសន្និបាត
**general partner** អ្នកចូលហ៊ុនគ្មានកំរិត (ទទួលខុសត្រូវគ្មានកំរិត)
**general regulations** និតិរួម

**general rule, as a** តាមវិធានទូទៅ

**generality** ភាពទូទៅ

**generalisation** ការធ្វើឱ្យមានលក្ខណៈទូទៅ

**Generalised System of Preferences** (GSP) ប្រព័ន្ធអនុគ្រោះទូទៅ

**generally accepted accounting principle** (GAAP) គោលការណ៍គណនេយ្យមានការទទួលស្គាល់ទូទៅ

**genetic** នៃហ្សែន, ~ sequence លំដាប់ហ្សែន

**genetic modification** (GM) ការច្នៃហ្សែន, GM food អាហារច្នៃហ្សែន, GM agriculture កសិកម្មច្នៃហ្សែន

**genome** ជីណូម, សំណុំហ្សែន

**genus** ពួក, ជំពូក (សត្វ, រុក្ខជាតិ ...)

**geography, economic** ភូមិវិទ្យាសេដ្ឋកិច្ច

**geology** ភូគព្ភសាស្ត្រ

**gesture** កាយវិការ

**gift** អំណោយ

**gilt-edged investments** វិនិយោគមានសុវត្ថិភាពខ្ពស់ (ឧ. ប័ណ្ណរតនាគារ)

**global adj.** សាកល, សរុប, ~ demand តំរូវការសរុប, ~ social product ផលិតផលសង្គមសរុប, ~ economic recession ការធ្លាក់ចុះសេដ្ឋកិច្ចជាសាកល

**globalisation of economy** សាកលភាវូបនីយកម្មសេដ្ឋកិច្ច

**glossary** សទ្ទានុក្រម, បទានុក្រម

**glut** ច្រើនកកកុញ, ~ the market ច្រើនលិចលង់ទីផ្សារ

**GNP** (gross national product) ផលិតផលជាតិសរុប, ផលទុនជាតិសរុប, ~ deflator សន្ទស្សន៍បរិត្តផរណាផលិតផលជាតិសរុប

**goal** គោលដៅ

**going concern** អាជីវកម្មមានដំណើរការ

**going price** ថ្លៃធម្មតា, ថ្លៃចរន្ត

**going rate** អត្រាធម្មតា, អត្រាចរន្ត

**gold standard** ស្តង់ដារមាស, ~ system ប្រព័ន្ធប្តូរប្រាក់តាមស្តង់ដារមាស

**goods** ទំនិញ, capital ~ ទំនិញមូលធន, consumer/consumable ~ ទំនិញប្រើប្រាស់, dry ~ ក្រណាត់និងខោអាវ, faulty ~ ទំនិញខូចគុណភាព, finished ~ ផលិតផលសំរេច, free circulation ~ ទំនិញចរាចរសេរី, luxury ~ ទំនិញប្រណិត, household ~ ទំនិញប្រើប្រាស់ក្នុងផ្ទះ, manufactured ~ ទំនិញធ្វើដោយម៉ាស៊ីន, ~ and services ទំនិញ និងសេវា, ~ in bond ទំនិញនៅឃ្លាំងគយ (រង់ចាំការបង់ពន្ធ), ~ in stock ទំនិញក្នុងស្តុក, ~ left on hand ទំនិញត្រូវបានបដិសេធមិនទទួល, ~ in transit ទំនិញឆ្លងកាត់, ~ on consignment ទំនិញផ្ញើទៅលក់

**goodwill ១.** កេរ្តិ៍ឈ្មោះជំនួញ, មូលនិធិពាណិជ្ជកម្ម **២.** សុឆន្ទៈ

**governance** អភិបាលកិច្ច, local ~ អភិបាលកិច្ចមូលដ្ឋាន

**government** រដ្ឋាភិបាល, ~ and institutional accounting គណនេយ្យរដ្ឋាភិបាល និងគណនេយ្យស្ថាប័ន, ~ agency ស្ថាប័នរដ្ឋ, ~ securities សញ្ញាប័ណ្ណរដ្ឋាភិបាល

**grace period** (debt payment) ថេរវេលាអនុគ្រោះ

**grade** (civil servant) ថ្នាក់

**grading** ការបែងចែកគុណភាព

**grand plan** ប្លង់ចំបង

**grand total** សរុបរួម
**grandstanding** ការយកកំពស់
**grant** អំណោយហិរញ្ញវត្ថុ, ~ aid ជំនួយឥតសំណង
**graphics** ក្រាហ្វិក, ពិន្ទុរេខីយ៍
**grassroots level** កំរិតមូលដ្ឋាន
**grassroots organisation** អង្គការថ្នាក់ក្រោម (កំរិតប្រជាជន)
**gratuity** ប្រាក់សគុណ, សទ្ធាទាន, ជំនួន (តបស្នង)
**Greater Mekong Sub-region** មហាអនុតំបន់មេគង្គ
**green revolution** បដិវត្តន៍បៃតង
**greenhouse** ផ្ទះកញ្ចក់, ~ effect បច្ច័យផ្ទះកញ្ចក់, ~ gas ឧស្ម័នផ្ទះកញ្ចក់
**grid** បណ្តាញ (ប្រទាក់ក្រឡា)
**gross** ដុល, សរុប, ~ domestic product (GDP) ផលិតផលក្នុងស្រុកសរុប (ផសស), ~ margin ចំណេញដុល, អប្បហារដុល (ជាភាគរយនៃថ្លៃលក់), ~ national product (GNP) ផលិតផល/ផលទុន ជាតិសរុប,~ price ថ្លៃដុល, ~ negligence ការធ្វេសប្រហែសធ្ងន់ធ្ងរ (ច្បាប់), ~ output ធាតុចេញដុល, ~ profit ចំណេញដុល, ~ proceeds/receipts/returns ចំណូលដុល, ~ weight ទំងន់ដុល
**groupage/grouped bill of lading** វិក្កយបត្រដឹកជញ្ជូនសរុប
**growth** កំណើន, ការលូតលាស់, ~ rate អត្រាកំណើន
**GSP** (Generalised System of Preferences) ប្រព័ន្ធអនុគ្រោះទូទៅ
**guarantee** ការធានា, វត្ថុធានា, ~ for a loan វត្ថុធានាសំរាប់កំចី, ~ of payment ការធានាទូទាត់, ~ certificate or certificate of ~ ប័ណ្ណធានាគុណភាព, quality ~ ការធានាគុណភាព
**guaranteed bill of exchange** រូបិយាណត្តិមានការធានា
**guaranteed deposit fund** ប្រាក់កក់
**guarantees and commitments under signature** (banking) ការសន្យាតាមហត្ថលេខា
**guarantor** អ្នកធានា (ឧ. លើអ្នកណាម្នាក់ក្នុងការសងបំណុល)
**guardianship** អាណាព្យាបាល
**guideline** គោលការណ៍ណែនាំ
**guilt** ពិរុទ្ធភាព

## H, h

**habitual** ជាទំលាប់
**hacker** ហាក់គ័រ (អ្នកលួចជ្រៀតចូលទៅក្នុងប្រព័ន្ធកុំព្យូទ័ររបស់អ្នកដទៃ)
**half** ពាក់កណ្តាល, first ~ of the 6th century ពាក់កណ្តាលទី១ នៃសតវត្សរ៍ទី៦
**hallucination** មមាល, ការមមាល
**hand bill** ខិត្តប័ណ្ណ (ប័ណ្ណឃោសនាផ្សព្វផ្សាយចែកអោយផ្ទាល់ដៃ)
**handicraft** សិប្បកម្ម, វត្ថុធ្វើដោយដៃ, ~ goods ទំនិញសិប្បកម្ម
**handle** ចាត់ចែង, ដោះស្រាយ, ~ a situation ដោះស្រាយស្ថានការណ៍
**handling** (goods) ការលើកដាក់
**hard** រឹង, លំបាក, ~ condition លក្ខខណ្ឌតឹងតែង, ~ bargain ការតថ្លៃដ៏តឹងតែង, ~ cash

សាច់ប្រាក់មានក្នុងដៃ
**hard disk** (computer) ថាសរឹង
**hardware** គ្រឿងចក្រធ្ងន់, ធាតុរឹង (កុំព្យូទ័រ)
**harmonisation** សុខដុមនីយកម្ម, ការធ្វើឱ្យមានភាពចុះសំរុងគ្នា
**harmonised** ដែលរលូនគ្នា
**harmony** ភាពសុខដុមរមនា
**harsh conditions** លក្ខខណ្ឌតឹងតែង
**haulage** ថ្លៃដឹកទំនិញ, ការដឹកទំនិញ (តាមរថយន្ត រឺ រថភ្លើង), ~ cost (rates) ថ្លៃដឹកទំនិញ, ~ company/firm ក្រុមហ៊ុនដឹកជញ្ជូនទំនិញ
**hazardous** ដែលប្រកបដោយគ្រោះថ្នាក់
**head office** ការិយាល័យធំ, ទីចាត់ការធំ
**head tax** ពន្ធមនុស្ស
**heading** ចំណងជើង, ខ្ទង់ (តារាងតុល្យការ)
**headquarters** (of a company) ទីស្នាក់ការកណ្ដាល
**health care** ការថែទាំសុខភាព
**healthy** ដែលមានសុខភាពល្អ, ~ balance sheet តារាងតុល្យការស្តែងផលចំណេញ, ~ profit ផលចំណេញក្នុងចំនួនយ៉ាងច្រើន
**hearing** សវនាការ
**heavy equipment** បរិក្ខារធុនធ្ងន់
**heavy industry** ឧស្សាហកម្មធុនធ្ងន់
**hedged** (ដែលត្រូវបាន) ការពារការខាតបង់
**heir** ទាយាទ (អ្នកទទួលមរតក)
**hereafter** ពីនេះតទៅ
**hereby** តាមរយៈនេះ
**heritage** មរតក, national ~ បេតិកភ័ណ្ឌជាតិ
**heterogeneity** ភាពមិនស្មើសាច់
**heterogeneous** លាយចំរុះគ្នា, វិសមាន, វិសភាគ (មិនដូចគ្នា, មិនស្មើសាច់)
**hidden adj.** បង្កប់, ~ reserves ធនបំរុងបង្កប់
**hierarchy** ឋានានុក្រម
**high grade** (ore) គុណភាពខ្ពស់ (រ៉ែ)
**high school** វិទ្យាល័យ, junior ~ អនុវិទ្យាល័យ
**high-tech** (sector) បច្ចេកវិទ្យាខ្ពស់ (វិស័យ)
**hindsight** ការយល់ដឹងតាមក្រោយ (គឺមានបទពិសោធន៏ដោយព្រឹត្តិការណ៏បានកើតឡើងហើយ)
**hire-purchase agreement** កិច្ចសន្យាជួល-ទិញផ្ដាច់, កិច្ចសន្យាទិញបណ្ដាក់
**historic/historical cost** តំលៃតាមប្រវត្តិសាស្ត្រ (តំលៃជាក់ស្តែងកាលពីពេលទិញចូល)
**historical steps** ជំហានមានអត្ថន័យជាប្រវត្តិសាស្ត្រ
**hold in trust** កាន់កាប់ជាការផ្ញើទុក
**holder** (of a cheque...) អ្នកកាន់
**holder in due course** អ្នកកាន់កាប់ត្រឹមត្រូវ, គាហកនិយ័ត
**holding company** ក្រុមហ៊ុនហូលឌិញ (កាន់កាប់ជាង ៥០% នៃភាគហ៊ុនក្នុងក្រុមហ៊ុនមួយទៀត)
**home market** ផ្សារក្នុងស្រុក
**homelessness** ភាពគ្មានផ្ទះសំបែង
**home-made** ផលិតនៅ ក្នុងស្រុក/ផ្ទះ
**homogeneity** ភាពស្មើសាច់
**homogenous adj.** សភាគ, ស្មើសាច់ (ដូចគ្នា)
**honorarium** ប្រាក់សគុណ
**horizontal** ផ្ដេក, ~ coordination ការសំរបសំរួលតាមខ្សែផ្ដេក (រឺ ខ្សែទទឹង)
**horticulture** សាកវប្បកម្ម, ការធ្វើច្បារដំណាំ
**host government** រដ្ឋាភិបាលម្ចាស់ផ្ទះ
**hot money** (money moving frequently from one country to another) លុយក្ដៅ
**household** គ្រួសារ, គ្រួ, female-headed ~ គ្រួសារស្ត្រីមេគ្រួ, male-headed ~ គ្រួសារ

បុរសមេគ្រួ

**household equipment** បរិក្ខារគេហកិច្ច

**household survey** អង្កេតគ្រួសារ

**housing** ផ្ទះស្នាក់នៅ, ការផ្តល់ផ្ទះស្នាក់នៅ, ផ្ទះសំបែង (ខ្ទង់ចំណាយ), ~ loan កំចីសំរាប់សង់/ទិញផ្ទះ

**human-capital investment** វិនិយោគទុនមនុស្ស

**humanism** មនុស្សនិយម

**humanitarian assistance** ជំនួយមនុស្សធម៌

**humanitarian relief** ការសង្គ្រោះផ្នែកមនុស្សធម៌

**humanity** មនុស្សជាតិ, នរជាតិ

**husbanding of resources** ការគិតគូរសំចៃធនធាន

**hydropower construction** សំណង់វារីអគ្គិសនី

**hyperinflation** អតិផរណាលោតផ្លោះ

**hypothesis** សម្មតិកម្ម

## I, i

**idea** គំនិត

**ideal** ឧត្តមគតិ

**idealised condition** លក្ខខណ្ឌសុក្រិតភាព

**identification** អត្តសញ្ញាណកម្ម, ~ mission បេសកកម្ម រកសំគាល់/បំផុសគំនិត

**identify v.** ស្វែងរកមើល, រកសំគាល់, សំគាល់បានតាមភិនភាគ,

**ideology** មនោគមន៍វិជ្ជា

**idle** ទំនេរចោល, គ្មានប្រើការ, ~ capital ទុនគ្មានប្រើការ, ~ time ម៉ោងទំនេរចោល (ម៉ាស៊ីនធ្វើការបានតែគ្មានដំណើរការ)

**illegal adj.** ខុសច្បាប់, ~ contract កិច្ចសន្យាខុសច្បាប់

**illicit adj.** ខុសច្បាប់, ~ alcohol ស្រាខុសច្បាប់

**ill-will** ទុរឆន្ទៈ (បំណងអាក្រក់)

**imbalance** អតុល្យភាព, នានត្តភាព

**imaginary profit** ចំណេញប្រឌិត

**immaculate** ថៃស (ថ្មី, ស្អាត)

**immediate objective** ទិសដៅបន្ទាន់

**immediate payment** ការទូទាត់ភ្លាមៗ

**immediate supervisor** អ្នកមើលការខុសត្រូវផ្ទាល់

**immobilise** (finance) ធ្វើអចលកម្ម

**immoral** អសីលធម៌

**immovable** (property) **n.** អចលនទ្រព្យ

**immunity** ១. ភាពស៊ាំ (នឹងជំងឺ) ២. អភ័យឯកសិទ្ធិ, diplomatic ~ អភ័យឯកសិទ្ធិការទូត

**impact** ផលប៉ះពាល់

**impartial** មិនលំអៀង

**impartiality** ភាពមិនលំអៀង, អនាគតិ

**impeccable** ឥតខ្ចោះ

**imperfection** ភាពមានខ្ចោះ, អនិបុណភាព

**impetus n.** សន្ទុះជំរុញ

**implementation of a law** ការអនុវត្តន៍ច្បាប់

**implementing agency** ទីភ្នាក់ងារអនុវត្ត

**import** ការនាំចូល, អាហរណ, ~ duty ពន្ធនាំចូល, ~ permit អាជ្ញាប័ណ្ណនាំចូល, ~ quota កូតានាំចូល

**importer** អ្នកនាំចូល, អាហារិន
**import-export** អាហរណ-នីហរណ, ការនាំចេញ-នាំចូល
**imports** ទំនិញនាំចូល, វិទេសភ័ណ្ឌ
**impose taxes** អោយបង់ពន្ធ
**impoundment** ការឃាត់ចាប់ទុក (រថយន្ត, ទូក...)
**impression** ចំណាប់អារម្មណ៍
**improvement** ការកែលំអ, សុវុឌ្ឍិកម្ម
**impunity** និទណ្ឌភាព, ភាពរួចទោស, culture of ~ វប្បធម៌និទណ្ឌភាព
**impurity n.** ១. ភាពមិនសុទ្ធ ២. អ្វីដែលធ្វើឱ្យមិនសុទ្ធ (ឧ. កករ)
**in good faith** ដោយស្មោះត្រង់
**in post** ក្នុងតំណែង
**inaccuracy** ភាពមិនត្រឹមត្រូវ
**inaccurate adj.** មិនត្រឹមត្រូវ
**inactive adj.** អសកម្ម
**inadequate** មិនសមល្មម
**inappropriate** មិនសមស្រប, ~ aid ជំនួយមិនសមស្រប
**incapacity** អសមត្ថភាព, physical/mental ~ ការបាត់បង់សមត្ថភាពខាង បញ្ញា/កាយសម្បទា
**incentive** គ្រឿងលើកទឹកចិត្ត, ការលើកទឹកចិត្ត, investment ~ ការលើកទឹកចិត្តវិនិយោគ
**inception** ការកកើត
**incertitude** ភាពមិនប្រាកដ
**incessant** ដែលឥតឈប់ឈរ
**incidence n.** ការកើតមាន, ~ of tax បន្ទុកពន្ធ (ចំនួនប្រាក់ពន្ធត្រូវធ្លាក់លើបុគ្គលណាម្នាក់នៅចុងបញ្ចប់)
**incident** ឧប្បត្តិហេតុ
**incidental** បន្ទាប់បន្សំ
**inclusion** ការរាប់បញ្ចូល
**inclusive** ដែលរាប់បញ្ចូល, ជាបរិយាប័ន្ន
**income** ចំណូល, ផលទុន, បដិលាភ, disposable ~ ចំណូលក្រោយកាត់ពន្ធ, ចំណូលប្រើបានដោយសេរី, private ~ ចំណូលក្រៅពីបៀវត្សរ៍, personal ~ ចំណូលផ្ទាល់ខ្លួន, ~ account គណនីចំណូល, ~ (collected) in advance ចំណូលបានទទួលមុន, ~ per capita ចំណូលក្នុងមនុស្សម្នាក់, ~ tax ពន្ធលើប្រាក់ចំណូល, ~ statement របាយការណ៍ចំណូល
**income-generating activities** សកម្មភាពបង្កើតប្រាក់ចំណូល
**income-outlay accounts** គណនីចំណូល-ចំណាយ
**incompatibility** វិសមិតភាព, ភាពមិនចុះសំរុង
**incompetence** អសមត្ថភាព
**inconvenience** ផលវិបាក
**inconvertible currency** រូបិយវត្ថុមិនអាចប្តូរ (យករូបិយវត្ថុដទៃ) បាន
**incorporated** ចូលជាក្រុមហ៊ុន, បានចុះបញ្ជីជាក្រុមហ៊ុន
**incorporated company** ក្រុមហ៊ុន (ជានីតិបុគ្គលពេញលេញ)
**increase v. & n.** ១. កើន ២. កំណើន
**incremental** ដែលកើនជាដំណាក់ៗ
**indebtedness** ភាពជំពាក់បំណុល
**indefinite** មិនជាក់លាក់, គ្មានកំនត់
**indemnify v.** ធ្វើសំណង
**indemnity** ១. សំណង ការខូចខាត/ជំងឺចិត្ត ២. ប្រាក់បំណាច់
**independent audit** សវនកម្មឯករាជ្យ
**in-depth** ស៊ីជំរៅ, ~ evaluation ការវាយតំលៃស៊ីជំរៅ

**index** សន្ទស្សន៍

**indexation** ការដាក់សន្ទស្សន៍ (ឧ. អោយបៀវត្សរ៍ប្រែប្រួលទៅតាមអតិផរណា)

**indicator** អាំងឌីកាទ័រ, សូចនាករ

**indigenous people** ប្រជាជនដើម

**indirect tax** ពន្ធប្រយោល

**individual** ឯកត្តជន, បុគ្គល, ~ insurance ការធានារ៉ាប់រងបុគ្គល

**inducement** គ្រឿងជំរុញទឹកចិត្ត

**industrialisation** ឧស្សាហូបនីយកម្ម

**industrious adj.** ឧស្សាហ៍ (ព្យាយាម)

**industry** ឧស្សាហកម្ម, របរ, primary ~ ឧស្សាហកម្មវត្ថុធាតុដើម, secondary ~ ឧស្សាហកម្មកែច្នៃ (ពីវត្ថុធាតុដើមទៅផលិតផល), light ~ ឧស្សាហកម្មធុនស្រាល, heavy ~ ឧស្សាហកម្មធុនធ្ងន់, extractive ~ ឧស្សាហកម្មនិស្សារណកម្ម (ឧ. ឧស្សាហកម្មទាញយករ៉ែ)

**inefficiency** អប្រសិទ្ធភាព

**inequality** វិសមភាព, ភាពមិនស្មើគ្នា, income ~ វិសមភាពនៃប្រាក់ចំណូល

**infant mortality rate** អត្រាមរណៈកុមារ

**inference** ការសន្និដ្ឋាន

**inflammable goods** ទំនិញអាចឆាបឆេះ

**inflate** បំប៉ោង, ធ្វើអោយមានអតិផរណា, inflated price ថ្លៃបំប៉ោង (តំលើងខ្ពស់ដោយគ្មានហេតុផល)

**inflation** អតិផរណា, ~ accounting គណនេយ្យអតិផរណា (ថ្លៃទ្រព្យសកម្មមានគិតបញ្ចូលអតិផរណា), ~ factor កត្តាពង្រីក, កត្តាអតិផរណា

**inflationary gap** គំលាតអតិផរណា

**inflationary period** រយៈពេលមានអតិផរណា, អតិផរណាកាល

**inflexibility** ភាពរឹងកំព្រឹស, ភាពមិនរស់រវើក

**inflict v. a penalty** ដាក់ទោសទ័ណ្ឌ (ឧ. ចាប់អោយបង់ផាកពិន័យ)

**inflow** លំហូរចូល

**influential** ដែលមាន អនុភាព/ឥទ្ធិពល

**influx** លំហូរគំហុកចូល

**informal sector** វិស័យមិនរៀបរយ, វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

**information and communication technology** (ICT) បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍

**information technology** (IT) បច្ចេកវិទ្យាព័ត៌មាន

**infrastructure** ហេដ្ឋារចនាសម្ព័ន្ធ

**infringe v.** ប្រព្រឹត្តខុស, ល្មើស (ច្បាប់, កិច្ចសន្យា... ), infringement n.

**inheritance** មរតក (អំពីអ្នកស្លាប់)

**in-house adj.** ក្នុងអង្គភាព, ~ language training ការបណ្តុះបណ្តាលភាសាក្នុងអង្គភាព

**initial adj.** ដំបូង, ~ capital មូលធនដំបូង (សំរាប់ចាប់ផ្តើមអាជីវកម្ម), ~ price ថ្លៃដំបូង

**initial outlay or initial capital outlay** សោហ៊ុយបង្កើតសហគ្រាសដំបូង

**initial v.** ចុះហត្ថលេខាសង្ខេប, initialisation n.

**initiative** គំនិតផ្តួចផ្តើម, ការផ្តួចផ្តើមគំនិត

**injunction** (judge's order) អធិបញ្ញា (បញ្ជារបស់ចៅក្រម)

**injustice** អយុត្តិធម៌

**in-kind contribution** វិភាគទានជាវត្ថុ

**input n.** ធាតុចូល

**inquiry** ការសាកសួរ (ព័ត៌មាន, ថ្លៃ..), letter of ~ លិខិតសាកសួរព័ត៌មាន

**insensitivity** ១. អវេទយិតភាព ២. ភាពមិនចាប់អារម្មណ៍

**insider trading** ការជួញដូរហ៊ុនដោយអ្នកផ្ទៃក្នុង (ដែលដឹងព័ត៌មានសំងាត់ពីក្រុមហ៊ុន)

**insolvency** ភាពមិនអាចសងបំណុលបាន, អសាធភាព

**inspect v.** ធ្វើអធិការកិច្ច, ត្រួតពិនិត្យ

**inspection** អធិការកិច្ច, ~ fee កំរៃសេវាអធិការកិច្ច, pre-shipment ~ អធិការកិច្ចទំនិញមុនពេលផ្ទុក, ~ certificate វិញ្ញាបនប័ត្រអធិការកិច្ច

**inspectorate** ក្រុមអធិការកិច្ច

**installation** ឋបនកម្ម, ការរៀបចំតំលើង, ~ cost ចំណាយផ្គុំតំលើង

**instalment** ប្រាក់សងបណ្តាក់, ~ system ប្រព័ន្ធទូទាត់បណ្តាក់

**instalment sales credit or instalment plan buying** ការលក់/ទិញ ដោយទូទាត់សងបណ្តាក់

**instalment shipment** ការបញ្ជូនទំនិញជាបណ្តើរៗ

**institutional finance** ហិរញ្ញវត្ថុស្ថាប័ន

**institutionalisation** ស្ថាបន្ទូបនីយកម្ម

**institutionalise** ធ្វើស្ថាបន្ទូបនីយកម្ម, កសាងជាស្ថាប័ន

**instruction** បទបញ្ជា, សេចក្តីណែនាំ

**instrument** បរិធាន, ឧបករណ៍, negotiable ~ ឧបករណ៍ទូទាត់

**instrument of accession** លិខិតូបករណ៍ចូលជាភាគី

**instrument of ratification** លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន

**insufficiency** ភាពមិនគ្រប់គ្រាន់

**insurance** ការធានារ៉ាប់រង, all risks ~ ការធានារ៉ាប់រងហានិភ័យគ្រប់ប្រភេទ, car ~ ការធានារ៉ាប់រងលើរថយន្ត, life ~ ការធានារ៉ាប់រងលើជីវិត, ~ agent ភ្នាក់ងារធានារ៉ាប់រង, ~ certificate វិញ្ញាបនប័ត្រធានារ៉ាប់រង, ~ company ក្រុមហ៊ុនធានារ៉ាប់រង, ~ law ច្បាប់ស្តីពីការធានារ៉ាប់រង, ~ policy ប័ណ្ណសន្យារ៉ាប់រង, ~ premium(s) បុព្វលាភធានារ៉ាប់រង

**insured n.** អ្នកត្រូវបានធានារ៉ាប់រង

**insurer** អ្នកធានារ៉ាប់រង

**intake** ការស្រូបចូល

**intangible** អរូបី, ~ assets ទ្រព្យអរូបី

**integration** សមាហរណកម្ម, ការបញ្ចូលគ្នា, ~ of industry សមាហរណកម្មឧស្សាហកម្ម, vertical ~ សមាហរណកម្មបញ្ឈរ

**integrity** ភាពស្អាតស្អំ, territorial ~ បូរណភាពដែនដី

**intellectual property** កម្មសិទ្ធិបញ្ញា

**intelligible** ដែលយល់បាន

**intensification** ប្រពលកម្ម, ប្រពលវប្បកម្ម, agricultural ~ ប្រពលវប្បកម្មកសិកម្ម

**intensive** អតិផល, ~ agriculture កសិកម្មអតិផល

**intention** បំណង, ចេតនា

**interaction** អន្តរកម្ម

**interactive** អន្តរសកម្ម

**inter-bank adj.** អន្តរធនាគារ, ~ settlement system ប្រព័ន្ធទូទាត់អន្តរធនាគារ

**inter-censal decade** ទសវត្សរ៍ចន្លោះជំរឿន

**interdependence** ការពឹងផ្អែកគ្នាទៅវិញទៅមក

**interest** ១. ផលប្រយោជន៍ ២. ការប្រាក់,

compound ~ ការប្រាក់សមាស, high/low ~ ការប្រាក់ ខ្ពស់/ទាប, simple ~ ការប្រាក់សាមញ្ញ, ~ due date ថ្ងៃគិតការប្រាក់, ~ period កាលគិតការប្រាក់

**interest rate** អត្រាការប្រាក់, ~ for savings អត្រាការប្រាក់សន្សំ

**interference** ការជ្រៀតជ្រែក

**integrate** v. ធ្វើសមាហរណកម្ម, ដាក់បញ្ចូល, ~ed pest management (IPM) វិធានការចំរុះថែទាំដំណាំ

**interim** ស្ដីទី, បណ្ដោះអាសន្ន

**intermediary project** គំរោងអន្តរការី

**intermediate goods** ទំនិញអន្តរការី

**intermediate output** ធាតុចេញអន្តរការី, ផលិតផលអន្តរការី

**intermediate technology** បច្ចេកវិទ្យាថ្នាក់កណ្ដាល

**intermediation** អន្តរការីកម្ម, financial ~ អន្តរការីកម្មហិរញ្ញវត្ថុ

**intern n.** (see trainee) កម្មសិក្សាការី

**internal** ផ្ទៃក្នុង, ~ affairs កិច្ចការផ្ទៃក្នុង, ~ audit សវនកម្មផ្ទៃក្នុង, ~ control ការត្រួតពិនិត្យផ្ទៃក្នុង, ~ rate of return (IRR) អត្រាទាញចំណូលផ្ទៃក្នុង, ~ transfer បង្វែរផ្ទៃក្នុង

**international** អន្តរជាតិ, ~ standard ស្តង់ដារអន្តរជាតិ, ~ bidding/tendering ការដេញថ្លៃជាអន្តរជាតិ, ~ relations ទំនាក់ទំនងអន្តរជាតិ

**International Air Transport Association** (IATA) សមាគមដឹកជញ្ជូនផ្លូវអាកាសអន្តរជាតិ

**International Monetary Fund** (IMF) មូលនិធិរូបិយវត្ថុអន្តរជាតិ

**International Organisation for Standardisation** (ISO) អង្គការអន្តរជាតិខាងស្តង់ដារូបនីយកម្ម

**internet** អ៊ិនធឺណិត, ~ -cafe សាលបំរើអ៊ិនធឺណិត

**intersect v.** (graph lines) កាត់គ្នា

**inter-sectoral** អន្តរវិស័យ

**interview v. & n.** ១. សំភាស, ធ្វើសំភាស ២. បទសំភាសន៏, semi-structured ~ បទសំភាសន៏ពាក់កណ្ដាលរៀបរយ (ប្រើបញ្ជីសំនួរមួយភាគ និងសួរថែមមួយភាគ)

**interviewee n.** អ្នកឆ្លើយសំភាសន៏

**interviewer n.** អ្នកសួរសំភាសន៏

**intimidate v.** បំភិតបំភ័យ

**intra-cluster** ក្នុងរង្វង់កញ្ចុំ

**intrinsic** សជ្ឈន្តិកៈ

**introduction** សេចក្ដីផ្ដើម

**intuition** អព្ភន្តញ្ញាណ

**inundated forest** (see flooded forest) ព្រៃលិចទឹក

**invalidate v.** ចាត់ទុកជាមោឃៈ

**invaluable adj.** កាត់ថ្លៃមិនបាន

**invasion** ការលុកលុយ, ~ of privacy ការរំលោភសិទ្ធិជាឯកជន

**inventory** សារពើភណ្ឌ, ស្តុក, ទំនិញ, draw up an ~ ធ្វើបញ្ជីសារពើភ័ណ្ឌ

**inventory stock card** ប័ណ្ណស្តុក

**invest v.** វិនិយោគ, ធ្វើវិនិយោគ

**investigate v.** ស៊ើបអង្កេត

**investment n.** វិនិយោគ, ការបណ្ដាក់ទុន, ~ licence អាជ្ញាប័ណ្ណវិនិយោគ

**investor** វិនិយោគិន, អ្នកវិនិយោគ
**invisible adj.** មើលមិនឃើញ, ~ assets ទ្រព្យអរូបី
**invoice** វិក្កយបត្រ
**involuntary** អចេតនា, ឥតបំណង
**involvement** ការ ចូលពាក់ព័ន្ធ/ពាក់ព័ន្ធ
**IOU** (I owe you) លិខិតទទួលជំពាក់ (ខ្ញុំជំពាក់អ្នក)
**irrecoverable** ដែល ប្រមូលមិនបាន/ ទារមិនបាន
**irregular** មិនទៀងទាត់, មិនប្រក្រតី
**irregularities** (mistakes) ភាពមិនប្រក្រតី (កំហុស)
**irrelevant** ដែលមិនទាក់ទង
**irreversible adj.** ដែលមិនអាចប្រែក្រឡាស់បាន
**irrevocable adj.** មិនអាចបដិសេធបាន, ~ letter of credit សារតណទានមិនអាចបដិសេធបាន
**irrigate v.** ស្រោចស្រព, irrigation n.
**issuance** ការបោះផ្សាយ (ក្រដាសប្រាក់)
**issue bank** ធនាគារបោះផ្សាយក្រដាសប្រាក់
**issue v.** (a licence) ចេញ (អាជ្ញាប័ណ្ណ), currency issued រូបិយវត្ថុបោះផ្សាយ
**issuing bank** (for a letter of credit) ធនាគារបើកសារតណទាន
**IT** (Information Technology) បច្ចេកវិទ្យាព័ត៌មាន
**item** ១. អីវ៉ាន់, មុខ (ទំនិញ) ២. ខ្ទង់, cancel an ~ (accounting) បដិសេធលេខនា, enter an ~ ចុះលេខនា, off-balance sheet items ខ្ទង់ក្រៅតារាងតុល្យការ

## J, j

**jettison** ទំលាក់អីវ៉ាន់ចោលខ្លះដើម្បីសំរាល (នាវា, យន្តហោះ)
**job** ការងារ, white-collar ~ or office ~ ការងារក្នុងការិយាល័យ, ~ description ពិពណ៌នាការងារ, ~ design គំរោងការងារ, ប្លង់ការងារ, ~ grading/ranking ចំណាត់ថ្នាក់ការងារ, ~ holder អ្នកកាន់ការងារ, ~ lot ទំនិញចំរុះមួយដុំៗ ច្រើនអន់ៗ និងលក់ថោកៗ, ~ rotation ការប្តូរវេនការងារ, ~ specialisation ឯកទេសកម្មការងារ, ~ title ឈ្មោះការងារ
**joblessness** ភាពអត់ការងារធ្វើ, និកម្មភាព
**joint** (enterprise, committee) ចំរុះ
**joint** (liability) (ការទទួលខុសត្រូវ) រួមគ្នា, ~ and several liability ការទទួលខុសត្រូវរួមគ្នានិងរៀងៗខ្លួន
**joint account** គណនីរួម (មានម្ចាស់គណនីពី ២នាក់ឡើងទៅ)
**joint inter-ministerial committee** គណៈកម្មាធិការចំរុះអន្តរក្រសួង
**joint owner** ម្ចាស់កម្មសិទ្ធិរួមគ្នា
**joint venture** (គំរោង) វិនិយោគចំរុះ, ~ enterprise សហគ្រាសសមាសភាពសេដ្ឋកិច្ចចំរុះ
**joint-stock bank** ធនាគាររួមភាគហ៊ុន
**joint-stock company** (see public limited company) សាជីវកម្មក្រុមហ៊ុនភាគហ៊ុន

**journal** ១. ទិន្នានុប្បវត្តិ (គណនេយ្យ)
២. សារព័ត៌មាន
**journal voucher** ប័ណ្ណទិន្នានុប្បវត្តិ, សក្ខីប័ត្រចុះបញ្ជី
**journalising** ការចុះទិន្នានុប្បវត្តិ
**judgement** ១. ការវិនិច្ឆ័យ
២. សាលក្រម (តុលាការ)
**judicial record** លិខិតថ្កោលទោស (តុលាការ)
**judicial reform** កំណែទំរង់ប្រព័ន្ធយុត្តិធម៌
**judiciary** អង្គចៅក្រម
**jump-start** ចាប់ផ្តើមឱ្យបានឆាប់
**junk n.** របស់អត់ប្រយោជន៍, របស់អេតចាយ
**juridical** គតិយុត្តិ (ដែលស្របតាមច្បាប់ និងរបៀបរបបនៃ ច្បាប់/តុលាការ)
**jurisdiction** ដែនសមត្ថកិច្ច, យុត្តាធិការ
**just adj.** ត្រឹមត្រូវ, យុត្តិធម៌
**justification of a project** ការធ្វើយុត្តិកម្មគំរោង, ការបង្ហាញហេតុផលពីតំរូវការធ្វើគំរោង
**justified** (expense...) (ចំណាយ...) មានសក្ខីកម្ម
**justify** ធ្វើយុត្តិកម្ម

## K, k

**key role** តួនាទីគន្លឹះ

**keynote address** សុន្ទរកថាគន្លឹះ

**kind, payment in** ការទូទាត់ជាវត្ថុ

## L, l

**label** ស្លាក (សំរាប់បិទលើផលិតផល)
**labour** ពលកម្ម (ការងារ វីពលករ), casual ~ ពលកម្មអណ្តែត (រយះពេលការងារខ្លី), manual ~ ហត្ថកម្ម, organised ~ ពលកម្មចូលសហជីព, skilled ~ ពលកម្មមានជំនាញ, ~ card ប័ណ្ណការងារ, ~ force កំលាំងពលកម្ម, ~ laws ច្បាប់ពលកម្ម, ~ productivity ផលិតភាពនៃពលកម្ម, ~ security សន្តិសុខពលកម្ម, ~ turnover អត្រាបុគ្គលិកចេញ (ពីអង្គភាព), ~ union or trade union សហជីព
**labourer** ពលករ, day ~ ទិនិកជន, ពលករស៊ីប្រាក់ថ្ងៃ
**labour-intensive adj.** ប្រើពលកម្មច្រើន, អតិពលកម្ម, ~ industry ឧស្សាហកម្មអតិពលកម្ម
**lack** កង្វះ, ~ of balance បាត់តុល្យភាព, ~ of confidence កង្វះទំនុកចិត្ត
**lading n.** ការផ្ទុកទំនិញ, ~ port កំពង់ផែផ្ទុកទំនិញ
**laissez-passer** លិខិតបើកផ្លូវ
**land** ដី, ដីធ្លី, ~ alienation ការផ្ទេរកម្មសិទ្ធិដី, ~ conflict ទំនាស់ដីធ្លី, ~ degradation ការចុះគុណភាពដី, ការខូចដី, ~ dispute វិវាទដីធ្លី, ~ encroachment ការរំលោភយកដី, ~ grabbing ការទន្ទ្រានយកដី, ~ owner ម្ចាស់ដី, ~ ownership កម្មសិទ្ធិដីធ្លី, ~ reform កំណែទំរង់ដីធ្លី, ~ survey អង្កេតដីធ្លី, ឋានគណិត, ~ restructuring ការកែប្រែដីធ្លីឡើងវិញ, ~ settlement ដំណោះស្រាយដីធ្លី, ~ tenure ការកាន់កាប់ដី

**land dispute settlement committee** គណៈកម្មាធិការដោះស្រាយបាតុភាពដីធ្លី
**landless adj.** គ្មានដី
**landlessness** ភាពគ្មានដីធ្លី
**landlocked country** ប្រទេសគ្មានច្រកសមុទ្រ
**landlord** ម្ចាស់ ដី/ផ្ទះ (ដែលជួលឱ្យគេ)
**landscape** ទេសភាព, protected ~ តំបន់ទេសភាពការពារ
**large-scale survey** អង្កេតទ្រង់ទ្រាយធំ
**latent** មិនទាន់ជាក់ស្តែង
**launch n.** ការដាក់ចេញជាលើកដំបូងនូវ (ឧ. ផលិតផលលើទីផ្សារ)
**law** ច្បាប់, draft ~ សេចក្តីព្រាងច្បាប់, ~ of contract ច្បាប់នៃកិច្ចសន្យា
**Law on Co-Statute of Civil Servants** ច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
**Law on Financial Management** ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង
**Law on Social Security** ច្បាប់ស្តីពីរបបសន្តិសុខសង្គម
**lawful** ស្របច្បាប់
**lawless** ដែលអត់ច្បាប់ (គ្មានច្បាប់គ្រប់គ្រង រឺ គ្មានការគោរពច្បាប់)
**laws and regulations** ច្បាប់ និង បទប្បញ្ញត្តិ/លិខិតបទដ្ឋាន
**lawsuit** រឿងក្តី
**lawyer** អ្នកច្បាប់, មេធាវី
**lay in stock v.** បញ្ចូលឃ្លាំង
**lay off v.** បញ្ឈប់បុគ្គលិក
**lay out v.** ចាយ (ប្រាក់)
**layout of letter** ទំរង់/ប្លង់ សំបុត្រ
**leader** ១. អ្នកដឹកនាំ, popular ~ មេខ្យល់ ២. ផលិតផលលក់ដាច់ជាងគេ, market ~ ផលិតផល/ក្រុមហ៊ុន នាំមុខគេលើទីផ្សារ
**leading** នាំមុខគេ, ~ indicator អាំងឌីកាទ័រនាំមុខគេ (ដែលបង្ហាញនិន្នាការបានមុនអាំឌីកាទ័រឯទៀត)
**lease** ភតិសន្យា, ការជួល (ដោយមានកិច្ចសន្យា), finance ~ ភតិសន្យាហិរញ្ញវត្ថុ (ក្នុងនេះសហគ្រាសត្រូវកត់ត្រាទ្រព្យជួលពីគេក្នុងតារាងតុល្យការ និងធ្វើរំលស់វា), operating ~ ភតិសន្យាប្រតិបត្តិការ (ក្នុងនេះសហគ្រាសមិនត្រូវកត់ត្រាទ្រព្យជួលពីគេក្នុងតារាងតុល្យការទេ)
**lease v.** ជួល, ~ back ជួលមកវិញ
**least developed countries** (LDCs) ប្រទេសលូតលាស់តិចជាងគេ
**ledger** (accounting) សៀវភៅធំ, purchase ~ សៀវភៅធំទិញ
**legacy** ១. អច្ច័យទានជាចលនទ្រព្យ (តាមមរតកសាសន៏) **២.** អច្ច័យទាន (កេរ្តិ៍)
**legal** តាមច្បាប់, នីត្យានុកូល ~ capital ដើមទុនតាមច្បាប់, ~ document ឯកសារតាមច្បាប់, ~ representative អ្នកតំណាងតាមច្បាប់, ~ framework ក្របខ័ណ្ឌច្បាប់, ~ decision សេចក្តីសំរេចតាមច្បាប់, ~ reserves ធនបំរុងតាមច្បាប់
**legal effect** អានុភាពគតិយុត្តិ
**legal entity/person** នីតិបុគ្គល
**legal substance** (French: nature juridique) នីតិសារជាតិ
**legal tender** រូបិយមាត្រា, ប្រាក់ដែលច្បាប់ទទួលស្គាល់
**legality** ភាពតាមច្បាប់, នីត្យានុកូលភាព
**legalise v.** ធ្វើអោយទៅតាមច្បាប់,

ធ្វើនីត្យានុកូលកម្ម

**legatee** អច្ច័យទានលាភី ( អ្នកទទួលស្នងមរតកតាមរយៈមរតកសាសន៍ )

**legator** អច្ច័យទាយក

**legislation** ច្បាប់, នីតិកម្ម

**legislative power** ១. អំណាចនីតិបញ្ញត្តិ ( សភា ) ២. អំណាចបញ្ញត្តិ ( ស្ថាប័នផ្សេងទៀត ដូចជាក្រុមប្រឹក្សាឃុំ )

**legislative structure** រចនាសម្ព័ន្ធនីតិបញ្ញត្តិ

**legislator** អ្នកធ្វើច្បាប់, នីតិពន្ធ

**legislature** ១. អង្គនីតិបញ្ញត្តិ ( អង្គការធ្វើច្បាប់ ) ២. នីតិកាល ( នៃសភា )

**legitimate** ពេញលក្ខណៈត្រឹមត្រូវ, ពេញច្បាប់, ធម្មានុរូប

**lend v.** អោយខ្ចី

**lender** អ្នកអោយខ្ចី, ~ of last resort អ្នកឱ្យខ្ចីជាចុងក្រោយ

**lending institution** ស្ថាប័ន ឥណទាន/ ឱ្យខ្ចីប្រាក់

**lessee** ភតិកៈ, អ្នកជួល ( ពីគេ )

**lessor** ភតិបតី, អ្នកជួលអោយ

**let v.** ជួល ( ផ្ទះ, ការិយាល័យ ... )

**letter** លិខិត, covering ~ (or US: cover ~) លិខិតអមឯកសារ, ~ of attorney លិខិតផ្ទេរសិទ្ធិ, ~ of credit (L/C) លិខិតឥណទាន, ~ of exchange រូបិយាណត្តិ, ~ of indemnity លិខិតធានាសង, ~ of intent លិខិតបញ្ជាក់គោលបំណង, លិខិតស្តែងចេតនា, ~ of inquiry លិខិតសាកសួរព័ត៌មាន, ~ of non-conviction លិខិតបញ្ជាក់ថាគ្មានទោស

**level** កំរិត, multi-level ច្រើនកំរិត, ~ of development កំរិតអភិវឌ្ឍន៍

**lever** ឃ្នាស់

**leverage** គំនាស់, ការប្រើកំចីមានការប្រាក់ថេរទៅរកស៊ីដើម្បីបានចំណេញលើសពីការប្រាក់

**levy v. & n.** ១. ហូតពន្ធ ២. ពន្ធ ( ជាពិសេសពន្ធបន្ថែម )

**liabilities** បំណុល, ទ្រព្យអកម្ម, meet one’s liabilities សងបំណុលរបស់ខ្លួន

**liability** ១. បំណុល ២. ការទទួលខុសត្រូវ, ~ insurance ការធានារ៉ាប់រងលើភារៈទទួលខុសត្រូវ

**liable adj. for** ទទួលខុសត្រូវ ( តាមច្បាប់ ) ចំពោះ

**liaison** ទំនាក់ទំនង, សម្ពន្ធការ, ~ office ការិយាល័យទំនាក់ទំនង

**libel** ការសរសេរបរិហាកេរ្តិ៍

**liberal democracy and pluralism or liberal multi-party democracy** លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស

**liberal profession** វិជ្ជាជីវៈសេរី

**liberality or liberal gift** សទ្ធាទាន

**liberalisation** សេរីភាវូបនីយកម្ម, ~ of trade សេរីភាវូបនីយកម្មពាណិជ្ជកម្ម

**Libor** (London Interbank Offered Rate) អត្រាការប្រាក់រវាងធនាគារពាណិជ្ជនៅទីក្រុងឡុង

**licence** អាជ្ញាប័ណ្ណ, លិខិតអនុញ្ញាត

**licensed** មានអាជ្ញាប័ណ្ណ, ប្រតិស្រុត, ~ bank ធនាគារប្រតិស្រុត

**licensed technology** បច្ចេកវិទ្យាទិញពីគេ

**licensee** អ្នកកាន់អាជ្ញាប័ណ្ណ

**licit adj.** ត្រូវច្បាប់

**lien** ១. ប្រាតិភោគបំណុល ( វត្ថុដាក់ធានាបំណុល ) ២. សិទ្ធិឃាត់ទុក

**life expectancy** អាយុកាលមធ្យម, អាយុរស់

នៅមធ្យម
**life or death issue** បញ្ហាស្លាប់រស់
**life skill** បំណិនជីវិត
**life span** អាយុកាល (ពីពេលកើតដល់ស្លាប់)
**lifestyle** របៀបរស់នៅ
**lifetime** អាយុកាល, មួយអាយុ
**LIFO** (last in, first out) លីហ្វូ (ចូលក្រោយចេញមុន)
**likelihood** ភាពទំនង
**limit n. & v.** ១. ព្រំដែន, ~ of liability ព្រំដែននៃការទទួលខុសត្រូវ, ២. ដាក់កំរិតព្រំដែន
**limitation n.** ការដាក់កំរិតព្រំដែន
**limited liability** ការទទួលខុសត្រូវមានកំណត់, ~ company ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត
**limited partner** អ្នកចូលហ៊ុនមានកំរិត (ទទួលខុសត្រូវមានកំរិត)
**line (department)** (មន្ទីរ) ខ្សែបណ្តោយ
**line item (budget)** មាតិកា (ថវិកា)
**line of credit or credit line** កំរិតឥណទាន
**link** ចំណងទាក់ទង
**linkage** ការចងភ្ជាប់, ចំណងទាក់ទង
**liquid assets** ទ្រព្យប្តូរយកប្រាក់បានរហ័ស
**liquid investments** វិនិយោគដោយសាច់ប្រាក់
**liquidate v.** ជំរះ, ទូទាត់ (បំណុល, បញ្ជី), ~ a debt ទូទាត់បំណុលទាំងមូល
**liquidation** ការរំលាយ (ក្រុមហ៊ុន), ការជំរះបញ្ជី, compulsory ~ ការជំរះបញ្ជីជាកាតព្វកិច្ច (តាមការសំរេចរបស់តុលាការ), voluntary ~ ការជំរះបញ្ជីដោយស្ម័គ្រចិត្ត, ~ report របាយការណ៍ជំរះបញ្ជី
**liquidator** អ្នកជំរះបញ្ជី, អ្នកត្រួតពិនិត្យការបិទក្រុមហ៊ុន
**liquidity** ១. សន្ទនីយភាព, លទ្ធភាពសងបំណុល ២. សាច់ប្រាក់ទំនេរ, ~ ratio សមាភាគសាច់ប្រាក់ទំនេរ
**liquidity** (banking) សាច់ប្រាក់និងទ្រព្យងាយប្តូរជាសាច់ប្រាក់, total ~ រូបិយវត្ថុទូទៅ (M2)
**list** បញ្ជី, ~ price ថ្លៃលើបញ្ជី (កាតាឡុក), listed company ក្រុមហ៊ុនដែលមានសន្លឹកហ៊ុនលក់-ទិញ នៅផ្សារហ៊ុន
**litigation** បណ្តឹងវិវាទ, ការប្តឹងផ្តល់
**livelihood** ជីវភាព, ការរកចិញ្ចឹមជីវិត,
**lively** យ៉ាងសកម្ម, ~ market ទីផ្សារមានសកម្មភាពរស់រវើក
**livestock** សត្វចិញ្ចឹម (យកផល)
**living** ១. ជីវភាព, ការរស់នៅ, ~ standard កំរិតជីវភាព, cost of ~ ចំនាយទ្រទ្រង់ការរស់នៅ
**load factor, passenger** (air travel) អត្រាបំពេញកៅអីអ្នកដំណើរ (តាមយន្តហោះ)
**loading and unloading of goods** ការផ្ទុក និងការរើទំនិញ
**loading capacity** ចំណុះផ្ទុក
**loading port** ផែផ្ទុកទំនិញ
**loan** កំចី, ឥណទេយ្យ, បំណុល, bridging ~ កំចីផ្លាស់ផ្ទះថ្មី (នៅពេលផ្ទះចាស់លក់មិនទាន់ដាច់), soft ~ កំចីការប្រាក់ទាប, ~ at call កំចីគ្មានកាលកំណត់ (ត្រូវសងវិញពេលគេទារ), personal ~ កំចីផ្ទាល់ខ្លួន, unsecured ~ កំចីគ្មានការធានា, ~ disbursed កំចីបានបើកផ្តល់
**loan service** (interest payment) សេវាបំណុល
**lobby v.** កៀងគរ, ឃោសនាបញ្ចុះបញ្ចូល
**local** (នៃ) មូលដ្ឋាន, ក្នុងស្រុក, ~ authority អាជ្ញាធរមូលដ្ឋាន
**location** ទីតាំង
**logging** ការកាប់ឈើ, illegal ~ ការកាប់ឈើខុសច្បាប់

**logic** តក្កវិជ្ជា, ឡូស៊ិក
**logistics** ភស្តុភារ, ការផ្គត់ផ្គង់
**logo** រូបសញ្ញា
**long-life assets** ទ្រព្យអាយុកាលវែង
**long-term** រយៈពេលវែង, ទីឃកាល,
~ liabilities បំណុលរយៈពេលវែង
**loophole** ចន្លោះប្រហោង, tax ~ ចន្លោះប្រហោងនៃពន្ធ (ដែលអាចគេចៀសវាងមិនបង់ពន្ធដោយស្របច្បាប់)
**loose-leaf ledger** សៀវភៅធំសន្លឹកដាច់ពីគ្នា
**loss** កំហាត,ការខាតបង់, ការបាត់បង់, actual total ~ កំហាតសរុបជាក់ស្តែង
**lot n.** ឡូតិ៍, fishing ~ ឡូតិ៍នេសាទ
**low-income group/households** ក្រុម/គ្រួសារ មានប្រាក់ចំណូលទាប
**lump-sum** ប្រាក់បង់ទាំងដុល, ~ payment ការទូទាត់តាមរបៀបម៉ៅការ (រឺ ឆាកា)
**lump-sum tax** ពន្ធម៉ៅការ
**luxury** ប្រណិត, ~ goods ទំនិញប្រណិត,
~ trade ពាណិជ្ជកម្មវត្ថុប្រណិត

## M, m

**M1** (money) រូបិយវត្ថុ
**M2** (liquidity) រូបិយវត្ថុទូទៅ
**macro-** ម៉ាក្រូ
**macroeconomic analysis** ការវិភាគម៉ាក្រូសេដ្ឋកិច្ច
**macroeconomic stability** ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច
**macroeconomics** ម៉ាក្រូសេដ្ឋកិច្ច
**magnitude** ទំហំ
**mail transfer** ការផ្ទេរ(ប្រាក់) តាមប្រៃសនីយ៍
**mail, electronic** សារអេឡិចត្រូនិក, អ៊ីមែល
**main adj.** ចំបង
**mainstream v.** បញ្ជ្រាប
**maintain v. accounting book** កាន់កាប់បញ្ជីគណនេយ្យ
**maintenance** ការថែទាំ, ~ expenses/ costs ចំណាយថែទាំ
**major adj.** ចំបង, សំខាន់
**majority** ភាគច្រើន, សំលេងភាគច្រើន (បោះឆ្នោត)
**mala fide seller** អ្នកលក់ដែលមានល្បិចកលមិនល្អ
**maladministration** ការគ្រប់គ្រងអសមត្ថភាព
**mal-development** ការអភិវឌ្ឍន៏ខុសទំនង
**malpractice** របៀបរបបមិនល្អ, កំហុសឆ្គង
**malthusianism** និបុលនិយម, ម៉ាល់ទុសនិយម
**manage v.** គ្រប់គ្រង, ចាត់ចែង
**management** ការគ្រប់គ្រង, ~ control ការត្រួតពិនិត្យការគ្រប់គ្រង
**manager** អ្នកគ្រប់គ្រង, បណ្ណាធិការ, financial ~ អាណាប័ក
**managerial accounting** គណនេយ្យគ្រប់គ្រង
**managership** ភាពជាអ្នកគ្រប់គ្រង
**managing director** នាយកគ្រប់គ្រង
**mandate n.** ១. សិទ្ធិអំណាច ២. អាណត្តិ
**mandate v.** ១. ផ្តល់សិទ្ធិអំណាច ២. តំរូវ, the law mandates that... ច្បាប់តំរូវថា
**mandatory adj.** ដែលខានមិនបាន
**manifest** និវេទនប័ណ្ណ, បញ្ជី អ្នកដំណើរ/ ទំនិញដឹកជញ្ជូន (តាមយន្តហោះ រឺ នាវា)

**man-made disaster** មហន្តរាយបង្កដោយមនុស្ស
**manner** បែបបទ
**manual** ១. ហត្ថកម្ម ២. សៀវភៅក្បួន
**manufacture** កម្មន្តសាល
**manufactured goods** ទំនិញកម្មន្តសាល
**manufacturing** កម្មន្តសាលកម្ម, ការផលិត (យ៉ាងច្រើនៗដោយប្រើម៉ាស៊ីន)
**margin** អប្បហារ, កំរិត, ម៉ាជីន, ~ of error កំរិតល្មៀង, ~ of lending កំរិតអោយខ្ចីប្រាក់, ~ of profit កំរិតប្រាក់ចំណេញ
**marginal benefit** ផលចំណេញឯកតាបន្ថែម (ក្នុងការបង្កើនមួយឯកតាផលិតផល)
**marginal cost** ថ្លៃដើមឯកតាបន្ថែម (ដើម្បីផលិតបន្ថែមមួយឯកតាផលិតផលលើសផែនការ), បន្ទុកចំណាយម៉ាហ្ស៊ីណាល់
**marginal project** គំរោងបន្ទាប់បន្សំ
**marginal propensity to consume** កំរិតទំនោរនៃការប្រើប្រាស់បន្ថែម
**marginal propensity to save** កំរិតទំនោរនៃការសន្សំបន្ថែម
**marginal revenue** ចំណូលឯកតាបន្ថែម (ពីការលក់ផលិតផលបន្ថែមមួយឯកតា)
**marginal utility** ផលប្រយោជន៏ឯកតាបន្ថែម
**marginalisation** ម៉ាជីនូបនីយកម្ម, ការច្រានចូលស្ថានភាពគ្មានសិទ្ធិអំណាច
**marginal-tax ratio** សមាភាគកំណើនចំណូលពន្ធធៀបនឹងកំណើនផលទុនជាតិសរុប
**marine** ខាងសមុទ្រ, ~ concession ដែនសម្បទានទឹកប្រៃ, ~ fisheries នេសាទសមុទ្រ, ~ insurance ការធានារ៉ាប់រងផ្លូវសមុទ្រ
**mark down v.** បញ្ចុះថ្លៃ
**mark up v.** តំលើងថ្លៃ

**market n.** ទីផ្សារ, black ~ ផ្សារងងឹត, capital ~ ទីផ្សារទុន (សំរាប់វិនិយោគ), ~ capitalisation តំលៃក្រុមហ៊ុនគិតតាមតំលៃទីផ្សារនៃសន្លឹកហ៊ុន, closed ~ ទីផ្សារបិទ (លក់ឱ្យតែតំណាងផ្ដាច់មុខ), open ~ ទីផ្សារចំហ (គ្រប់គ្នាអាចទិញ/លក់បាន) ~ demand/need តំរូវការទីផ្សារ, ~ economy សេដ្ឋកិច្ចទីផ្សារ, ~ failure បរាជ័យនៃទីផ្សារ, ~ forces កំលាំងទីផ្សារ, money/finance ~ ទីផ្សាររូបិយវត្ថុ (កំចីរយៈពេលខ្លីៗ), ~ practice ទំលាប់ទីផ្សារ, ~ price ថ្លៃនៅទីផ្សារ, ~ saturation តិត្ថិកម្មក្នុងផ្សារ, ភាពឆ្អែតពេញដោយទំនិញនៃទីផ្សារ, ~ segmentation ការបែងចែកទីផ្សារ, ~ value តំលៃទីផ្សារ (តំលៃនៅថ្ងៃនេះ), តំលៃធានិក, ~ share/penetration ចំណែកទីផ្សារ
**market v.** លក់លើទីផ្សារ, ~ a new product លក់ផលិតផលថ្មីលើទីផ្សារ
**marketable** អាចលក់យ៉ាងងាយ
**marketing** ម៉ាឃីតទីង, ការបញ្ចេញលក់លើទីផ្សារ, ~ chain ខ្សែចង្វាក់ ម៉ាឃីទីង/ទីផ្សារ
**market-regulated economy** សេដ្ឋកិច្ចទីផ្សាររៀបរយ, សេដ្ឋកិច្ចនិយ័តទីផ្សារ
**mark-up** អប្បហារ
**marriage certificate** សំបុត្រអាពាហ៏ពិពាហ៏
**mass media** ប្រព័ន្ធផ្សព្វផ្សាយ (ព័ត៌មាន)
**mass production** ការផលិតទ្រង់ទ្រាយធំ
**master adj.** គោល, មេ, ~ budget ថវិកាមេ, ~ map ផែនទីគោល, ~ plan ផែនការ/ប្លង់គោល, ~ sample គំរូតាងមេ
**master's degree** ថ្នាក់អនុបណ្ឌិត
**matching concept/convention** គោលការណ៏នៃភាពស៊ីគ្នា

**material** សំភារៈ, ក្រណាត់
**maternal mortality rate** អត្រាមរណៈមាតុភាព
**mature** ពេញវ័យ, ចាស់ទុំ, ~ economy សេដ្ឋកិច្ចរីកចំរើនពេញលេញ
**maturity** បក្កភាព, ភាពពេញវ័យ, ភាពចាស់ទុំ, កាលវសាន, កាលកំណត់, date of ~ ថ្ងៃដល់កំណត់ (សង)
**maximisation** អតិបរមានីយកម្ម
**mayor** ចៅហ្វាយក្រុង
**mean** (statistics) មធ្យម, arithmetic ~ មធ្យមនព្វន្ត, geometric ~ មធ្យមធរណីមាត្រ
**means** មធ្យោបាយ, ~ of production មធ្យោបាយផលិតកម្ម
**measurability** ភាពអាចវាស់បាន
**measure** ១. ទំហំ, រង្វាស់ ២. វិធានការ, economic ~ វិធានការសេដ្ឋកិច្ច, fiscal ~ វិធានការសារពើពន្ធ
**measurement of profitability** ការវាស់វែងភាពមានចំណេញ
**mechanism** ១. យន្តការ ២. សេនាធិការ (ស្ថាប័ន)
**mechanisation** យន្តកម្ម, យន្តូបនីយកម្ម
**media or mass media** ប្រព័ន្ធផ្សព្វផ្សាយ
**mediation** ការសំរុះសំរួល
**mediator** អ្នកសំរុះសំរួល
**medic n.** អ្នកវេជ្ជសាស្ត្រ
**medical** (នៃ) វេជ្ជសាស្ត្រ, ~ assistant ជំនួយវេជ្ជសាស្ត្រ
**medical aid n.** អ្នកជំនួយវេជ្ជសាស្ត្រ
**medical care** (expense) (ចំណាយ)ថៃទាំសុខភាព
**medium** មធ្យម, ~ grade គុណភាពមធ្យម, ~ term loan កំចីរយៈពេលមធ្យម
**meet** ជួប, ដោះស្រាយ, បំពេញ (លក្ខខណ្ឌ), ~ a deficit បំពេញឱនភាព
**meeting** ជំនួប, ការប្រជុំ, (ប្រជុំមហាជន
**MEFP** (Memorandum of Economic and Financial Policy: for the IMF) អនុស្សារណៈស្តីពីគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
**MFN (Most Favoured Nation clause)** លក្ខខណ្ឌអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម
**membership** សមាជិកភាព
**memorandum** ជំនួយស្មារតី, អនុស្សារណៈ, ~ of association អនុស្សារណៈបង្កើតក្រុមហ៊ុន, លក្ខន្តិកៈក្រុមហ៊ុន, ~ of understanding (MOU) អនុស្សារណៈព្រមព្រៀង
**mental ability** សមត្ថភាពខាងបញ្ញា
**mental job** ការងារប្រើខួរក្បាល (ដែលត្រូវរិះគិត)
**mercantile adj.** នៃពាណិជ្ជកម្ម, ~ marine កងនាវាពាណិជ្ជកម្ម(របស់ប្រទេសណាមួយ), ~ country ប្រទេស (មានចំណូលដោយការធ្វើ) ពាណិជ្ជកម្ម
**mercantilism** ពាណិជ្ជកម្មនិយម
**merchandising service establishment** គ្រឹះស្ថានសេវាកម្មទំនិញ
**merchant** ពាណិជ្ជករ
**merger** ការរំលាយបញ្ចូលគ្នា (នូវក្រុមហ៊ុនពីរ រឺច្រើន ជាក្រុមហ៊ុនមួយ)
**merit** កុសល, កុសលកិច្ច, គុណសម្បត្តិ
**message** សារ
**messenger** នារសារ, លេខហារី

**method** វិធី
**methodology** វិធីសាស្ត្រ
**micro biology** មីក្រូជីវៈ
**microcosm** អតិសុខុមលោក
**micro-credit** មីក្រូឥណទាន
**microeconomics** មីក្រូសេដ្ឋកិច្ច
**micro-finance** មីក្រូហិរញ្ញវត្ថុ
**middle class** វណ្ណៈកណ្ដាល (រឺ វណ្ណៈគហបតី)
**middleman** ឈ្មួញកណ្ដាល, គួកជេ, ជើងសារ/អន្តរការី
**migrant** ជនចំណាកស្រុក, និរប្រវេសន៍
**migrate v. from/to** ធ្វើចំណាកស្រុក រឺ ចាកស្រុក ពី/ទៅ
**migration** ចំណាកស្រុក, ពហិប្រវេសន៍, សន្តរប្រវេសន៍
**milestone** ១. គោល (ប្រាប់ចំងាយ) ២. ព្រឹត្តិការណ៍សំខាន់ (ក្នុងដំណើរការវិវត្តន៍នៃអ្វីមួយ)
**milieu** មជ្ឈដ្ឋាន
**military** យោធា, យោធិន, ~ region យោធភូមិភាគ
**Millennium Development Goals** (MDGs) គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍
**mineral concentrate** រ៉ែចំរាញ់
**minicomputer** កំព្យូទ័រធុនតូច
**minimisation** អប្បបរមាភាវូបនីយកម្ម, tax ~ ការធ្វើឱ្យបន្ទុកពន្ធថយចុះទាបបំផុត
**minimise v.** បន្ថយដល់កំរិតអប្បបរមា
**mining** អាជីវកម្មរ៉ែ, ការយករ៉ែ
**minor adj. & n.** ១. តូចតាច, បន្ទាប់បន្សំ ២. អនីតិជន
**minority** ភាគតិច, អប្បភាគ
**misappropriation of public funds** វិតិកម្មធនសាធារណៈ, ការកេងប្រវ័ញ្ចទ្រព្យសម្បត្តិសាធារណៈ
**miscalculate v.** គណនាខុស
**miscellaneous** ផ្សេងៗ, គណនីចំណាយ "ផ្សេងៗ"
**misdemeanour** បទមជ្ឈិម (កំរិតទាបជាងបទឧក្រិដ្ឋ)
**mission** បេសកកម្ម, ~ letter លិខិតបញ្ជាបេសកកម្ម, ~ statement សេចក្ដីប្រកាសបេសកកម្ម
**misunderstanding** ការយល់ច្រឡំ, ការយល់ខុស
**mixed economic entity** អង្គភាពសេដ្ឋកិច្ចចំរុះ
**mobilisation of private savings** ការកេណ្ឌប្រមូលប្រាក់សន្សំឯកជន
**mobilise v.** កេណ្ឌប្រមូល, ប្រមែប្រមូល
**modality of investment** បែបបទនៃការវិនិយោគ
**mode n.** ម៉ូដ, របៀប
**model n.** គំរូ
**moderate adj. & n.** ១. ល្មម (ឧ. មិនថោក មិនថ្លៃ) ២. មជ្ឈនិកជន
**modernisation** ទំនើបភាវូបនីយកម្ម, ទំនើបកម្ម
**modernise** ធ្វើទំនើបកម្ម
**modification** ការកែប្រែ, កំណែប្រែ
**module** ម៉ូឌុល
**modus operandi** បែបបទប្រតិបត្តិការ
**momentum** សន្ទុះជឿនទៅមុខ, កំលាំងរុញច្រាន, ម៉ូម៉ង់
**monetarism** រូបិយវត្ថុនិយម
**monetarisation of the deficit** រូបិយវត្ថុនីយកម្មនៃឱនភាព
**monetary adj.** នៃ រូបិយវត្ថុ/លុយ, ~ policy នយោបាយរូបិយវត្ថុ, ~ overhang រូបិយវត្ថុលើសតុល្យភាព, ~ confidence ទំនុកចិត្តលើរូបិយវត្ថុ,

~ stabilisation ស្ថិរកម្ម/ស្ថិរភាវូនីយកម្មរូបិយវត្ថុ, ~ transaction ប្រតិបត្តិការគិតជា លុយ/រូបិយវត្ថុ

**money** រូបិយវត្ថុ, លុយ, ~ (M1) រូបិយវត្ថុ (M1), ~ (M2) រូបិយវត្ថុទូទៅ (M2), quasi- ~ រូបិយវត្ថុផ្សេងៗ, ~ in circulation រូបិយវត្ថុចរាចរ, ~ economy សេដ្ឋកិច្ចរូបិយវត្ថុ, ~ laundering ការលាងលុយកខ្វក់, ~ market ទីផ្សាររូបិយវត្ថុ (កំចីរយៈពេល ខ្លីៗ), ~ supply ការផ្គត់ផ្គង់រូបិយវត្ថុ/សាច់ប្រាក់, ~/funds at call រូបិយវត្ថុ/មូលនិធិដែលអាចផ្តល់អោយបានភ្លាមៗ

**moneylender** ឥណទាយក, អ្នករកស៊ីចងការប្រាក់

**monitor v.** ឃ្លាំមើល (ឯកសារខ្លះប្រើពាក្យ *តាមដាន*)

**monoculture** ឯកវប្បកម្ម, ធ្វើដំណាំមួយមុខ

**monopolise v.** ធ្វើផ្តាច់មុខ

**monopoly n.** ភាពផ្តាច់មុខ, monopolistic adj.

**monthly** ប្រចាំខែ, ~ statement របាយការណ៏/សំរង់គណនី ប្រចាំខែ, ~ returns ចំណូលប្រចាំខែ

**moral obligation** កាតព្វកិច្ចផ្លូវចិត្ត

**morality** សីលធម៌, good ~ មានសីលធម៌ល្អ, social ~ សីលធម៌សង្គម

**morbidity** ភាពមានជំងឺធ្វើអោយស្លាប់

**mortgage** និក្ខេប, អ៊ីប៉ូតែក, វត្ថុបញ្ចាំបំណុល

**mortgagee** ម្ចាស់បំណុលអ៊ីប៉ូតែក, និក្ខេបគាហក

**mortgager/mortgagor** កូនបំណុលអ៊ីប៉ូតែក

**most favoured nation** (MFN) **clause** លក្ខខណ្ឌអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម

**motion of censure** ញត្តិបន្ទោស

**motivate v.** ជំរុញទឹកចិត្ត, បំផុសទឹកចិត្ត

**movable** (property) ចលនវត្ថុ

**multi-disciplinary team** ក្រុមពហុជំនាញ

**multilateral** ពហុភាគី, ~ agreement កិច្ចព្រមព្រៀងពហុភាគី, ~ aid/assistance ជំនួយពហុភាគី

**multinational** ពហុជាតិ, ~ corporation ក្រុមហ៊ុនពហុជាតិ

**multiple-shop undertakings** ក្រុមហ៊ុនមានសាខាច្រើន

**multiplier** មេគុណ

**multi-purpose allocation** ការបែងចែកសំរាប់គោលដៅច្រើនយ៉ាង

**multi-stage** ច្រើនដំណាក់, ~ design ប្លង់ច្រើនដំណាក់, ~ frame គ្រោងច្រើនដំណាក់, ~ sampling ការយកគំរូតាងច្រើនដំណាក់

**mutation n.** រូបវិវត្តន៏

**mutatis mutandis** ដែលត្រូវផ្លាស់ប្តូរតាមការចាំបាច់

**mutual** ទៅវិញទៅមក, ~ assistance ការជួយគ្នាទៅវិញទៅមក, ~ insurance ការធានារ៉ាប់រងទៅវិញទៅមក, ~ benefit មានផលប្រយោជន៏ទៅវិញទៅមក,

**mutual fund** សង្គហធន

**mutual societies** សង្គហសមាគម

**mutually supportive** ជួយទ្រទ្រង់គ្នាទៅវិញទៅមក

## N, n

**nascent economy** សេដ្ឋកិច្ចកំពុងចាប់កំណើត

**nation** ប្រជាជាតិ, សង្គមជាតិ

**national** នៃជាតិ, ~ accounting គណនេយ្យជាតិ, ~ budget support ឧបត្ថម្ភពីថវិការដ្ឋ (ឧ. ចំពោះថវិកាខេត្ត), ~ bank ធនាគារជាតិ,

~ debt បំណុលជាតិ (ខ្ចីដោយរដ្ឋាភិបាល), ~ income ផលទុនជាតិ, ~ Institute of Statistics វិជ្ជាស្ថានជាតិស្ថិតិ, ~ patrimony បេតិកភ័ណ្ឌជាតិ, ~ product ផលិតផលជាតិ, ~ economic management ការគ្រប់គ្រងសេដ្ឋកិច្ចជាតិ

**nationality** សញ្ជាតិ, ~ of ships សញ្ជាតិនាវា

**nationalise v.** ធ្វើជាតូបនីយកម្ម, ធ្វើជាតិកម្ម

**nationwide** ទូទាំងប្រទេស

**natural** នៃធម្មជាតិ, ~ condition លក្ខខណ្ឌធម្មជាតិ, ~ asset ទ្រព្យសម្បត្តិធម្មជាតិ (ធនធានធម្មជាតិអ្វីមួយ), ~ disaster គ្រោះ/មហន្តរាយធម្មជាតិ, ~ unemployment rate អត្រានិកម្មភាពធម្មជាតិ, ~ resource ធនធានធម្មជាតិ, ~ loss ការបាត់បង់ ឯកឯង/ដោយធម្មជាតិ

**nature ១.** ធម្មជាតិ **២.** ចរិតលក្ខណៈ (របស់មនុស្ស)

**near-liquid asset or near money** ទ្រព្យជិតដូចរូបិយវត្ថុ (ទ្រព្យសកម្មដែលអាចប្តូរជារូបិយវត្ថុបានយ៉ាងងាយ)

**need** តំរូវការ, ~ for affiliation តំរូវការដើម្បីចងសម្ព័ន្ធ

**needs** តំរូវការ (ចាំបាច់ជាមូលដ្ឋាន), ~ assessment study ការវាយតំលៃពីតំរូវការ

**negation** អវិជ្ជមានកម្ម

**negative adj.** អវិជ្ជមាន, ~ interest ការប្រាក់អវិជ្ជមាន (អត្រាការប្រាក់ទាបជាងអត្រាអតិផរណា)

**negligence** ការធ្វេសប្រហែស, gross ~ ការធ្វេសប្រហែសធ្ងន់ធ្ងរ

**negotiable adj.** ១.អាចចរចាបាន, ~ price ថ្លៃអាចចរចាបាន ២.អាចជួញដូរបាន, ~ debt instrument រូបិយាណត្តិឥណទេយ្យអាចជួញដូរបាន, ~ documents ឯកសារយកទូទាត់បាន, ~ instrument ឧបករណ៍ទូទាត់

**negotiate v.** ចរចា, negotiation n.

**neocolonialism** អាណានិគមនិយមបែបថ្មី

**net** សុទ្ធ, សជ្ឈត្តិករ, ~ exports ការនាំចេញសុទ្ធ, ~ cost តំលៃ សុទ្ធ/សជ្ឈត្តិករ, ~ foreign assets ទ្រព្យសកម្មបរទេសសុទ្ធ, ~ foreign current transfer (NFCT) ការផ្ទេរបរទេសចរន្តសុទ្ធ, ~ foreign factor income (NFFI) កត្តាផលទុនបរទេសសុទ្ធ, ~ income ចំណូលសុទ្ធ, ~ indirect taxes (NIT) ពន្ធប្រយោលសុទ្ធ, ~ national product ផលទុនជាតិសុទ្ធ, ~ profit ប្រាក់ចំនេញសុទ្ធ, ~ present value (NPV) តំលៃបច្ចុប្បន្នសុទ្ធ, ~ taxable income ចំនូលជាប់ពន្ធសុទ្ធ, ~ worth មូលនិធិផ្ទាល់សុទ្ធ, តំលៃពិតទ្រព្យសកម្មសុទ្ធ (ទ្រព្យសកម្មគិតតាមតំលៃពិតនៅទីផ្សារ ហើយដកបំណុលចរន្ត)

**network** បណ្តាញ

**neutralisation** អព្យាក្រឹតភាវូបនីយកម្ម, អព្យាក្រឹតកម្ម

**new international economic order (NIEO)** លំដាប់សេដ្ឋកិច្ចអន្តរជាតិថ្មី

**newly** ថ្មីៗ, ~ industrialised countries (NICs) ប្រទេសធ្វើឧស្សាហូបនីយកម្មថ្មី

**newsletter** ព្រឹត្តិប័ត្រព័ត៌មាន

**next of kin** ញាតិជិតជាងគេ

**NGO (non-government organisation)** អង្គការមិនមែនរដ្ឋាភិបាល

**nine years basic education** ការអប់រំមូលដ្ឋានរយៈពេល ៩ឆ្នាំ

**nobility** វណ្ណៈអភិជន

**nomenclature** នាមវលី (មាតិកា), មុខទំនិញ

**nominal** ចារឹក, ~ GNP ផលិតផលជាតិសរុប

ចារឹក, ~ rate of interest អត្រាការប្រាក់ ចារឹក, ~ value តំលៃចារឹក
**nomination** ការតែងតាំង
**nominee** អ្នកទទួលការតែងតាំង, ~ account គណនីកាន់កាប់ក្នុងនាមបុគ្គលម្នាក់ទៀត
**non-commercial bank** ធនាគារអពាណិជ្ជ
**non-agricultural or non-farm employment** ការងារមិនមែនកសិកម្ម
**non-aligned movement** ចលនាមិនចូលបក្សសម្ព័ន្ធ
**non-compliance** ការមិនប្រតិបត្តិតាម, ភាពមិនស្របតាម
**non-concessional adj.** មិនផ្តល់សម្បទាន
**non-convertible currency** រូបិយវត្ថុមិនអាចប្តូរ (យករូបិយវត្ថុដទៃ) បាន
**non-delivery** ការមិនប្រគល់
**non-discriminatory adj.** មិនរើសអើង
**non-durables** ទំនិញមិនគង់យូរ (អាហារ, សារព័ត៌មាន...)
**non-food items** ទំនិញមិនមែនអាហារ
**non-government organisation** (NGO) អង្គការមិនមែនរដ្ឋាភិបាល
**non-household sector** វិស័យមិនទាក់ទងនឹងគ្រួសារ
**non-negotiable instrument** ឧបករណ៍មិនអាចយកទៅទូទាត់បាន
**non-payment** ការមិនទូទាត់
**non-performance** ការមិនអនុវត្តន៍, ការគ្មានលទ្ធផល
**non-performing loan** កំចីពិបាកទារ
**non-refundable adj.** ដែលមិនបង្វិលសងវិញ
**non-resident** អនិវាសនជនរឹ អនិវាសជន
**non-returnable packing** សំបកវេចខ្ចប់មិនប្រមូលវិញ
**non-tax features** លក្ខណៈមិនទាក់ទងនឹងពន្ធដារ
**non-taxable adj.** មិនជាប់ពន្ធ, ~ income ចំណូលមិនជាប់ពន្ធ
**non-timber forest products** (NTFPs) អនុផលព្រៃឈើ
**non-urban population** ប្រជាជនមិនមែនអ្នកទីក្រុង
**norm** បទដ្ឋាន
**normalisation** ប្រក្រតីភាពកម្ម, បកតិកម្ម, និយ័តកម្ម
**North, the** (countries) ឧត្តរប្រទេស (ប្រទេសអ្នកមាន)
**notarial deed** លិខិតវិញ្ញាបនកម្ម
**notary public** សារការី
**note** សារខ្លីៗ, លិខិត, កំណត់សំគាល់, advice ~ លិខិតជូនដំណឹង, bank/currency ~ ក្រដាសប្រាក់, covering ~ លិខិតអម, credit/debit ~ លិខិតឥណទាន/ឥណពន្ធ, delivery ~ លិខិតប្រគល់ទំនិញ, dispatch ~ លិខិតបញ្ជូនទំនិញ, promissory ~ ប័ណ្ណជំពាក់ប្រាក់, ប័ណ្ណសន្យា
**noticeable change** ការប្រែប្រួលគួរឱ្យកត់សំគាល់
**notification** ការជូនដំណឹង, ~ procedure នីតិវិធីជូនដំណឹង
**notifying bank** ធនាគារជូនដំណឹង
**notion** សញ្ញាណ
**novation** កិច្ចព្រមព្រៀងផ្ទេរកិច្ចសន្យា (ឱ្យភាគីទី៣)

**novelty adj. & n.** ភាព/របស់ ថ្មីប្លែក
**NPRS** (National Poverty Reduction Strategy) យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ
**nuclear-family structures** រចនាសម្ព័ន្ធគ្រួសារស្នូល (ឪពុកម្តាយនិងកូន)
**null and void** មោឃៈ
**nullification** មោឃកម្ម, nullify v. ធ្វើឱ្យទៅជាមោឃៈ
**nullity** មោឃភាព
**numeracy** ការចេះលេខ
**numerator** (fraction) ភាគយក
**nutrition** អាហារូបត្ថម្ភ

## O, o

**obedience** ការស្តាប់ឱវាទ
**object to v.** ជំទាស់, ប្រឆាំង
**objection, have no** គ្មានការយល់ទាស់
**objective n. & adj.** ១. កម្មវត្ថុ, ទិសដៅ ២. សត្យានុម័ត, ដែលឈរលើការពិតជាក់ស្តែង
**objectivity** កម្មវិស័យភាព
**obligation** កាតព្វកិច្ច, be under ~ មានកាតព្វកិច្ច, meet one's obligations សងបំណុលរបស់ខ្លួន
**obligatory** ជាកាតព្វកិច្ច, ខានមិនបាន
**observation** ១. ការសង្កេត (មើល) ២. សេចក្តីសង្កេត (ការកត់សំគាល់)
**observe v.** សង្កេត
**observer** អ្នកសង្កេតការណ៍
**obsolescence** ភាពហួសសម័យ
**obsolete** ហួសសម័យ
**occupation** ១. មុខរបរ ២. ការកាន់កាប់
**occupancy rate** (hotel) អត្រាស្នាក់នៅ (សណ្ឋាគារ)
**occupational accident** គ្រោះថ្នាក់នៅពេលបំពេញការងារ
**occupier** អ្នកកាន់កាប់
**oceanography** សាគរសាស្ត្រ
**odd job** ការងារល្អិតល្អោច
**odd number** លេខសេស
**offence** បទល្មើស, ទោសកម្ម
**offer** ១. ការអោយថ្លៃ, cash ~ ការសុំបង់ជាសាច់ប្រាក់ ២. ការប្រកាសលក់ (ក្នុងថ្លៃណាមួយ), introductory ~ ថ្លៃទាក់ម៉ូយ (ចំពោះផលិតផលថ្មី), special ~ ទំនិញលក់ថោកពិសេស
**offer and demand** ការផ្តល់និងតំរូវការ
**off-farm employment** ការងារក្រៅកសិដ្ឋាន
**officer** មន្ត្រី
**official** ផ្លូវការ, ~ confirmation សេចក្តីបញ្ជាក់ជាផ្លូវការ, ~ rate អត្រាផ្លូវការ
**Official Gazette** រាជកិច្ច (សៀវភៅ)
**official n.** មន្ត្រីផ្លូវការ, អ្នកផ្លូវការ
**officialdom** ការិយាធិបតេយ្យ
**offload v.** ជំរុះចេញ (ទូវអ្វីមួយដែលខ្លួនមិនចង់ទុក ឧ. សន្លឹកហ៊ុនលើសតំរូវការ)
**offset v.** ប៉ះប៉ូវវិញ, កាត់កងវិញ
**offshore adj.** ក្រៅឆ្នេរ (ប្រេងកាត)
**off-the-job training** ការបណ្តុះបណ្តាលដាច់ពីការងារ
**ombudsman** មន្ត្រីស៊ើបអង្កេតពីការតវ៉ា (ចំពោះស្ថាប័នរដ្ឋ ឬអង្គការធំៗ)

**omission** ១. ការខកខាន (មិនបានធ្វើ) ២. ការកាត់ចេញ ៣. អ្វីដែល មិនបានធ្វើ រឺ កាត់ចេញ

**omnibus adj.** ចំរុះមុខ, ~ agreement កិច្ចព្រមព្រៀងចំរុះមុខ, ~ bill of lading អញ្ញតប័ត្ររួម

**on an equal footing** ដោយស្មើភាពនិងស្មើសិទ្ធិ

**on the path of reform** លើមាគ៌ានៃកំណែទំរង់

**onerous adj.** អស់សោហ៊ុយច្រើន

**one-stop service** សេវាច្រកចេញចូលតែមួយ

**ongoing activity** សកម្មភាពកំពុង ដំណើរការ/ប្រព្រឹត្តទៅ

**on-the-job training** ការបណ្តុះបណ្តាលភ្ជាប់នឹងការងារ

**open adj.** ចំហ, ~ economy សេដ្ឋកិច្ចបើកចំហ, ~ account គណនីចំហ (កត់ត្រាការទិញជឿដោយអ្នកទិញគ្មានដាក់វត្ថុធានា)

**open balance** សមតុល្យមានលេខ (មិនសូន្យ)

**open cheque** មូលប្បទានប័ត្រគ្មានឆូត (ឬចំហ)

**open credit** ឥណទានគ្មានដាក់វត្ថុធានា (សំរាប់អតិថិជនល្អរបស់ធនាគារ)

**open market** ផ្សារចំហ, ផ្សារសេរី, ~ operations ប្រតិបត្តិការលើផ្សារចំហ

**open policy** គោលនយោបាយបើកទូលាយ

**open the trade sector v.** បើកទូលាយវិស័យពាណិជ្ជកម្ម

**opening balance** សមតុល្យដើមគ្រា

**opening bank** (for letters of credit) ធនាគារបើកសារឥណទាន

**operating budget** ថវិកាប្រតិបត្តិការ

**operating costs/expenses** បន្ទុកចំណាយប្រតិបត្តិការធម្មតា

**operation** ប្រតិបត្តិការ, insurance ~ ប្រតិបត្តិការធានារ៉ាប់រង

**operational costs** បន្ទុកចំណាយប្រតិបត្តិការ

**operative system** ប្រព័ន្ធប្រតិបត្តិការ

**operator** ប្រតិបត្តិករ

**opinion** យោបល់, មតិ, ~ poll ការស្ទង់មតិ

**opportunity** កាលានុវត្តិភាព, ឱកាស

**opportunity cost** តំលៃឱកាសត្រូវបាត់បង់, តំលៃនៃការលះបង់

**opposition** ១. ការប្រឆាំង រឺ ជំទាស់ ២. បក្សប្រឆាំង

**optical fiber cable** ខ្សែកាបអុបទិច

**optimal allocation** ការលៃចែកប្រសើរបំផុត

**optimism** សុទិដ្ឋិនិយម

**optimistic estimate** ការប៉ាន់ស្មានសុទិដ្ឋិ

**optimise v.** ធ្វើអោយបានប្រសើរ (បំផុត)

**option** ជំរើស, at your ~ តាមជំរើសរបស់អ្នក, share ~ សិទ្ធិទិញភាគហ៊ុន (ក្នុងថ្លៃណាមួយនៅពេលណាមួយ) នាអនាគត

**oral agreement/contract** កិច្ចព្រមព្រៀង/ កិច្ចសន្យាផ្ទាល់មាត់ (មិនមែនជាលាយលក្ខណ៍អក្សរ)

**order** ១. បញ្ជា, provincial/municipal ~ ដីកាខេត្ត/ក្រុង, ២. លំដាប់ ៣. សណ្តាប់ធ្នាប់, public ~ សណ្តាប់ធ្នាប់សាធារណៈ

**order for payment (French: mandat de dépense)** អាណត្តិបើកប្រាក់ចំណាយ

**order form/slip** ប័ណ្ណបញ្ជាទិញ

**order, purchase** ប័ណ្ណ/ការ បញ្ជាទិញ

**ordinary share** ភាគហ៊ុនសាមញ្ញ

**ordnance** យុទ្ធភ័ណ្ឌ, unexploded ~

យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
**organic agriculture** កសិកម្មសរីរាង្គ
**organic/organisational law** ច្បាប់រៀបចំអង្គការ
**organisation chart** អង្គការលេខ
**organisational structure** រចនាសម្ព័ន្ធចាត់តាំង
**Organisation for Economic Cooperation and Development** (OECD) អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍
**orientation** ការតំរង់ទិស
**oriented** (orientated) តំរង់ទៅរក, សំដៅ, មាននិន្នាការទៅរក
**origin** ប្រភពដើម, ដើមកំណើត, ឫសគល់, certificate of ~ វិញ្ញាបនប័ត្រប្រភពដើម ទំនិញ, country of ~ ប្រទេសប្រភពដើម
**origin, zero point** គល់អ័ក្ស
**original cost** តំលៃនៅពេលចូល (តំលៃសំភារៈពេលទិញចូល)
**original invoice** វិក្កយបត្រដើម
**originating bank** ធនាគារបើកសារឥណទាន
**orthodox policy** គោលនយោបាយសម្មាមតិ (ស្របតាមការជំនឿ/មតិជាទូទៅ)
**outcome** លទ្ធផល
**outdated, out-of-date** ហួសសម័យ
**outflow** លំហូរចេញ
**outgoing letters** លិខិតចេញ
**outgoings** ចំណាយ
**outlays** (financial) ចំណាយ, debt amortisation ~ ចំណាយរំលស់បំណុល
**outlet** កន្លែងលក់ចេញ
**outlook** ទស្សនវិស័យ, ការប្រមើលមើលអនាគត
**output** ធាតុចេញ, ផលិតផល, final ~ ធាតុចេញ សំរេច/ចុងក្រោយ
**output tax or VAT** (value added tax) អាករលើតំលៃបន្ថែម
**outreach** ការឈោងដល់, ការឈានដល់
**outsource v.** ចុះកិច្ចសន្យាខាងក្រៅ
**outstanding adj.** នៅជំពាក់, ~ balance សមតុល្យនៅជំពាក់, ~ cheque មូលប្បទានប័ត្រមិនទាន់សងប្រាក់, ~ loans កំចីនៅជំពាក់ ~ student សិស្សពូកែ
**outstanding obligations** (debt) បំណុលហួសកាលបរិច្ឆេទ
**outward-looking country** ប្រទេសបើកចំហ (ឆ្ពោះទៅខាងក្រៅ)
**overcapacity** សមត្ថភាពលើស (តំរូវការផលិត)
**overcharge** កំរៃយកលើស (លើសកំរិតសមរម្យ)
**overcontrol** ការត្រួតពិនិត្យហួស
**overdraft** ១. ការដកប្រាក់លើសប្រាក់បញ្ញើ ២. ឥណទានកំណត់, ឥណទានលើសសមតុល្យ (ធនាគារ)
**overdraft, to grant an** អនុញ្ញាតឥណទានលើសសមតុល្យ
**overdue** ហួសកាលកំណត់សង, ~ bill លិខិតទារប្រាក់ហួសកាលកំណត់, ~ loans ប្រាក់កំចីហួសកាលកំណត់សង, ~ payment ការសងប្រាក់ហួសកាលកំណត់សង
**overfishing** ការនេសាទត្រីហួសប្រមាណ
**overheads or overhead expenses/costs** ចំណាយ ប្រយោល/ទូទៅ (ចំណាយទៀងទាត់ និងសំខាន់ៗ ដូចជា ឈ្នួលផ្ទះ, ទូរស័ព្ទ, សំភារៈការិយាល័យ... ដែលមិនទាក់ទងដោយផ្ទាល់នឹងការផលិត)

**overheated economy** សេដ្ឋកិច្ចរត់ក្តៅពេក (កំណើនសកម្មភាពសេដ្ឋកិច្ចដែលធ្វើឱ្យមានកំណើនអតិផរណា)
**overlap** ត្រួតគ្នា, គងគ្នា
**overlook** មើលរំលង
**overpopulation** ប្រជាជនច្រើនហួស
**overproduction** បរិផលិតកម្ម, ការផលិតលើស
**overriding** (in law) សំខាន់ជាងអ្វីឯទៀត
**over-sampling** ការយកគំរូតាងលើស
**overseas adj.** នៅបរទេស, ~ branches សាខានៅបរទេស
**oversight** ១. ការប្រហែសភ្លេចភ្លាំង ២. ការមើលខុសត្រូវលើ, ការទទួលបន្ទុក
**overspending** ចំណាយហួសកំណត់
**overstaffed** ដែលមានបុគ្គលិកច្រើនហួស
**overtime, work v.** ធ្វើការម៉ោងបន្ថែម
**overview** ការពិនិត្យជាទូទៅ, ទស្សនៈរួម
**overwhelming majority** ភាគច្រើនលើសលប់
**owner** ម្ចាស់, ម្ចាស់កម្មសិទ្ធិ, កម្មសិទ្ធិករ, ~ of the goods ម្ចាស់ទំនិញ
**ownership** កម្មសិទ្ធិ, ភាពជាម្ចាស់

## P, p

**package** កញ្ចប់, ~ budget កញ្ចប់ថវិកា, pay/salary ~ កញ្ចប់បៀវត្សរ៍ (បៀវត្សរ៍ និងប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់ការងារអ្វីមួយ) ~ tour កញ្ចប់ខ្សែទស្សនកិច្ច
**packaging** (accounting) សំបកវេចខ្ចប់
**packing list** បញ្ជីវេចខ្ចប់ (បញ្ជីបញ្ជាក់ការវេចខ្ចប់ទំនិញ)
**packing, non-returnable** សំបកវេចខ្ចប់មិនប្រមូលយកវិញ
**pact** កតិកាសញ្ញា (កិច្ចព្រមព្រៀងជាផ្លូវការ)
**paddy** ស្រូវ, ~ husking ការកិនស្រូវ, ~ plots អំពកស្រែ
**paid holidays** ថ្ងៃឈប់សំរាកមានបៀវត្សរ៍
**paid-up capital** មូលធនបានបង់ជំរះ (ដើមទុនដែលបានបង់ហើយ)
**panel of experts** គណៈជំនាញការ
**panic** ការភ័យផ្អើល, អហេតុភ័យ, financial ~ អហេតុភ័យហិរញ្ញវត្ថុ
**paper loss/profit** ចំណេញ/ខាត លើក្រដាស (ទ្រព្យបានចុះ/កើនតំលៃប៉ុន្តែមិនទាន់បានលក់ចេញទេ)
**paper money** លុយក្រដាស, ក្រដាសប្រាក់
**paperwork** ការងារក្រដាសស្នាម
**par value** តំលៃចុះលើប័ណ្ណ (រឺ តំលៃចារឹក)
**paradox** បរមតិ, ប្រតិមតិ
**paradoxically** ដែលប្រទាំងប្រទើសផ្ទៃក្នុង
**paramedic n.** អ្នកអមវេជ្ជសាស្ត្រ
**paramedical adj.** អមវេជ្ជសាស្ត្រ
**parameter** ប៉ារ៉ាម៉ែត្រ
**pare the budget v.** បន្ថយថវិកាបន្តិចម្តងៗ
**parent company** ក្រុមហ៊ុនមេ
**park** ឧទ្យាន, national ~ ឧទ្យានជាតិ
**partiality n.** ភាពលំអៀង (ក្នុងការជួយគាំទ្រ)
**participant n.** អ្នកចូលរួម
**participate v.** ចូលរួម
**participation** ១. ការចូលរួម ២. ភាគកម្ម (ការបណ្តាក់ទុន)

**participatory poverty assessment** (PPA) ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម
**participatory rural appraisal** (PRA) ការវាយតំលៃជនបទដោយមានការចូលរួម
**partner** ដៃគូ, សមាគត, អ្នកចូលហ៊ុន
**partnership** ១. ភាពជាដៃគូ ២. ជំនួញហ៊ុនគ្នា
**part-time work** ការងារមិនពេញម៉ោង
**party (to the contract)** ភាគី (នៃកិច្ចសន្យា)
**pass the test** (education) ធ្វើតេស្តជាប់
**passbook** សៀវភៅប្រាក់បញ្ញើ
**passive adj.** អកម្ម
**passport** លិខិតឆ្លងដែន
**past-due debt** បំណុលហួស កាលកំណត់/ថ្ងៃកំណត់សង
**patent** ប្រកាសនីយប័ត្រ (អនុញ្ញាតអោយប្រកបអាជីវកម្ម), ប៉ាតង់, ~ licence ប័ណ្ណប៉ាតង់
**patrimony** បេតិកភ័ណ្ឌ, ទ្រព្យសម្បត្តិ, កេរ្តិ៍មរតក (ដែលមានជាប់តមកពីខាងឪពុក)
**patron** អ្នកឧបត្ថម្ភ, មេកើយ, បរិបាល
**pattern** លំនាំ, គំរូ, trading ~ លំនាំធ្វើពាណិជ្ជកម្ម, ~ of rotation លំនាំវិលផ្លាស់ប្តូរគ្នា
**pawn v.** បញ្ចាំ
**pawnbroker** កុងស៊ី (បញ្ចាំ)
**pay as you earn** (PAYE) ប្រព័ន្ធពន្ធកាត់ទុកលើប្រាក់បៀវត្សរ៍
**pay at sight** សងប្រាក់ពេលបង្ហាញឯកសារ
**pay back v.** សងវិញ
**pay n.** បៀវត្សរ៍, ប្រាក់កំរៃ, holidays with ~ ថ្ងៃឈប់សំរាកមានបៀវត្សរ៍, leave without ~ ការឈប់សំរាកគ្មានបៀវត្សរ៍
**pay off v.** ១. ទូទាត់/បង់ ផ្តាច់ ២. ទូទាត់ប្រាក់ផ្តាច់ និងបញ្ចប់ការងារអ្នកណាម្នាក់
**pay out v.** ទូទាត់/បង់ ប្រាក់ចេញ
**pay up v.** ទូទាត់សងប្រាក់ជំពាក់គេ
**payable adj.** សងបាន, ~ to bearer សងអោយអ្នកកាន់, ~ to order សងតាមបញ្ជា
**payback period** ១. រយះពេលត្រូវសងកំចីវិញ ២. រយះពេល ប្រមូលទុនបានវិញ/ស្រង់ដើម (បានចំណេញស្មើទុនដាក់ចុះ)
**payee** អ្នកត្រូវបានបង់ប្រាក់ឱ្យ
**payer** អ្នកបង់ប្រាក់(ឱ្យគេ)
**paying bank** ធនាគារទូទាត់
**paying business** អាជីវកម្ម/ជំនួញ ដែលផ្តល់ចំណេញ
**payment** ការទូទាត់, ការបង់ប្រាក់, ការសងប្រាក់, ~ by instalments ការសងបណ្តាក់ (ឧ. តាមខែ), ~ credit ឥណទានទូទាត់, ~ currency រូបិយវត្ថុទូទាត់, ~ in kind ការទូទាត់ជាវត្ថុ, ~ systems ប្រព័ន្ធទូទាត់, ~ mechanism យន្តការទូទាត់, ~ warrant អាណត្តិបើកប្រាក់
**payoff n.** ប្រាក់បង់ផ្តាច់
**payout n.** ១. ប្រាក់ទូទាត់ចេញ ២. ប្រាក់បង់ជួយក្រុមហ៊ុនណាមួយ (ឧ. ដោយរដ្ឋាភិបាល)
**payroll** បញ្ជី/តារាង បៀវត្សរ៍
**peace building** ការកសាងសន្តិភាព
**pecuniary** ទាក់ទងនឹងប្រាក់កាស, ~ motives ហេតុផលខាងលុយកាក់
**penalise v.** ពិន័យ, ដាក់ទោស
**penalty** ទោសទ័ណ្ឌ, ទោសបញ្ញត្តិ, ការផាកពិន័យ
**pending accounts** គណនីព្យួរ (រង់ចាំការដោះស្រាយ)
**pension** សោធននិវត្តន៍, ប្រាក់រ៉ុំត្រេត, ~ fund មូលនិធិសោធននិវត្តន៍

**pensioner** អ្នកទទួលសោធននិវត្តន៍
**per diem** (ប្រាក់) ចំណាយតាមថ្ងៃ (គិតតាមចំនួនថ្ងៃ និងតាមធម្មតាមានអត្រាស្មើគ្នាសំរាប់បុគ្គលិកគ្រប់កំរិត)
**percentage** ភាគរយ
**perception** សញ្ញាខន្ធ, ចំណាប់អារម្មណ៍
**performance** ទង្វើ, ការអនុវត្តន៍, លទ្ធផល, ~ standard ស្តង់ដារ លទ្ធផល/ប្រតិបត្តិ
**performing** ដែលដំណើរការ, ~ asset ទ្រព្យសកម្មដំណើរការ, non ~ asset ទ្រព្យសកម្មមិនដំណើរការ
**period** រយៈពេល, អំឡុងពេល, គ្រា (គណនេយ្យ)
**periodic** តាមកាលកំណត់, ទៀងពេល, សាមាយិក, ~ control system ប្រព័ន្ធត្រួតពិនិត្យតាមកាលកំណត់, ~ order system ប្រព័ន្ធបញ្ជាទិញទៀងពេល
**periodical n.** កាលិកប័ត្រ (ទស្សនាវដ្តី, ព្រឹត្តិប័ត្រ...)
**periodically** ដោយទៀងពេល
**periodicity** សាមយិកភាព
**perishable adj.** ដែលងាយខូច(គុណភាព), ~ goods ទំនិញងាយខូច
**perishables n.** ទំនិញងាយខូច
**perks (or perquisites)** អត្ថប្រយោជន៍បន្ថែម (ផ្តល់ជាបន្ថែមលើបៀវត្សរ៍)
**permanent** អចិន្ត្រៃយ៍, ~ establishment គ្រឹះស្ថានអចិន្ត្រៃយ៍, គ្រឹះស្ថានជាប់លាប់, ~ organ អង្គការអចិន្ត្រៃយ៍
**permit** លិខិតអនុញ្ញាត, ទិដ្ឋាការ, building ~ លិខិតអនុញ្ញាតសាងសង់, export/import ~ លិខិតអនុញ្ញាតនាំចេញ/នាំចូល, work ~ លិខិតអនុញ្ញាតអោយធ្វើការ (សំរាប់ជនបរទេស)
**perpetual inventory system** ប្រព័ន្ធសារពើភ័ណ្ឌនិរន្តន៍
**perpetuity** និច្ចភាព
**person** បុគ្គល, physical/natural ~ រូបវន្តបុគ្គល, legal person/entity នីតិបុគ្គល
**personal** ផ្ទាល់ខ្លួន, ~ consumption ការប្រើប្រាស់ផ្ទាល់ខ្លួន, ~ effects សំភារៈប្រើប្រាស់ផ្ទាល់ខ្លួន, ~ loan កំចីផ្ទាល់ខ្លួន (សំរាប់ការប្រើប្រាស់ក្នុងគ្រួសារ រឺ ផ្ទាល់ខ្លួន មិនមែនសំរាប់អាជីវកម្មទេ), ~ property ទ្រព្យផ្ទាល់ខ្លួន, ~ revenue ប្រាក់ចំណូលបុគ្គល, ~ selling ការឃោសនាផ្សាយលក់ផ្ទាល់ (នៃបុគ្គលម្នាក់), ~ income tax ពន្ធលើប្រាក់ចំណូលបុគ្គល
**personal identification number** (see PIN)
**personality** ១. បុគ្គលិកលក្ខណៈ (គួរកត់សំគាល់) ២. អ្នកល្បីល្បាញ
**personnel** បុគ្គលិក, ~ benefits អត្ថប្រយោជន៍ផ្តល់អោយបុគ្គលិក
**perspective** យថាទស្សន៍, ទស្សនវិស័យ
**PERT** (Programme Evaluation and Review Techniques) បច្ចេកទេសពិនិត្យវាយតំលៃគំរោង (រឺ កម្មវិធី)
**pessimistic estimate** ការប៉ាន់ស្មានទុទិដ្ឋិ
**pesticides** ថ្នាំសំលាប់សត្វចង្រៃ
**petition** ញត្តិ
**petroleum** ប្រេងកាត, ប្រេងឥន្ធនៈ, ~ security agreement កិច្ចព្រមព្រៀងស្តីពី សន្តិសុខប្រេងឥន្ធនៈ
**petty cash** សាច់ប្រាក់បន្តិចបន្តួច, ~ custodian អ្នកកាន់ហិបប្រាក់ (ប្រាក់តិចតួច), ~ book សៀវភៅចំណាយតូចតាច, ~ fund បេឡា, មូលនិធិសំរាប់

ចំណាយបន្តិចបន្តួច, ~ voucher ប័ណ្ណចំណាយបេឡា
**Ph.D. (degree)** ថ្នាក់បណ្ឌិត
**phase n.** ដំណាក់កាល
**Phillips curve** ខ្សែកោងហ្វីលីព (បង្ហាញទំនាក់ទំនងរវាងអត្រាប្រែប្រួលនៃប្រាក់បៀវត្សរ៍ទៅនឹងកម្រិតនិកម្មភាព)
**phone card** ស័ព្ទប័ត្រ (កាតទូរស័ព្ទ)
**physical** រូបវន្ត, ជាក់ស្តែង, ~ accounts គណនេយ្យរូបធាតុ, ~ environment បរិស្ថានរូបវន្ត, ~ factor កត្តារូបវន្ត, ~ infrastructure ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ~ investment វិនិយោគរូបវន្ត (ជាសំភារៈ, ប្រាក់កាស..), ~ resources ធនធានរូបវន្ត (អាគារ, ឧបករណ៏..)
**physical therapist** អ្នកព្យាបាលដោយចលនា
**phytosanitary** ភូតគាមអនាម័យ
**piece rate** អត្រាតាមឯកតាផលិត (កំរៃគិតតាមបរិមាណផលិតបាន)
**pilot project** គំរោងសាកល្បង
**PIN** (personal identification number) លេខសំគាល់ផ្ទាល់ខ្លួន, លេខអត្តសញ្ញាណបុគ្គល
**pioneer industry** ឧស្សាហកម្មឈានមុខ
**pioneering work** ការងារឈានមុខ/ត្រួសត្រាយ
**pisciculture** ការចិញ្ចឹមត្រី, មច្ឆវប្បកម្ម
**pittance** ប្រាក់ចំណូលដ៏ស្តួចស្តើង
**place** កន្លែង
**plan n.** ផែនការ, five-year ~ ផែនការប្រាំឆ្នាំ, investment ~ ផែនការវិនិយោគ, rolling ~ ផែនការរំកិល
**planned economy** សេដ្ឋកិច្ចផែនការ
**planner** អ្នកធ្វើផែនការ, ផែនការី
**planning** ផែនការកម្ម, ការធ្វើផែនការ, ការកសាងផែនការ
**plant n.** ១. រោងចក្រ ២. គ្រឿងម៉ាស៊ីន
**plantation** ចំការ, rubber ~ ចំការកៅស៊ូ
**platform** វេទិកា, កម្មវិធីនយោបាយ (របស់គណបក្ស)
**playback** ការចាក់ឡើងវិញ (ខ្សែអាត់..)
**pledge** ការសន្យា, ប្រាក់សន្យាអោយ
**plenary session** សម័យប្រជុំពេញអង្គ
**plot** ដីឡូត៍, ក្បាលដី
**plough back v.** វិនិយោគបន្ត (នូវប្រាក់ចំណេញ)
**pocket of poverty** ច្រកល្ហកមានភាពក្រីក្រ
**polarisation, social** ភាពបាក់បែកសង្គម, ការប្រមូលផ្តុំជា (ពីរ) ក្រុមមានគំនិតផ្ទុយគ្នា
**police record, copy of the** លិខិតថ្កោលទោស (របស់ប៉ូលីស)
**policy brief** សង្ខេបសំរាប់គោលនយោបាយ
**policy formulation** និម្មិតកម្ម/ការកសាងគោលនយោបាយ
**policy framework** ក្របខ័ណ្ឌគោលនយោបាយ
**policymaker** អ្នកកសាង/អ្នកកំណត់គោលនយោបាយ
**political platform** (of a party) កម្មវិធីនយោបាយ (របស់គណបក្ស)
**poll n.** ការបោះឆ្នោត
**polling station**ការិយាល័យបោះឆ្នោត
**pollutant n.** សារធាតុបំពុល
**pollution** ការបំពុល, air ~ ការបំពុលខ្យល់
**polyculture** ការធ្វើដំណាំច្រើនមុខ, ពហុវប្បកម្ម
**population** ប្រជាជន, ~ growth rate អត្រាកំណើនប្រជាជន, ~ policy គោលនយោបាយប្រជាជន

**port of loading/shipment** កំពង់ផែផ្ទុកទំនិញ
**portfolio investments** វិនិយោគជាមូលប័ត្រ (ភាគហ៊ុនទាំងអស់របស់វិនិយោគិនណាម្នាក់)
**position** ១. ជំហរ
២. តំណែង, vacant ~ តំណែងទំនេរ
**positive adj.** វិជ្ជមាន, ~ balance of payments ជញ្ជីងទូទាត់វិជ្ជមាន, ~ cash flow លំហូរសាច់ប្រាក់វិជ្ជមាន (សាច់ប្រាក់ហូរចូលធំជាងសាច់ប្រាក់ចេញ), ~ interest ការប្រាក់វិជ្ជមាន (អត្រាការប្រាក់ខ្ពស់ជាងអត្រាអតិផរណា)
**possession** ការកាន់កាប់, ភោគៈ
**post** ជាក្រោយ, ~ auditing សវនកម្មជាក្រោយ
**post a profit/loss** ប្រកាសជា សាធារណៈ/ផ្លូវការ ពី ចំណេញ រឺ កំហាត
**post an entry/item to the ledger** ចុះលេខនាទៅក្នុងសៀវភៅធំ
**post-action controls** ការត្រួតពិនិត្យក្រោយសកម្មភាព
**post-date v.** ចុះកាលបរិច្ឆេទអនាគត
**potential n. & adj.** ១. សក្ដានុពល
២. សក្ដានុភូត
**potentiality** សក្ដានុភាព
**poverty** ភាពក្រីក្រ, ទុរគតភាព, ~ reduction ការកាត់បន្ថយភាពក្រីក្រ, ~ line បន្ទាត់ក្រីក្រ
**power** អំណាច, សិទ្ធិអំណាច, កំលាំង, អានុភាព
**power boat** ឡូងបុត (អូប័រ)
**power grid/network** បណ្ដាញអគ្គីសនី
**power of attorney** លិខិតប្រគល់សិទ្ធិ
**practice** ការអនុវត្តន៏ ជាក់ស្ដែង/ប្រចាំ, professional ~ ប្រព្រឹត្តិកម្មវិជ្ជាជីវៈ
**practitioner** អ្នកអនុវត្ត (ប្រចាំ)

**pragmatic adj.** ដែលគិតពីលទ្ធផល, ដែលមានផល
**pre-** មុន, បុរេ, pre-Angkor បុរេអង្គរ, pre-crisis មុនវិបត្តិ,
**pre-action controls** ការត្រួតពិនិត្យមុនសកម្មភាព
**precarious path** គន្លងគ្រោះថ្នាក់
**precedent n.** ករណីយុត្តិសាស្ត្រ (តុលាការ)
**preceding** មុន, ~ year ឆ្នាំមុន (ឆ្នាំមុនទី១)
**precious stones** ត្បូង (ថ្ម) មានតំលៃ
**preclude** ច្រានចោលជាមុន
**pre-concession inventory** សារពើភ័ណ្ឌបុរេសម្បទាន
**precondition** បុរេលក្ខខណ្ឌ (លក្ខខណ្ឌត្រូវបំពេញជាមុន)
**predictability n.** ភាពអាចទស្សន៏ទាយបាន, ទស្សលទ្ធភាព
**predictable adj.** អាចទស្សន៏ទាយបាន
**preemption** សិទ្ធិទិញមុនគេ (នូវសន្លឹកហ៊ុនចេញផ្សាយថ្មីថែមទៀត)
**pre-existing condition** លក្ខខណ្ឌមានតាំងពីមុន
**pre-feasibility study** ការសិក្សាមុនការសិក្សាពីភាពអាចធ្វើបាន
**preference** ចំណូលចិត្ត
**preference share** ហ៊ុនអនុគ្រោះ (ដែលជារឿយៗ គ្មានសិទ្ធិបោះឆ្នោតទេ ប៉ុន្តែទទួលបានភាគលាភមុនហ៊ុនឯទៀត និងត្រូវសងមុនហ៊ុនធម្មតា ក្នុងករណីរំលាយក្រុមហ៊ុន)
**preferential** ដែលមានសិទ្ធិ, ដែលគេចូលចិត្ត (ជាងអ្វីមួយទៀត), ~ creditor ឥណទាយកមានសិទ្ធិទារបំណុលមុន, ~ duty (tariff) អត្រាពន្ធគយអនុគ្រោះពិសេស (ទាប)
**pre-investment agency** ទីភ្នាក់ងារពិនិត្យ

លទ្ធភាពមុនពេលវិនិយោគ

**prejudice** ១. បុរេវិនិច្ឆ័យ ២. ការធ្វើឱ្យខូចខាតដល់

**preliminary adj.** ផ្តើមមុខ, ~ discussion ការពិភាក្សាផ្តើមមុខ

**premises** អាគារ និងដីជិតអាគារ (កម្មសិទ្ធិករតែមួយ)

**premium** បុព្វលាភ, at a ~ ដែលលក់បានថ្លៃ (លើសធម្មតា), insurance ~ បុព្វលាភធានារ៉ាប់រង

**prepaid expense** ចំណាយបង់មុន

**prepaid income** ចំណូលទទួលមុន

**prerequisite** បុព្វលក្ខខណ្ឌ

**prescription** បញ្ញត្តិ/វេជ្ជបញ្ជា

**present v.** បង្ហាញ, presenter អ្នកបង្ហាញ, presentation បទបង្ហាញ

**present value** តំលៃបច្ចុប្បន្ន

**press release** ប្រកាសព័ត៌មាន

**prestige** កិត្យានុភាព, ភាពថ្កើង, ~ product ផលិតផលប្រណិតថ្កុំថ្កើង

**presumption** ការសន្មតជាមុន, សច្ចធារណ៍, ~ of innocence សច្ចធារណ៍នៃនិរទោស

**pre-tax profit** ចំណេញមុនបង់ពន្ធ

**prevalence** ប្រេវ៉ាឡង់/ភាពជាទូទៅ

**price** ថ្លៃ, agreed ~ ថ្លៃព្រមព្រៀង, all-in ~ ថ្លៃសព្វគ្រប់, bargain ~ or cut ~ ថ្លៃថោកណាស់, list ~ ថ្លៃលើបញ្ជី (កាតាឡុក), ~ and salary freeze ការទប់ថ្លៃ និងបៀវត្សរ៍មិនអោយឡើង, ~ discrimination ការរើសអើងក្នុងការកំណត់ថ្លៃ, ~ list បញ្ជីថ្លៃ, closing/opening ~ ថ្លៃពេលហៀបបិទហាង/បើកលក់, cost ~ ថ្លៃដើម, competitive ~ ថ្លៃប្រកួតប្រជែង, fair ~ ថ្លៃយុត្តិធម៌, rock bottom ~ ថ្លៃថោកបំផុត, selling ~ ថ្លៃលក់, ~ fixing ការឃុបឃិតកំណត់ថ្លៃ

**prices to suit all pockets** ថ្លៃសមស្របនឹងលទ្ធភាពទិញរបស់គ្រប់គ្នា

**pricing** ការកំណត់ថ្លៃ, ~ system ប្រព័ន្ធកំណត់ថ្លៃ clearance ~ ការកំណត់ថ្លៃដើម្បីបញ្ចេញទំនិញ

**primary** បឋម, ដំបូង, ~ factor income កត្តាចំណូលបឋម, ~ factor of production កត្តាផលិតកម្មបឋម, ~ health care (PHC) ការថែទាំសុខភាពបឋម, ~ needs តំរូវការចាំបាច់ ជាមូលដ្ឋាន, ~ sampling unit (PSU) ឯកតាយកគំរូតាងដំបូង, ~ selection ជំរើសដំបូង, ~ stratification ស្រទាប់នីយកម្មដំបូង, ~ -sampling frame (PSF) គ្រោងយកគំរូតាងដំបូង

**primary education** ការអប់រំកំរិតបឋម

**prime cost** តំលៃផលិតផ្ទាល់ (គ្មានបូកចំនាយទូទៅ)

**principal** (in power transfer) អាណត្តិទាយក

**principal accountant** គណនេយ្យករដើមខ្សែ (ក្រសួងហិរញ្ញវត្ថុ)

**principal insurance company** ក្រុមហ៊ុនធានារ៉ាប់រងដើម

**principle of equality and mutual benefit** គោលការណ៍ស្មើភាពនិងមានប្រយោជន៍ទៅវិញទៅមក

**prior adj.** ពីមុន, ~ agreement កិច្ចព្រមព្រៀងពីមុន

**prioritise v.** ធ្វើអាទិភាវូបនីយកម្ម

**priority n.** អាទិភាព, have/take ~ over មានអាទិភាពលើ

**private company or privately owned company** ក្រុមហ៊ុនឯកជន

**private income** ចំណូលក្រៅពីបៀវត្សរ៍

**private investor** វិនិយោគិនឯកជន (មនុស្សធម្មតាដែលមានប្រាក់វិនិយោគ)

**private economic entity**

អង្គភាពសេដ្ឋកិច្ចឯកជន

**privatisation** ឯកជននីយកម្ម, ឯកជនភាវូបនីយកម្ម

**privilege ១.** ឯកសិទ្ធិ (អត្ថប្រយោជន៍ពិសេស) **២.** បុព្វសិទ្ធិ (សិទ្ធិពិសេស)

**pro forma invoice** វិក្កយបត្របណ្ដោះអាសន្ន

**proactive** សកម្មគ្រប់គ្រង, សកម្មប្រយុទ្ធ

**probability** ប្រូបាប៊ីលីតេ, ភវនីយភាព, ~ sampling ការយកគំរូតាងដោយប្រូបាប៊ីលីតេ

**procedural law** (French: code de procédure) ច្បាប់នីតិវិធី

**procedure** នីតិវិធី

**proceeds** ប្រាក់ចំណូល, ផល, net ~ ចំណូលសុទ្ធ

**process** ដំណើរការ

**processing** ការកែច្នៃ, ប្រព្រឹត្តកម្ម, ការចាត់ចែង (ទិន្នន័យ..), certificate of ~ វិញ្ញាបនប័ត្របញ្ជាក់ពីកន្លែងកែច្នៃ

**proclamation** សេចក្ដីប្រកាស, ការប្រកាស

**procurement** លទ្ធកម្ម, ការផ្គត់ផ្គង់, ~ phase ដំណាក់កាលផ្គត់ផ្គង់

**producer** ផលិតករ, ~ surplus ផលលើសបានដល់ផលិតករ

**product** ផលិតផល, ~ breadth ចំនួនមុខផលិតផល, ~ cycle វដ្ដផលិតផល, ~ depth ធុនផលិតផល (ក្នុងខ្សែផលិតផលនិមួយៗ), ~ line/ range ខ្សែផលិតផល (ផលិតផលប្រហាក់ប្រហែលគ្នា ១ខ្សែ), ~ mix ល្បាយផលិតផល (ផលិតផលទាំងអស់ដែលដាក់លក់ រឺផលិតដោយសហគ្រាសណាមួយ)

**production** ផលិតកម្ម, ~ accounts គណនីផលិតកម្ម, ~ cost ចំណាយផលិតកម្ម, ~ line ខ្សែសង្វាក់ផលិតកម្ម, ~ system ប្រព័ន្ធផលិតកម្ម

**production-sharing contract** (PSC) កិច្ចសន្យាបែងចែកផលិតកម្ម

**productive adj.** មានផលិតភាព, ~ assets ទ្រព្យសកម្មមានផលិតភាព, ~ ratio សមាភាគផលិតភាព

**productivity** ផលិតភាព

**profession n.** វិជ្ជាជីវៈ, medical ~ វិជ្ជាជីវៈ (ខាង) ពេទ្យ

**professional** នៃវិជ្ជាជីវៈ, ~ fees សោហ៊ុយវិជ្ជាជីវៈ, ~ secrecy ការរក្សាសំងាត់វិជ្ជាជីវៈ

**profile n.** ទំរង់, រូបភាពទូទៅ (ឧ. នៃក្រុមហ៊ុនចំពោះសាធារណជន)

**profit** ចំណេញ, ប្រាក់ចំណេញ, healthy ~ ចំណេញច្រើន, ~ margin អត្រាចំណេញ, អប្បហារ, ~ sharing ការបែងចែកប្រាក់ចំណេញ

**profit and loss account or profit and loss statement** (US) គណនីចំណេញខាតគណនីលទ្ធផល, របាយការណ៍ចំណូលចំណាយ

**profitability** ភាពមានចំណេញ

**programme of action** កម្មវិធីសកម្មភាព

**progress** វឌ្ឍនភាព, ភាពជឿនលឿន, ជំនឿន, ~ report របាយការណ៍ជំនឿន, ~ payment ការទូទាត់តាមដំណាក់នៃជំនឿនការងារ, in ~ កំពុងជឿនលឿន

**progressive personal income tax** ពន្ធកំណើនតាមថ្នាក់លើចំណូលបុគ្គល

**prohibition** ការហាមឃាត់

**prohibitive adj. ១.** ដែលខ្ពស់ហួសលទ្ធភាព (ថ្លៃ, តំលៃ) **២.** ដែលហាមឃាត់ (ច្បាប់)

**project** គំរោង, ~ appraisal ការវាយតំលៃគំរោង, ~ cycle វដ្ដនៃគំរោង, ~ formulation ការកសាងគំរោង, ~ justification យុត្តិកម្មគំរោង,

~ proposal សំណើគំរោង, ~ implementation ការអនុវត្តន៍គំរោង,

**projection** ការគន់គូរជាមុន

**proliferation** ការរីកសាយ (ចំនួន)

**promise to pay** (French: engagement de dépense) ការសន្យាចំណាយ

**promissory note** ប័ណ្ណជំពាក់ប្រាក់, ប័ណ្ណសន្យាសង

**promotion** ១. ការតំលើងឋានៈ (បុគ្គលិក) **២.** ការផ្សព្វផ្សាយ (លក់ផលិតផល) **៣.** ការជំរុញ, ~ of commercial interests ការជំរុញផលប្រយោជន៏ពាណិជ្ជកម្ម

**promotional strategy** យុទ្ធសាស្ត្រផ្សព្វផ្សាយ (លក់ផលិតផល)

**prompt adj.** ភ្លាមៗ, ~ cash ប្រាក់បង់ដល់ដៃ, ~ delivery ការប្រគល់ភ្លាមៗ, ~ payment ការទូទាត់ភ្លាមៗ

**proof** ភស្តុតាង, សក្ខីកម្ម

**propensity** ទំនោរ, ឧបនិស្ស័យ

**property** ទ្រព្យ, សម្បត្តិ, ទ្រព្យសម្បត្តិ, កម្មសិទ្ធិ, ដីនិងអាគារ, ~ insurance ការធានារ៉ាប់រងទ្រព្យសម្បត្តិ, ~ tax ពន្ធលើទ្រព្យសម្បត្តិ/កម្មសិទ្ធិ

**proportion n.** សមាមាត្រ, in ~ to សមាមាត្រនឹង

**proportional allocation** ការបែងចែកសមាមាត្រ

**proportional tax system** ប្រព័ន្ធពន្ធសមាមាត្រ

**proposal** សំណើ, project ~ សំណើគំរោង

**proprietor, proprietress, n.** ម្ចាស់, កម្មសិទ្ធិករ

**prosecution** ១. បណ្តឹងសាធារណៈ, ការប្តឹងចោទប្រកាន់ **២.** អយ្យការ (ភាគីដើមចោទក្នុងរឿងព្រហ្មទណ្ឌ)

**prosecutor** ព្រះរាជអាជ្ញា

**prospect** និទស្សន៏ (ការរំពឹងទុក)

**prospecting licence** អាជ្ញាប័ណ្ណសំរាប់ការរុករក (ប្រេងកាត, រ៉ែ...)

**prospective buyer** អ្នកទិញក្នុងការរំពឹង

**prospector** អ្នករុករក (រ៉ែ...), បុរេសិ

**prospectus** បរិយាយប័ណ្ណ

**prosperity** វិបុលភាព

**protection** កិច្ច/ការ ការពារ, environment(al) ~ កិច្ចការពារបរិស្ថាន

**protectionist measure** វិធានការការពារផលិតផលក្នុងស្រុក

**protocol** ១. ពិធីសារ (ឯកសារ) **២.** ពិធីការ (សំរាប់ពិធីផ្សេងៗ)

**protracted war** សង្គ្រាមរ៉ាំរ៉ៃ

**provision** ១.សេចក្តីថែង, បទប្បញ្ញត្តិ វិបញ្ញត្តិ (ច្បាប់), final ~អវសានប្បញ្ញត្តិ, transitional ~ អន្តរប្បញ្ញត្តិ **២.** វិធានការត្រៀម **៣.** វត្ថុផ្គត់ផ្គង់, សំវិធានវត្ថុ

**provision dealer, retail** អ្នកលក់រាយនូវទំនិញស្បៀងអាហារ

**provision reserve** សំវិធានធន

**provisional invoice** វិក្កយបត្របណ្តោះអាសន្ន

**proxy** ១. អ្នកទទួលការផ្ទេរសិទ្ធិ, អាណត្តិគាហក **២.** ឯកសារសិទ្ធិប្រទាន, លិខិតផ្ទេរសិទ្ធិ **៣.** សិទ្ធិប្រទាន, ការផ្ទេរសិទ្ធិ

**prudent monetary policy** គោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្ន

**prudential measure** វិធានការប្រុងប្រយ័ត្ន

**prudential rule** វិធានប្រុងប្រយ័ត្ន

**public administration** រដ្ឋបាលសាធារណៈ
**public n. & adj.** ១.សាធារណជន, general ~ សាធារណជន ២.សាធារណៈ, ~ accounting/accounts គណនេយ្យសាធារណៈ, ~ company or ~ limited company (PLC) ក្រុមហ៊ុនភាគហ៊ុន, សាជីវកម្ម (មានចេញសន្លឹកហ៊ុនលក់ឱ្យសាធារណជន), ~ finance ហិរញ្ញវត្ថុសាធារណៈ, ~ adminstrative establishment គ្រឹះស្ថានរដ្ឋបាលសាធារណៈ, ~ entity អង្គភាពរដ្ឋ ~ order សណ្តាប់ធ្នាប់សាធារណៈ, ~ proclamation សេចក្តីប្រកាសជាសាធារណៈ, ~ sector វិស័យសាធារណៈ, ~ utilities សហគ្រាសផ្គត់ផ្គង់សាធារណៈ (ផ្តល់សេវាសំរាប់ផលប្រយោជន៍សាធារណៈដូចជាទឹក, អគ្គិសនី, ឧស្ម័ន, ទូរគមនាគមន៍), ~ works សាធារណៈការ
**public relations** ទំនាក់ទំនងសាធារណៈ
**publicise v.** ផ្សព្វផ្សាយ (ច្បាប់)
**public-spirited** ដែលគិតប្រយោជន៍សាធារណជន
**publish v.** ១. បោះពុម្ពផ្សាយ ២. ប្រកាសផ្សាយ, ប្រកាសផ្សាយជាសាធារណៈ
**purchase ledger** សៀវភៅធំទិញ (កត់ត្រាការទិញចូល)
**purchase v. & n.** ១. ទិញ, ~ on credit ទិញជឿ ២. ការទិញ
**purchaser** អ្នកទិញ, likely/prospective ~ អ្នកទិញដែលគេរំពឹង
**purchasing power** អំណាចទិញ, លទ្ធកម្មពល, ~ of the currency អំណាចទិញនៃរូបិយវត្ថុ
**purge** វិសុទ្ធិកម្ម, វិរេចនកម្ម, ការសំអិតសំអាង
**purify v.** ចំរាញ់អោយសុទ្ធ, បន្សុទ្ធ, ច្រោះសំអាត
**purpose** គោលដៅ
**purposive sampling** ការយកគំរូតាងតាមគោលដៅ

## Q, q

**qualification** គុណវុឌ្ឍិ, កិរិតជំនាញ, គុណសម្បត្តិខាងជំនាញ, លក្ខណៈសម្បត្តិ
**qualified acceptance** ការទទួលព្រមដោយមានលក្ខខណ្ឌ
**qualitative** នៃគុណភាព, ~ method វិធីសាស្ត្រ (វិភាគ) តាមបែបគុណភាព
**quality shipped** គុណភាព (ទំនិញ) ពេលផ្ទុក
**quality standard** ស្តង់ដារគុណភាព, បមាទីយគុណភាព
**quantitative** នៃបរិមាណ, ~ method វិធីសាស្ត្រ (វិភាគ) តាមបែបបរិមាណ
**quarrying** អាជីវកម្ម(យក)ថ្ម
**quarter** ១. ត្រីមាស, ២. មួយភាគបួន, 2nd ~ of 7th century មួយភាគបួនទី២នៃសតវត្សរ៍ទី៧
**quarter-day** ថ្ងៃប្រគល់ប្រាក់(ឈ្នួល) ប្រចាំត្រីមាស
**quarterly adj. & adv.** ប្រចាំត្រីមាស
**quasi-money** រូបិយវត្ថុផ្សេងៗ
**quasi-public institution** ស្ថាប័នសាធារណៈប្រហាក់ប្រហែល
**questionnaire** បញ្ជីសំនួរ (សំរាប់សំភាសន៍)
**quick ratio** សមាភាគរហ័ស
**quintile** បញ្ចភាគ (ស្ថិតិ)
**quorum** កូរ៉ុម (ចំនួនមនុស្សចាំបាច់សំរាប់បើកការប្រជុំ)
**quota** កូតា, fixing of ~ ការកំណត់កូតា, ~ regime របបកូតា, ~ sampling ការយកគំរូតាងតាមកូតា

**quotation** ថ្លៃប្រកាស (នៅទីផ្សារ), ការប្រកាសថ្លៃ, share ~ ការប្រកាសថ្លៃសន្លឹកហ៊ុន, keen ~ ថ្លៃទាក់ទាញ (គួរអោយចង់ទិញ)

**quote v. & n. ១**. កំណត់/ប៉ាន់ស្មាន, ~ in local currency កំណត់ថ្លៃជារូបិយវត្ថុក្នុងស្រុក
**២**. ថ្លៃកំណត់

**quoted company** ក្រុមហ៊ុនចូលផ្សារហ៊ុន (សន្លឹកហ៊ុនមានលក់/ទិញ នៅផ្សារហ៊ុន)

**quoted price** ថ្លៃបានប្រកាស

**quotient n.** ផលចែក

## R, r

**racism** ពូជសាសន៍និយម

**raise v. ១**. តំលើង, ~ taxes តំលើងពន្ធ
**២**. កេណ្ឌប្រមូល, រៃអង្គាស (ប្រាក់)

**rally** (price) ឡើងថ្លៃវិញ (ក្រោយពីបានចុះ)

**random** ចៃដន្យ, ~ check ការត្រួតមើលចៃដន្យ, ~ sample គំរូតាងចៃដន្យ

**randomisation** ចៃដន្យនីយកម្ម

**range n. ១**. ប្រឡោះ, price ~ ប្រឡោះថ្លៃ, ~ of vision ប្រឡោះ (ចំងាយ) មើលឃើញ
**២**. ចំនួនមុខ (ផលិតផលប្រភេទណាមួយ)
**៣**. ជួរ (ភ្នំ)

**rank** ឋានៈ, ឋានន្តរស័ក្តិ (មន្ត្រីរាជការ)

**rank v.** ធ្វើចំណាត់ថ្នាក់ (តាមលំដាប់)

**ransom** ប្រាក់លោះខ្លួន

**rate** អត្រា, exchange ~ អត្រាប្តូរប្រាក់, closing ~ អត្រាប្តូរប្រាក់នៅពេលបិទ, forward ~ អត្រាប្តូរប្រាក់មានកាលកំណត់, ~ of interest អត្រាការប្រាក់, ~ of return អត្រាទាញចំណូល, spot ~ អត្រាប្តូរប្រាក់ដល់ដៃ

**rate** ថ្លៃ (ឯកតា)

**ratification** ការផ្តល់សច្ចាប័ន, សច្ចានុមតិ

**rating** ការធ្វើចំណាត់ថ្នាក់ តំលៃ/គុណសម្បត្តិ, performance ~ ការធ្វើចំណាត់ថ្នាក់លទ្ធផលការងារ

**ratio** សមាភាគ, អនុបាត, ~ analysis ការវិភាគសមាភាគ

**rational** សមហេតុផល, សនិទានីយ, ~ expectation ការរំពឹងសមហេតុផល

**rationale** សនិទានភាព, ហេតុផល

**rationality** សនិទានភាព

**rationalisation** សនិទានកម្ម, ការធ្វើឱ្យរឹតតែមានប្រសិទ្ធភាព, ~ of civil servants សនិទានកម្មមន្ត្រីរាជការ

**raw adj.** ឆៅ, ~ data ទិន្នន័យឆៅ (មិនទាន់វិភាគ), ~ materials វត្ថុធាតុដើម

**real** ពិត, ~ GNP ផលិតផលជាតិសរុបពិត, ~ rate of interest អត្រាការប្រាក់ពិត

**real estate/property** អចលនទ្រព្យ (ដី និង/ឬ អាគារ), ~ agency ទីភ្នាក់ងារអចលនទ្រព្យ

**realism** ប្រាកដនិយម

**reality n.** តថភាព, ការពិត

**realisation** សមិទ្ធិកម្ម, សមិទ្ធិផល

**realise v.** សំរេច, ធ្វើអោយសំរេច

**realty** អចលនទ្រព្យ

**reasonable** សមរម្យ

**reassess v.** វាយតំលៃឡើងវិញ, reassessment n.

**rebate ១**. ការចុះថ្លៃ (លើ ទំនិញមិនត្រូវប៉ាន់/ការសងប្រាក់មុនថ្ងៃកំណត់)
**២**. ការ បន្ថយ/ចុះ ថ្លៃ (ឱ្យអតិថិជនដែលទិញច្រើន)
**៣**. ការបង្វិលតំលៃ (មួយឆ្នាំគិតម្តងជាការដឹងគុណ

ដល់អតិថិជន)
**receipt** បង្កាន់ដៃ, លិខិតទទួល
**receiver** អ្នកទទួល
**recession, economic** ការធ្លាក់ចុះសេដ្ឋកិច្ច
**recidivism, case of** ករណីមិនរាងចាល
**recipient** អ្នកទទួល, ~ country ប្រទេសទទួល (ឧ. ជំនួយ)
**reciprocity** បដិការ, ភាពមានទៅមានមក
**recognise** ស្គាល់, ទទួលស្គាល់, recognised ប្រតិស្រុត
**recommendation** អនុសាសន៍, មតិផ្តាំផ្ញើ
**recompense v. & n.** ១. សង (ការខូចខាត), ២. សំណង
**reconcile v.** បន្សុី, សំរបសំរួល, ផ្សះផ្សាឡើងវិញ, reconciliation n.
**reconnaissance study** ការសិក្សាស្វែងយល់
**reconversion** ការផ្លាស់ប្តូរឡើងវិញ, ការរៀបចំឡើងវិញ
**record n. & v.** ១. កំណត់ត្រា, ប្រវត្តិ, ឯតទគ្គកម្ម (លទ្ធផលខ្ពស់បំផុត), ~ profits ចំណេញខ្ពស់បំផុតមិនធ្លាប់មាន ២. កត់ត្រា
**recourse** ឧបាស្រ័យ (សិទ្ធិរបស់អ្នកកាន់រូបិយាណត្តិក្នុងការតាមទារសំណងពីអ្នកធ្វើបិដ្ឋិលេខ)
**recoverable** (debt) ដែលអាចប្រមូលវិញបាន
**recovery** ១. ការយកចូលវិញ (ប្រាក់បង្ការ) ២. ការប្រមូលមកវិញ, ~ of debts ការប្រមូលប្រាក់បំណុលមកវិញ ៣.ការរើប (សេដ្ឋកិច្ច)
**recreation** (service) កំសាន្ត
**rectangular strategy** យុទ្ធសាស្ត្រចតុកោណ
**rectification** ការកែតំរូវ
**recurrent adj.** ម្តងហើយម្តងទៀត, ~ expenditure ចំណាយម្តងហើយម្តងទៀត
**recycling** ការកែច្នៃឡើងវិញ
**red soil** ដីក្រហម
**red tape** ការិយាធិបតេយ្យ, បែបបទនិយម
**redeem v.** ១. សងផ្តាច់, ~ a debt សងបំណុលផ្តាច់ ២. ប្តូរ/លក់ យកប្រាក់ (ឧ.សញ្ញាប័ណ្ណ)
**redemption n.** ការសងផ្តាច់ (បំណុល)
**rediscount** បុនអបហារ (ធ្វើអបហារម្តងទៀត)
**redistribution** ការបែងចែកឡើងវិញ
**redress n.** សំណង (ការខូចខាត, ជំងឺចិត្ត)
**reduction** ការកាត់បន្ថយ, budget ~ ការកាត់បន្ថយថវិកា
**redundancy programme** កម្មវិធីបញ្ឈប់ពលករដោយកង្វះការងារ
**redundant adj.** ដែលច្រើនលើសតំរូវការ រឺគ្មានប្រយោជន៍
**re-election** ការបោះឆ្នោតសាជាថ្មី
**reexportation** ការនាំចេញបន្ត, បុននីហរណកម្ម
**referee** អាជ្ញាកណ្តាល
**reference book** សៀវភៅ យោង/ស្រាវជ្រាវ
**reference period** គ្រា/រយៈពេល គោល
**referral hospital** មន្ទីរពេទ្យបង្អែក
**refinancing** (loan) បុនហិរញ្ញប្បទាន (កំចី)
**reflect v.** ឆ្លុះបញ្ចាំង
**reforestation** ការដាំព្រៃឈើឡើងវិញ, បុនវនការ
**reform n. & v.** ១. កំណែទំរង់ ២. កែទំរង់
**refund v. & n.** ១. សងវិញ ២. ប្រាក់សងវិញ
**refusal** ការបដិសេធ, ការប្រកែក, ~ of acceptance ការបដិសេធការទទួលព្រម
**regardless** ដោយមិនគិតដល់
**regime** របប, financial ~ របបហិរញ្ញវត្ថុ

**region** តំបន់, sub-~ អនុតំបន់, military ~ យោធភូមិភាគ, military sub- ~ តំបន់ប្រតិបត្តិការសឹករង

**regionalisation** តំបន់ភាវូបនីយកម្ម

**register n.&v.** ១. បញ្ជី ២. ចុះបញ្ជី, ចុះបញ្ជីការ

**registered capital** មូលធនបានចុះបញ្ជី (ជាផ្លូវការ)

**registered letter/parcel** លិខិត/កញ្ចប់បញ្ញើ អនុសិទ្ធិ

**registered office** (of a company) ទីចាត់ការចុះបញ្ជីជាផ្លូវការ

**registrar** មន្ត្រីចុះបញ្ជី (អ្នកកាន់កាប់បញ្ជី)

**registration n.** ការចុះបញ្ជី, ~ certificate វិញ្ញាបនប័ត្រចុះបញ្ជី, ~ number លេខចុះបញ្ជី

**regressive tax system** ប្រព័ន្ធពន្ធថយចុះ (ថយអត្រានៅពេលចំនួលកើនឡើង)

**regular adj.** ទៀងទាត់, ~ income ប្រាក់ចំណូលទៀងទាត់

**regularity** ភាពទៀងទាត់, និយតភាព

**regularisation** និយតកម្ម

**regularly** ដោយទៀងទាត់

**regulate v.** គ្រប់គ្រងដោយ បទបញ្ជា/បទប្បញ្ញត្តិច្បាប់

**regulations** បទបញ្ជា (*លិខិតបទដ្ឋាន* ក្នុងឯកសារខ្លះ), commune ~ ដីកាឃុំ, general ~ នីតិរួម, internal ~ បទបញ្ជាផ្ទៃក្នុង

**regulator** និយតករ

**rehabilitation** ការស្តារឡើងវិញ, នីតិសម្បទា, ~ project គំរោង នីតិសម្បទា/ស្តារឡើងវិញ, ~ of finances ការស្តារហិរញ្ញវត្ថុឡើងវិញ

**reimburse v.** សងវិញ (ប្រាក់ដែលបានចំណាយ)

**reimbursement** ការសងវិញ

**reinsurance** (ការ) ធានារ៉ាប់រងបន្ត

**reinvest v.** ១. វិនិយោគបន្ត (វិនិយោគប្រាក់ចំនេញទៅក្នុងអាជីវកម្មវិញ) ២. វិនិយោគឡើងវិញ

**reject v. & n.** ១. ច្រានចោល ២. វត្ថុច្រានចោល (ព្រោះមិនត្រូវស្តង់ដារ)

**related** (ជាប់) ទាក់ទង/ទាក់ទិន

**relation** ទំនាក់ទំនង

**relative adj.** ដែលធៀប, ~ price ថ្លៃធៀប

**relative advantage** ឧត្តមភាពប្រៀបធៀប

**relative majority vote** សំលេងភាគច្រើនដោយធៀប (បានសំលេងច្រើនជាងបេក្ខជនម្នាក់ទៀត)

**relative n.** សាច់ញាតិ, ញាតិពន្ធ

**relativity** សាបេក្ខភាព (ភាពមានទំនាក់ទំនង), រីឡាទីវីតេ

**release v.** បញ្ចេញ, ដោះលែង, បន្ធូរ (សំពាធ)

**relevant adj.** ដែលពាក់ព័ន្ធ, ~ institution ស្ថាប័នពាក់ព័ន្ធ

**relief n.** ជំនួយ, tax ~ ការអនុគ្រោះពន្ធ, ~ assistance ជំនួយសង្គ្រោះបន្ទាន់

**relinquish** បង្វិលអោយវិញ, បោះបង់

**remainder** សំណល់ (អ្វីដែលនៅសល់)

**reminder n.** លិខិតរំលឹក (ឧ. ឱ្យមកបង់ពន្ធ)

**remission of taxes** ការបង្វិលសងប្រាក់ពន្ធ (ដែលបានបង់លើស)

**remittance** ការផ្ញើប្រាក់ចេញ, វិសជ្ជនា, ការផ្ទេរប្រាក់

**remote area** តំបន់ដាច់ស្រយាល

**removal from a government office** ដកចេញពីមុខតំណែងអ្វីមួយក្នុងរដ្ឋាភិបាល

**remunerate v.** ផ្តល់លាភការ

**remuneration** លាភការ, ប្រាក់កំរៃ, ប្រាក់ខែ, ប្រាក់ឈ្នួល, ប្រាក់បំណាច់

**renew v. a licence** បន្តអាជ្ញាប័ណ្ណ

**renewable energy** ថាមពលកកើតឡើងវិញ

**rent v. & n.** ១. ជួល ២. ប្រាក់ឈ្នួល (សំខាន់លើអចលនទ្រព្យ)

**rental** ១. ប្រាក់ឈ្នួល (អចលនទ្រព្យ និងចលនទ្រព្យ) ២. ការជួល

**renter** អ្នកជួលពីគេ

**reorganisation** ការរៀបចំឡើងវិញ

**repatriation** មាតុភូមិនិវត្តន៍

**repayment n.** ការសងវិញ, ប្រាក់សងវិញ, ~ schedule តារាងពេលសងប្រាក់

**repeat order** ការបញ្ជាទិញថែមទៀត (នូវមុខទំនិញដដែល)

**repercussion** (of an incident) ប្រតិឃាត

**replacement investment** វិនិយោគបន្លាស់

**replacement value** តំលៃផ្លាស់ចេញ (ផ្លាស់របស់មួយដោយរបស់មួយផ្សេងទៀត)

**replenish v.** បំពេញឡើងវិញ

**replicate** ធ្វើចំលងតាម, ធ្វើសាជាថ្មី (តាមលំនាំដូចគ្នា)

**report** របាយការណ៏, annual ~ របាយការណ៏ប្រចាំឆ្នាំ, market ~ របាយការណ៏ថ្លៃទំនិញនៅទីផ្សារ

**representative** តំណាង, អ្នកតំណាង, authorized ~ អ្នកតំណាងមានសិទ្ធិប្រទាន

**reproductive adj.** នៃការបន្តពូជ, ~ health សុខភាពបន្តពូជ

**repurchase** ការទិញយកវិញ

**reputation** កេរ្តិ៍ឈ្មោះ, កិត្តិនាម, good ~ កិត្តិសព្ទ

**request v. & n.** ១. ស្នើ ២. សំណើ

**require v.** តំរូវឱ្យ (ធ្វើអ្វីមួយ), required reserves ប្រាក់បំរុងតាមការតំរូវ (ឧ, ក្នុងច្បាប់)

**requirement** ការតំរូវ

**resampling** ការយកគំរូតាងសាជាថ្មី

**reschedule** (a loan) ធ្វើកាលវិភាគថ្មី

**rescind v. a contract** លុបចោលកិច្ចសន្យា

**rescue v. & n.** ១. សង្គ្រោះ ២. ការសង្គ្រោះ

**research v. & n.** ១. ស្រាវជ្រាវ ២. ការស្រាវជ្រាវ, ~ and development (R & D) ការស្រាវជ្រាវ និងអភិវឌ្ឍន៏

**researcher** អ្នកស្រាវជ្រាវ, associate ~ អ្នកស្រាវជ្រាវរង, fellow ~ អ្នកស្រាវជ្រាវ, senior ~ អ្នកស្រាវជ្រាវជាន់ខ្ពស់

**reserve** ធនបំរុង, ឋបនីយភណ្ឌ, ~ of value ធនបំរុងមានតម្លៃ, ~ ratio សមាភាគធនបំរុង, ~ requirement account គណនីធនបំរុងកាតព្វកិច្ច, ~ requirements ការតំរូវធនបំរុង, ~ tranche ភាគធនបំរុង

**reserve fund** មូលនិធិបំរុង

**reserve member** (of a committee) សមាជិកបំរុង (នៃគណៈកម្មាធិការ)

**reserved** បំរុងទុក, ~ forest ព្រៃបំរុងទុក

**reserve, Tonle Sap biosphere** ឋបនីយជីវមណ្ឌលបឹងទន្លេសាប

**residence** និវាសដ្ឋាន, និវាសនដ្ឋាន

**resident** និវាសជន/និវាសនជន, អ្នកស្នាក់នៅ, non- ~ អនិវាសជន/អនិវាសនជន

**resident representative** តំណាងប្រចាំប្រទេស

**residual value** តំលៃសំណល់

**resignation** ការលាលែងពីតំណែង

**resolution n.** ១. សេចក្តីសំរេចចិត្ត (នៃអង្គប្រជុំ), ២. ការដោះស្រាយ, conflict ~ ការដោះស្រាយទំនាស់

**resort** រមណីយដ្ឋាន, ~ site មណ្ឌលកំសាន្ត,

កន្លែងរមណីយដ្ឋាន
**resource** ធនធាន, ~ consumption ការប្រើប្រាស់ធនធាន
**resource-rent tax** (RRT) ពន្ធជួលធនធាន
**response bias** លំអៀងក្នុងចំលើយ
**response rate** អត្រាឆ្លើយតប
**responsibility** ការទទួលខុសត្រូវ
**responsible, to hold** ចាប់អោយទទួលខុសត្រូវ
**responsiveness n.** ការ/ភាព ឆ្លើយតប
**restoration n.** ការស្តារជួសជុលឱ្យដូចដើម
**restraining force** កំលាំងបង្អាក់
**restrict v.** ដាក់កំហិត, ~ credit ដាក់កំហិតលើឥណទាន
**restriction n.** កំហិត, ការដាក់កំហិត, trade ~ កំហិតពាណិជ្ជកម្ម
**restructured loan** កំចីបានរៀបចំឡើងវិញ (ពន្យាពេលសង)
**resumption of exports** ការបន្តនាំចេញឡើងវិញ (ក្រោយបានផ្អាកមួយរយៈ)
**retail outlet** ហាង/កន្លែង លក់រាយ
**retail, to sell** លក់រាយ
**retailer, retail dealer** អ្នកលក់រាយ
**retail-trade business** អាជីវកម្ម/ពាណិជ្ជកម្ម លក់រាយ
**retained earnings** ប្រាក់ចំណេញរក្សាទុក
**retained imports** ទំនិញនាំចូលសំរាប់ប្រើប្រាស់ (ក្នុងស្រុក)
**retention of staff** ការរក្សាទុកបុគ្គលិក (កុំអោយគេចេញពីអង្គភាព)
**retiree** និវត្តជន
**retirement** ការចូលនិវត្តន៏
**retirement pension** សោធននិវត្តន៏
**retrenchment** ការកាត់បន្ថយ (ចំនាយ)
**retroactive** ប្រតិសកម្ម, ~ effect ឥទ្ធិពលប្រតិសកម្ម
**retrospection** ការក្រឡេកមើលទៅអតីតកាល
**return** ១. ប្រាក់ចំណូល ២. លិខិតប្រកាស, tax ~ លិខិតប្រកាសសារពើពន្ធ, nil ~ លិខិតប្រកាសសារពើពន្ធដែលគ្មានបំណុលពន្ធត្រូវបង់
**return on investment ratio** សមាភាគចំណូលធៀបនឹងទុនវិនិយោគ
**return, rate of** អត្រាទាញចំណូល
**returnable pack(ag)ing** សំបកវេចខ្ចប់ប្រមូលវិញ/ផ្ញើទុក
**returned cheque** មូលប្បទានប័ត្របញ្ជូនត្រឡប់
**returns** ១. ទំនិញបញ្ជូនត្រឡប់
២. ចំណូលពីវិនិយោគ
**revaluation** ការវាយតំលៃឡើងវិញ
**revealed comparative advantage** ឧត្តមភាពប្រៀបធៀបពិនិត្យឃើញ
**revenue** ចំណូល, ប្រាក់ចំណូល, ~ policy គោលនយោបាយខាងចំណូល, unearned ~ ចំណូលទទួលមុន
**reverse an entry v.** ចុះបញ្ច្រាសលេខនា, ធ្វើប្រតិក្រាន្តលេខនា
**reversible** ដែលអាចប្រែក្រឡាស់បាន
**review** ការពិនិត្យឡើងវិញ, ~ mission បេសកកម្មពិនិត្យឡើងវិញ, for ~ and decision/approval ដើម្បីពិនិត្យ និងសំរេច
**revise v.** កែសំរួល, revised plan ផែនការកែសំរួល
**revocable letter of credit** សារឥណទានអាចលុបវិញបាន
**revoke a licence** ដកហូតអាជ្ញាប័ណ្ណ (មកវិញ)

**revolving fund** ទុនចល័ត
**reward n. & v.** ១. រង្វាន់ ២. ផ្តល់រង្វាន់
**right n. & adj.** ១. សិទ្ធិ ២. ត្រឹមត្រូវ
**right of first refusal** សិទ្ធិបដិសេធទីមួយ
**right of way** សិទ្ធិឆ្លងកាត់ (ដីគេ)
**right to the lease** សិទ្ធិភតិសន្យា (សិទ្ធិនៃកិច្ចសន្យាជួល)
**riot n. & v.** ១. កុប្បកម្ម ២. ធ្វើកុប្បកម្ម
**rise v. & n.** ១. កើន ២. កំណើន
**risk** ហានិភ័យ, ភាពប្រថុយប្រថាន, គ្រោះភ័យ, at owner's ~ ហានិភ័យរ៉ាប់រងដោយម្ចាស់ (ទំនិញ), ~ consideration ការពិចារណាពីហានិភ័យ, ~ taking ការហ៊ានប្រថុយនឹងហានិភ័យ, aggregate credit ~ ហានិភ័យឥណទានសរុប
**rival n.** គូប្រជែង
**road tax** ពន្ធផ្លូវ
**role play** សំដែង (តួ)
**roll over v.** (loan) ផ្តល់សាឡើងវិញ (កំចី)
**rough estimate** ការប៉ាន់ស្មានច្បោលៗ
**routine n.** ទំរង់ការដដែលៗ
**row** ជួរ, ជួរផ្តេក (តារាង)
**royalties** សួយ (រី កំរៃសួយសារ, ប្រាក់បង់ថ្លៃឈ្នួលធ្វើអាជីវកម្ម, ប្រាក់លក់ស្នាដៃ)
**rule** វិធាន, ~ of law នីតិរដ្ឋ
**ruling** សេចក្តីសំរេចជាផ្លូវការ (តុលាការ), សាលដីកា (តុលាការកំពូល)
**ruling prices** ថ្លៃជាក់ស្តែង
**run a factory** (គ្រប់គ្រង) ដំណើរការរោងចក្រ
**running costs** ចំណាយ (សំរាប់) ដំណើរការ
**rush hour** ម៉ោងមមាញឹក

## S, s

**SAC** (structural adjustment credit) ឥណទានកំណែតំរូវរចនាសម្ព័ន្ធ (របស់ធនាគារពិភពលោក)
**safeguard v.** គាំពារ
**safety** សុវត្ថិភាព, ~ net សំណាញ់/ប្រព័ន្ធសុវត្ថិភាព
**salary** បៀវត្សរ៍, ប្រាក់ខែ, starting ~ បៀវត្សរ៍ចាប់ផ្តើមបំរើការ, ~ index សន្ទស្សន៍បៀវត្សរ៍, ~ loan (receivable) កំចីលើបៀវត្សរ៍
**sale** ការលក់, cash ~ ការលក់យកជាសាច់ប្រាក់, for ~ លក់ (សរសេរលើផ្លាកប្រកាស), ~ invoice វិក្កយបត្រលក់, ~ contract កិច្ចសន្យាលក់, ~ on credit ការលក់ជឿ, ~ on instalment plan ការលក់អោយសងបណ្តាក់, ~ or return ផ្ញើលក់ (អ្នកលក់រាយទូទាត់សងតែថ្លៃទំនិញលក់ដាច់ ហើយបង្វិលទំនិញនៅសល់ឱ្យអ្នកលក់ដុំវិញ), ~ proceeds/revenue ចំណូលពីការលក់
**sales** ប្រាក់លក់បាន, ចំនួនទំនិញលក់បាន, ~ manager នាយកគ្រប់គ្រងការលក់, ~ mix សារពើភ័ណ្ឌទំនិញសំរាប់លក់, ~ promotion ការផ្សព្វផ្សាយលក់, ~ returns ទំនិញលក់មិនដាច់បញ្ជូនមកវិញ, ~ tax ពន្ធលើចំណូលលក់បាន, ~ value តំលៃលក់(បាន), ~ volume ចំនួនឯកតាលក់ (បាន)
**salesman** អ្នកលក់, តំណាងលក់
**salination or salinisation** ការប្រែជាប្រៃ (ឧ. ដីប្រៃ)
**salvage v. & n.** ១. ប្រមូលវិញ ២. របស់បាន

ពីការប្រមូល (ពី អគ្គីភ័យ, នាវាលិច...) **៣.** ការសង្គ្រោះ (នាវា ឬទំនិញផ្ទុក)

**salvage/scrap value** តំលៃប្រមូលបានវិញ (ពេលបញ្ចេញលក់របស់ រឺគ្រឿងចក្រចាស់ៗ)

**sample n.** គំរូតាង, ប៉ាន់, take a ~ v. យកគំរូតាង, ~ allocation ការបែងចែកគំរូតាង, ~ design ប្លង់គំរូតាង, ~ group ក្រុមគំរូតាង, ~ overlap ការគងគំរូតាង, ~ implementation ការស្រង់គំរូតាង, ~ selection ការជ្រើសគំរូតាង, ~ survey អង្កេតគំរូតាង

**sample v.** យកគំរូតាង, sampled children កុមារ (ត្រូវបាន) យកជាគំរូតាង

**sampling** ការយកគំរូតាង, ~ bias លំអៀងយកគំរូតាង, ~ domain តំបន់យកគំរូតាង, ~ error ល្អៀងយកគំរូតាង, ~ efficiency ប្រសិទ្ធភាពយកគំរូតាង, ~ frame គ្រោងយកគំរូតាង, ~ rate អត្រាយកគំរូតាង, ~ variance វ៉ារីយ៉ង់យកគំរូតាង

**sanction** ទណ្ឌកម្ម, កម្មវិបាក, economic ~ ទណ្ឌកម្មសេដ្ឋកិច្ច

**sanction, with your** ដែលបានការអនុញ្ញាតពីលោកអ្នក

**sanctuary** ទីជំរក, fish ~ កន្លែងអភិរក្សពូជត្រី, wildlife ~ ដែនជំរកសត្វព្រៃ

**saturate v.** ផ្អែក, ធ្វើតិត្ថិកម្ម

**saver** អ្នកសន្សំប្រាក់, សន្និធិការកៈ

**savings** ប្រាក់សន្សំ, សញ្ជ័យ, ~ account គណនី សន្សំ/សញ្ជ័យ, ~ bank ធនាគារសន្សំ/សញ្ជ័យ, ~ curve ខ្សែកោងប្រាក់សន្សំ, ~ bank book សៀវភៅបេឡាសំចៃ

**saw mill** រោងចក្រអារឈើ

**scale** ខ្នាត, ទំហំ, ថ្នាក់, មាត្រដ្ឋាន (នៃផែនទី), economies of ~ សេដ្ឋកិច្ចមាត្រដ្ឋាន

**scarcity** ភាពកំរ, តនុភាព

**scenario** សេណារីយ៉ូ, ឆាក

**schedular tax** ពន្ធវិភាគតាមប្រភេទចំណូល

**schedule, time** តារាងពេល, កាលវិភាគ

**scheme** គ្រោងការ

**scope** វិសាលភាព, ដែនអនុវត្ត (ច្បាប់), ទំហំ

**scrap product** ផលិតផលកាកសំណល់

**scrap/salvage value** តំលៃប្រមូលបានវិញ (ពីការបញ្ចេញលក់ផលិតផលកាកសំណល់)

**sea-damaged** ដែលខូចខាតដោយសារទឹកសមុទ្រ

**seal n. & v.** ១. ត្រា **២.** បោះត្រាបិទ (ឧ. កុងតឺនើរ), sealed tender ការដេញថ្លៃក្នុងស្រោមសំបុត្របិទជិត

**seaport** កំពង់ផែសមុទ្រ

**seasonal** តាមរដូវ, មានលក្ខណៈរដូវកាល

**seaworthiness** លទ្ធភាពធ្វើដំណើរតាមសមុទ្រ

**secondary** បន្ទាប់បន្សំ, ~ need តំរូវការបន្ទាប់បន្សំ, ~ data ទិន្នន័យប្រភពទីពីរ

**secondary school** សាលាមធ្យមសិក្សា, higher ~ សាលាមធ្យមសិក្សាទុតិយភូមិ, lower ~ សាលាមធ្យមសិក្សាបឋមភូមិ

**second-stage unit** (SSU) ឯកតាដំណាក់ទីពីរ

**secretariat** លេខាធិការដ្ឋាន

**secretary** លេខាធិការ, ~ general អគ្គលេខាធិការ, ~ of state រដ្ឋលេខាធិការ

**sector n.** វិស័យ, ~ -wide ទូទាំងវិស័យ

**sectoral adj.** តាមវិស័យ, ~ level កំរិតវិស័យ

**secured** មានការធានា, assets fully ~ ទ្រព្យសកម្មមានការធានាពេញលេញ

**securities** មូលប័ត្រ, ~ market ផ្សារមូលប័ត្រ

**security** ១. សន្តិសុខ, food ~ សន្តិសុខស្បៀង ២. ការធានា ៣. របស់ធានា (ប្រាតិភោគ) ៤. អ្នកធានា

**Security Council** (UN) ក្រុមប្រឹក្សាសន្តិសុខ (អសប)

**security, without** ដោយគ្មានវត្ថុធានា

**SEDP** (Socio-Economic Development Programme) ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច

**seed n.** គ្រាប់ពូជ, ~ capital ទុន ដើម/ពូជ (ដើម្បីឱ្យបានដុះដាល), ~ money ប្រាក់ ដើម/ពូជ

**seizure** ការរឹបអូស

**selection** ការជ្រើស, ការជ្រើសរើស, ~ error ល្បៀងក្នុងការជ្រើស, ~ interval ចន្លោះជ្រើស, tentative ~ ការជ្រើសបណ្តោះអាសន្ន

**self-determination** ស្វ័យសំរេច

**self-employed people** ជនបំរើអាជីពឱ្យខ្លួនឯង

**self-financing** ស្វ័យហិរញ្ញប្បទាន

**self-help approach** វិធីសាស្ត្រជួយខ្លួនឯង

**self-managing** ស្វ័យគ្រប់គ្រង

**self-regulating mechanism** យន្តការស្វ័យកែតំរូវ

**self-reinforcing system** ប្រព័ន្ធស្វ័យពង្រឹង

**self-reliance** ភាពម្ចាស់ការ, ការពឹងផ្អែកលើខ្លួនឯង

**self-sufficiency** ភាពអាចផ្គត់ផ្គង់ខ្លួនឯងគ្រប់

**self-sustaining** ស្វ័យទ្រទ្រង់

**self-weighting** ស្វ័យទំងន់, ~ design ប្លង់ស្វ័យទំងន់, ~ sample គំរូតាងស្វ័យទំងន់

**sell** លក់, ~ at auction លក់ដេញថ្លៃ, ~ at a discount លក់ចុះថ្លៃ, ~ on credit លក់ជឿ, ~ up ប្រមូលលក់ក្រោយពេលក្ស័យធន, ~ retail លក់រាយ

**seller, best** សៀវភៅលក់ដាច់បំផុត

**seller, quick** ទំនិញលក់ដាច់ឆាប់ (ងាយលក់)

**selling** ការលក់, ~ order បញ្ជាលក់, ~ price ថ្លៃលក់

**semi-autonomous** ពាក់កណ្តាលស្វយ័ត

**semiconductor** អង្គធាតុពាក់កណ្តាលចំលង (អេឡិចត្រូនិក)

**semi-finished product** ផលិតផលពាក់កណ្តាលសំរេច

**send back v.** ផ្ញើត្រឡប់វិញ

**send for collection v.** ផ្ញើទៅប្រមូលប្រាក់

**sender** អ្នកផ្ញើ

**senior adj.** ថ្នាក់ខ្ពស់, ~ minister ទេសរដ្ឋមន្ត្រី, ~ officer មន្ត្រីថ្នាក់ខ្ពស់

**seniority** អតីតភាព, promotion by ~ តំលើងថ្នាក់តាមអតីតភាព

**sensitive issue** បញ្ហារសើប

**sensitivity** ភាពរសើប, ភាពឆាប់រំភើប, ភាពឆាប់ញោច, វេទយិតភាព, ~ analysis វិភាគនៃវេទយិទភាព

**sensitise v.** បំផុសការភ្ញាក់រលឹក

**series of reports** កំរងរបាយការណ៍

**servant** អ្នកបំរើ, civil ~ មន្ត្រីរាជការស៊ីវិល, public ~ មន្ត្រីរាជការ

**service** សេវា, សេវាកម្ម, ~ fees កំរៃសេវា, ~ contract កិច្ចសន្យាសេវា, ~ charge ថ្លៃសេវា ~ industry ឧស្សាហកម្មសេវា

**service v. a debt** សងការប្រាក់

**session** សម័យប្រជុំ, plenary ~ សម័យប្រជុំពេញអង្គ

**set n.** សំរាប់ (ឧ. កូនសោមួយសំរាប់), បណ្តុំ

( ឧ. បណ្ដុំគោលដៅ)
**settlement** ដំណោះស្រាយ, ការទូទាត់, final ~ ការទូទាត់ផ្ដាច់, ~ bank ធនាគារទូទាត់, ~ credit ឥណទានទូទាត់
**several** (liability) ដាច់ពីគ្នា, រៀងៗខ្លួន ( ការទទួលខុសត្រូវមិនរួមគ្នា)
**severance payment** (or golden handshake) ប្រាក់បំណាច់ពេលឈប់ធ្វើការ, ប្រាក់បើកផ្ដាច់
**sex worker** អ្នករកស៊ីផ្លូវភេទ
**share n.** ហ៊ុន, សន្លឹកហ៊ុន, ~ market ផ្សារហ៊ុន
**share n. & v.** ១. ចំណែក, market ~ ចំណែកទីផ្សារ ២. ចែករំលែក, ~ experiences ចែករំលែកបទពិសោធន៍
**shareholder** អ្នកកាន់ភាគហ៊ុន, ភាគទុនិកៈ, influential ~ ភាគទុនិកៈមានឥទ្ធិពល
**sharing** ភាគកម្ម, ការបែងចែក
**shelter n.** ជំរក, tax ~ ជំរកចៀសពន្ធ
**shipped bill of lading** អញ្ញាតប័ណ្ណដឹកទំនិញតាមនាវា
**shipped quality** គុណភាព( ទំនិញ) ពេលផ្ទុក
**shipping agent** ភ្នាក់ងារនាវាចរ
**shipping company** ក្រុមហ៊ុននាវាចរ
**shipping note** លិខិតបញ្ជូនទំនិញ
**shop around v.** រកមើលទំនិញ ( ថ្លៃ, គុណភាព... ដើម្បីទិញ), ជ្រើសទំនិញមើល
**shoplifting** ការលួចឥវ៉ាន់ក្នុងហាង
**shopping n.** ការដើរទិញទំនិញ, international ~ ការពិគ្រោះថ្លៃជាអន្តរជាតិ
**short bill** រូបិយាណត្តិកំណត់រយៈពេលខ្លី
**short delivery** ការប្រគល់ទំនិញខ្វះ
**short notice, at** ជូនដំណឹងមុនរយៈពេលខ្លី
**short of, be v.** ខ្វះខាត, អស់
**short term** រយៈពេលខ្លី, ~ payoff ផលរយៈពេលខ្លី
**shortage** កង្វះ, ការក្រខ្សត់, ~ in weight កង្វះទំងន់
**short-change v.** អាប់ ( ប្រាក់) ខ្វះ
**shortcoming** កង្វះខាត
**shortfall** កង្វះ ( ថវិកា), ចំនួនខ្វះ
**short-season rice** ស្រូវស្រាល
**show of hands n.** ការបោះឆ្នោតដោយលើកដៃ
**sick leave** ការឈប់សំរាកពេលឈឺ
**sick pay** ប្រាក់ឧបត្ថម្ភពេលឈឺ
**side effect** ផលប៉ះពាល់បន្ទាប់បន្សំ, បច្ច័យរង
**sight bill/draft** រូបិយាណត្តិបង្ហាញ ( ប្ដូរយកប្រាក់បានទៅពេលបង្ហាញ)
**sight payment** ការសងប្រាក់ពេលបង្ហាញឯកសារ
**sight deposit** ប្រាក់បញ្ញើអាចបើកបានតាមសំណើ ( ដោយពុំចាំបាច់ផ្ដល់ដំណឹងមុនឱ្យធនាគារ)
**signatory** ហត្ថលេខី
**significance** សារៈសំខាន់
**silting** (of waterways) ការដុះដី
**silviculture** រុក្ខវប្បកម្ម
**simple** សាមញ្ញ, ~ entry លេខនាសាមញ្ញ ( មានចុះគណនីតែ ១គូ), ~ interest ការប្រាក់សាមញ្ញ ( គិតលើតែប្រាក់ដើម)
**simple random sampling** ការយកគំរូតាងចៃដន្យសាមញ្ញ
**simple response variance** វ៉ារីយ៉ង់ចំលើយសាមញ្ញ
**simple unbiased estimate** ការប៉ាន់ស្មានសាមញ្ញមិនលំអៀង
**simplification n.** ការធ្វើសាមញ្ញកម្ម, ~ of

customs procedures ការធ្វើសាមញ្ញកម្មនីតិវិធីគយ
**simplify n.** ធ្វើអោយសាមញ្ញ
**simulation** ការធ្វើត្រាប់តាម
**sine qua non condition** លក្ខខណ្ឌខានមិនបាន
**single entry** (accounting) របៀបចុះបញ្ជីឯកភាគ
**single indicator technique** បច្ចេកទេសអាំងឌីកាទ័រទោល
**single window** ច្រកចេញចូលតែមួយ
**sinking fund** មូលនិធិដាក់សន្សំបំរុង (ទឹកប្រាក់ដកមករក្សាទុកដោយឡែកយ៉ាងទៀងទាត់ សំរាប់ដោះស្រាយតំរូវការអ្វីមួយនាអនាគតដូចជាសងបំណុលជាដើម)
**Sino-Khmer** ខ្មែរកាត់ចិន
**site** ទីកន្លែង
**size** ទំហំ
**skill** ជំនាញ, life ~ បំណិនជីវិត
**slogan** ពាក្យស្លោក
**slope of a curve/line** ចំណោតនៃ ខ្សែកោង/បន្ទាត់
**sloppy adj.** ខ្ជីខ្ជា, ~ work ការងារខ្ជីខ្ជា
**slum n.** សង្កាត់ក្រីក្រ(រខេករខាក), ~ -dwellers អ្នករស់នៅក្នុងសង្កាត់ក្រីក្រ
**slush fund** ហិបខ្មៅ (បង្កើតដោយសំងាត់)
**small-scale** ខ្នាតតូច
**SME** (small and medium enterprise) សហគ្រាសធុនតូច និងមធ្យម
**smoking gun** ភស្តុតាងក្តៅៗ
**smooth adj.** រលោង, រលូន, ~ operation ដំណើរការរលូន (ល្អ)
**smuggler** អ្នករត់ពន្ធ
**smuggling** ការរត់ពន្ធ
**social** នៃសង្គម, សង្គមកិច្ច, ~ cost បន្ទុកសង្គម, ការខាតបង់ខាងសង្គមកិច្ច, ~ cost-benefit analysis (SCBA) ការវិភាគចំនាយ និងផលចំនេញខាងសង្គមកិច្ច, ~ impact ផលប៉ះពាល់សង្គម, ~ insurance cost បន្ទុកចំណាយធានារ៉ាប់រងសង្គម, ~ justice យុត្តិធម៌សង្គម, ~ morality សីលធម៌សង្គម, ~ order សណ្តាប់ធ្នាប់សង្គម, ~ product ផលិតផលសង្គម, ~ reintegration បុនសមាហរណកម្មសង្គមកិច្ច, ~ safety net ប្រព័ន្ធសុវត្ថិភាពសង្គម, ~ security/welfare (budget expenditure) ប្រាក់វិភាជន៏សង្គម, ~ security សន្តិសុខសង្គម, ~ security contribution វិភាគទានសន្តិសុខសង្គម, ~ status ឋានៈ (ក្នុង) សង្គម, ~ strictures បញ្ញត្តិសង្គម,
**socio-economic adj.** សេដ្ឋកិច្ច-សង្គមកិច្ច, ~ policy គោលនយោបាយសេដ្ឋកិច្ច-សង្គមកិច្ច, ~ survey អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច
**sociology** សង្គមវិទ្យា
**soft currency** រូបិយវត្ថុខ្សោយ (មិនអាចប្តូរយករូបិយវត្ថុដទៃទៀតបាន)
**soft goods** ទំនិញវាយនភ័ណ្ឌ
**soft loan** កំចីមានការប្រាក់ទាប (ទាបជាងអត្រានៅទីផ្សារ), កំចីគ្មានការប្រាក់
**soft market** ទីផ្សារមានការផ្គត់ផ្គង់ច្រើនជាងតំរូវការ
**soft repayment terms** លក្ខខណ្ឌសងអនុគ្រោះ
**software** (computer) សូហ្វវែរ
**soil erosion** ការច្រោះដាច់ដី
**sole agency** ទីភ្នាក់ងារផ្តាច់មុខ

**sole agent/representative** តំណាងផ្ដាច់មុខ
**sole distributor** អ្នកបែងចែកផ្ដាច់មុខ
**sole proprietorship** ១. ឯកកម្មសិទ្ធិ
២. សហគ្រាសឯកបុគ្គល
**solicitor** អ្នកច្បាប់ (ភាគច្រើន ជួយពិគ្រោះយោបល់ និងរៀបចំឯកសារខាងច្បាប់)
**solidarity n.** សាមគ្គីភាព
**solvency** សាធនភាព, លទ្ធភាពសងបំណុល
**solvent** សាធនីយ (ដែលអាចសងបំណុល)
**sophisticated technology** បច្ចេកវិទ្យាជឿនលឿននិងស្មុគស្មាញ
**sort v.** រៀបតាមលំដាប់
**sound adj.** ត្រឹមត្រូវ, ប្រកបដោយគតិបណ្ឌិត
**sound the market v.** ស្ទាបស្ទង់ទីផ្សារ
**South, the** ទក្សិណប្រទេស(ប្រទេសក្រ)
**sovereign immunity** អភ័យឯកសិទ្ធិរដ្ឋ (សិទ្ធិរបស់រដ្ឋដើម្បីបានរួចផុតពីការប្ដឹងទារសំណងខូចខាត)
**sovereign risk** ហានិភ័យរដ្ឋាភិបាលមិនអាចសងប្រាក់
**sovereignty** អធិបតេយ្យភាព
**spatial sampling** ការយកគំរូតាងតាមកន្លែង
**special drawing rights** (SDR) សិទ្ធិដកពិសេស
**special economic zone** តំបន់សេដ្ឋកិច្ចពិសេស
**special promotion zone** (SPZ) តំបន់អភិវឌ្ឍន៍ពិសេស
**speciality** ឯកទេស, របស់ពិសេស
**specialisation** ឯកទេសនីយកម្ម, ជំនាញនីយកម្ម
**specialised bank** ធនាគារឯកទេស
**specific period of time** រយៈ/កំណត់ពេលជាក់លាក់
**specification** យថាប្រភេទ
**specify v.** បញ្ជាក់, កំណត់, specified period កាល កំណត់/បញ្ញត្តិ
**specimen** គំរូបង្ហាញ, បដិរូប, ~ signature គំរូហត្ថលេខា
**speculation n.** ១. ការឆក់ឱកាសកេងចំណេញ (ក្នុងការទិញ/លក់), oil ~ ការឆក់ឱកាសកេងចំណេញក្នុងប្រេងកាត
២. ការវាយស្មាន, pure ~ ការវាយស្មានសុទ្ធសាធ
**spoilage n.** ១. ការខូចគុណភាព (របស់ហូប)
២. របស់ខូចគុណភាព
**spoils** ជ័យភ័ណ្ឌ, វត្ថុរឹបអូសបាន
**spot price** ថ្លៃទិញលក់ដល់ដៃ (ទូទាត់ និងប្រគល់ទំនិញភ្លាមៗ)
**spouse** សហព័ទ្ធ
**spread, spreading n.** ការរីករាលដាល
**squeeze v. expenditure** រឹតត្បិតចំណាយ
**stabilisation** ស្ថិរកម្ម/ស្ថិរភាវូបនីយកម្ម, ~ policy នយោបាយស្ថិរកម្ម
**stability, economic** ស្ថិរភាពសេដ្ឋកិច្ច
**stable exchange rate** អត្រាប្ដូរប្រាក់មានស្ថិរភាព
**staff** បុគ្គលិក
**stage n.** ដំណាក់, ដំណាក់កាល
**stagflation** (stagnation + inflation) ការស្ដីកទ្រឹងមានអតិផរណា
**stagnation** ការស្ដីកទ្រឹង, អវឌ្ឍនភាព, economic ~ ការស្ដីកទ្រឹងសេដ្ឋកិច្ច
**stake** ភាគកម្ម, ការចូលហ៊ុន
**stakeholder** អ្នកមានភាគហ៊ុន, អ្នកពាក់ព័ន្ធ
**stamp duty** ពន្ធតែម
**standard** ស្តង់ដារ, ~ cost តំលៃស្តង់ដារ,

~ deviation គំលាតស្តង់ដារ, draft ~ ស្តង់ដារព្រាង, compulsory ~ ស្តង់ដារបញ្ជា, gold ~ ស្តង់ដារ/ខ្នាត មាស, ~ of living or living standard កំរិតជីវភាព, up to ~ ដល់កំរិតស្តង់ដារ ~ operating procedures នីតិវិធីប្រតិបត្តិការស្តង់ដារ

**standard-conversion factor** (SCF) កត្តាបំលែងស្តង់ដារ

**standardisation** ស្តង់ដារូបនីយកម្ម

**stand-by adj.** ត្រៀម, ~ agreement កិច្ចព្រមព្រៀងត្រៀម, ~ credit ឥណទានត្រៀម

**standing** (bank) ស្តង់ឌិង/ស្ថានភាព, bank of good ~ ធនាគារមានស្តង់ឌិងល្អ

